ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 11-Jan-2012, 15:41
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១០ ខែមករា ឆ្នាំ២០១២**

**ម៉ោង ០៩: ០៧នាទី**

**សវនាការលើកទី១២**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms. Faiza ZOUAKRI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក វីល្លៀម ស្មីត *(Mr.William Smith)*

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

លោក សេង ប៊ុនឃាង

លោក វេង ហ៊ាត់

លោក ច័ន្ទ តារាស្មី

លោក វ៉ាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោក ឡោ ជុនធី

លោកស្រី ស៊ីន សុវ៉ន

កញ្ញា ម៉ុច សុវណ្ណារី

លោកស្រី នូស៊ីន សាកាវ៉ាទី

*(Ms. Nushin SARKARATI*

កញ្ញា ហ្វីលីពីន ស៊ុតហ្ស៍ *(Ms.Phillipine SUTZ)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

**មន្ត្រីអង្គភាពគាំពារសាក្សី/អ្នកជំនាញ៖**

លោក ញ៉ែម សំណាង

## បញ្ជីឈ្មោះអ្នកនិយាយ៖

### ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល | បារាំង |
| លោក ច័ន្ទ តារាស្មី | ខ្មែរ |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក ហ្សាស្តើ ប៉ៅ | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វតៈ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក បាណាបេ ណោគ្វី | បារាំង |
| លោក រម៉ាម យុន | ខ្មែរ |
| លោក ក្លាន រ៉ិត | ខ្មែរ |
| លោក នួន ជា | ខ្មែរ |
| លោក ញ៉ែម សំណាង | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅ ជនជាប់ចោទ នួន ជា**

ស្តួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................................................................ទំព័រ ៨

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី រ៉ោម យុន** (TCP-123)

សួរដោយលោក អាង ឧត្តម ផ្តើមពី.......................................................................ទំព័រ ៥៣

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី...........................................................ទំព័រ ៦៣

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី ក្លាន ទ៊ុត** (TCP-185)

សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល ផ្តើមពី....................................................ទំព័រ ៧០

សួរដោយលោក ច័ន្ទ តារាស្មី ផ្តើមពី....................................................................ទំព័រ ៧៧

# កិច្ចដំណើរការនីតិវិធី

[០៩:០៧:២៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការពិភាក្សាដេញដោលលើភស្តុតាងក្នុងសំណុំរឿងលេខ ០០២។ កាលពីចុងខែធ្នូ ឆ្នាំ២០១១ សវនាការចុងក្រោយបង្អស់គឺអង្គជំនុំជម្រះបានដំណើរការសួរចម្លើយជនជាប់ចោទ នួន ជា លើអង្គហេតុសម្រាប់វគ្គទីមួយ អំពីប្រវត្តិសាវតារបក្សកុម្មុយនីស្តកម្ពុជា ហើយបញ្ហានេះគឺការពិភាក្សាដេញដោលពិនិត្យលើភស្តុតាងមិនទាន់ចប់ទេ។ ហេតុដូច្នេះអង្គជំនុំជម្រះ បន្តការសួរចម្លើយលោក នួន ជា នៅព្រឹកនេះ។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំលោក នួន ជា មកកាន់ឈើរាងវង់ក្រចកសេះនៅពីមុខអង្គជំនុំជម្រះ។

*(ជនជាប់ចោទ នួន ជា ទៅកាន់ឈើរាងវង់ក្រចកសេះ)*

[០៩:០៩:១៧]

**លោក ម៉ៃខល ផេសមិន៖**

សូមគោរពលោក លោកស្រីចៅក្រម ខ្ញុំសូមទាញមតិបន្តិច គឺថា ទាក់ទងទៅនឹងការសួរចម្លើយនេះខ្ញុំមានមតិដើម្បីជម្រាបជូនជាបឋមសិន។ សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីការពារ មេធាវីអន្តរជាតិការពារក្តីឲ្យ នួន ជា ចង់មានយោបល់អីសូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមលើកនូវបញ្ហាមួយកាលពីម្សិលមិញនេះ ខ្ញុំបានទទួលអត្ថបទសារព័ត៌មានជាធម្មតាមួយរបស់តុលាការ គឺមានអត្ថបទសារព័ត៌មានមួយដែលនិយាយនៅក្នុងសារព័ត៌មានដែលនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់នៅក្នុងសន្និសីទកាសែតមួយ នៅក្នុងសប្តាហ៍កន្លងទៅនៅវៀតណាម។ នៅក្នុងសន្និសីទនេះ គាត់បាននិយាយថា តាមអ្នកសារព័ត៌មានដែលវត្តមាននៅទីនោះ ដែរថា នួន ជា សេចក្តីថ្លែងការណ៍របស់ នួន ជា នៅក្នុងតុលាការនៅក្នុងខែធ្នូ គឺការបោកបញ្ឆោត ដែលអ្នកសារព័ត៌មាននោះបានស្តាប់ឮ ហើយក៏គាត់ហៅកូនក្តីរបស់

ខ្ញុំថា ជាឃាតក ហើយជាចារីនៃបទប្រល័យពូជសាសន៍។ នេះគឺជាសេចក្តីថ្លែងការណ៍ច្បាស់ដែលកាសែតនោះ ដែលគេបញ្ជាក់ថា លោក នួន ជា មានពិរុទ្ធភាពដោយ បញ្ជាក់ដោយមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលកម្ពុជា ដែលថា នេះគឺជាការលើកឡើងទាក់ទងទៅនឹងសិទ្ធិរបស់កូនក្តីរបស់ខ្ញុំ ក្នុងការទទួលការជំនុំជម្រះដោយយុត្តិធម៌ ហើយនិងសិទ្ធិទទួលបាននូវការចាត់ទុកថាជាជនគ្មានទោសរហូត ទាល់តែតុលាការរកឃើញ។

[០៩:១១:២៦]

ដូច្នេះ សេចក្តីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីនៅក្នុងករណីនេះ ហាក់ដូចជាការប៉ះពាល់ទៅដល់កិច្ចការរដ្ឋបាលរបស់តុលាការ។ ហើយតុលាការសិទ្ធិមនុស្សរបស់អឺរ៉ុប ដែលឡឺម៉ុងដ៍ ដែលប្រឆាំងនឹងប្រទេសបារាំងនោះ ហើយក៏មានលើកឡើងនូវចំណុចមួយសំខាន់ជាទូទៅ ទាក់ទងនឹងបញ្ហា ស្រដៀងនឹងបញ្ហានេះដែរ។ ហើយខ្ញុំសូមអនុញ្ញាតឲ្យតុលាការពិនិត្យមើលសេចក្តីសម្រេចរបស់តុលាការនោះ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបនោះ បានសម្រេចថា សេចក្តីសម្រេចរបស់តុលាការនោះ បញ្ជាក់ថាការបញ្ជាក់របស់មន្ត្រីសាធារណៈនិយាយអំពីពិរុទ្ធភាពរបស់ជនណាម្នាក់មុនពេលដែលតុលាការសម្រេចនោះ គឺបុរេនិច្ឆ័យ ហើយតុលាការត្រូវវាយតម្លៃលើអង្គហេតុដែលថា ផ្អែកទៅលើយុត្តាធិការរបស់តុលាការ ទើបអាចសម្រេចបានថា ពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះ។

[០៩:១២:៣៥]

នៅក្នុងករណីកូនក្តីរបស់ខ្ញុំនេះ គឺថាពេលដែលមន្ត្រីជាន់ខ្ពស់សម្តែងមតិបែបនេះ គឺហាក់ដូចជាដាក់បន្ទុកទៅលើរឿងក្តីរបស់កូនក្តីខ្ញុំ អាចនឹងប៉ះពាល់ទៅដល់ឯករាជ្យភាពរបស់តុលាការ របស់ចៅក្រមនៅក្នុងតុលាការផងដែរ។ ដូច្នេះហើយអាចនឹងបញ្ជាក់ថា-- ហើយយើងខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមជំទាស់នឹងការថ្លែងការណ៍យ៉ាងរឹងមាំ ហើយសូមអនុញ្ញាតឲ្យតុលាការថ្កោលទោស ឬក៏ប្រកាសចាត់ទុកជាមោឃៈចំពោះសេចក្តីថ្លែងការណ៍នោះ ហើយនិងបញ្ជាក់ថា ការបញ្ជាក់បែបនោះ គឺប៉ះពាល់ដល់សិទ្ធិរបស់កូនក្តីរបស់ខ្ញុំក្នុងការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ គឺអាស្រ័យលើលោក លោកស្រីចៅក្រម ដោយផ្អែកលើសុចរិតភាព និងភាពអាណាគិតរបស់តុលាការនេះ ក្នុងការវិនិច្ឆ័យទៅលើសេចក្តីថ្លែងការណ៍នោះ។ សូមអរគុណលោកប្រធាននិងតុលាការ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត មុននឹងផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរ

ចំពោះលោក នួន ជា។ អង្គជំនុំជម្រះសម្រេចទៅលើការជំទាស់របស់លោក នួន ជា អំពីការប្រើប្រាស់ឯកសារអេឡិចត្រូនិចនៅក្នុងសំណុំរឿងដែលបានធ្វើការជំទាស់នៅថ្ងៃចុងក្រោយនៃសវនាការនៅក្នុងខែធ្នូ ឆ្នាំ២០១១ កន្លងមក។

អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់អំពីការជំទាស់របស់មេធាវីការពារក្តី ដែលបានស្នើសុំដល់អង្គជំនុំជម្រះ ឲ្យបដិសេធនូវឯកសារថតចម្លងនៃទស្សនាវដ្តីទង់បដិវត្តធ្វើជាភស្តុតាង ដោយហេតុថាឯកសារមួយនេះមិនមែនជាឯកសារយថាភូត។ ឯកសារលេខD243/2.1.12 អង្គជំនុំជម្រះកត់សម្គាល់ថា ក្រៅពីការបង្ហាញថាឯកសារខាងលើនេះជាឯកសារថតចម្លងនោះ មេធាវីការពារក្តីមិនបានបង្ហាញអំណះអំណាងផ្សេងទៀតនោះទេ។

ដោយអនុលោមវិធាន៨៧(១)នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិគ្រប់គ្រាន់ក្នុងការសម្រេចនៅពេលឯកសារត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

អង្គជំនុំជម្រះយល់ឃើញថា ឯកសារទស្សនាវដ្តីទង់បដិវត្តខាងលើនេះ ពុំស្ថិតនៅក្នុងប្រភេទនៃឯកសារណាមួយដូចមានចែងនៅក្នុងវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងឡើយ។ ឯកសារនេះ គឺជាប់ពាក់ព័ន្ធទៅនឹងសំណុំរឿង។ ហេតុដូច្នេះហើយអង្គជំនុំជម្រះសម្រេចទទួលយកធ្វើជាឯកសារភស្តុតាង អនុលោមតាមវិធាន៨៧(១) នៃវិធានផ្ទៃក្នុង។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងទទួលយកឯកសារនេះ។

អង្គជំនុំជម្រះសូមគូសបញ្ជាក់ថាការតវ៉ាដែលលើកឡើងដោយមេធាវីការពារក្តី គឺពាក់ព័ន្ធទៅនឹងខ្លឹមសារនៃឯកសារដែលបញ្ហានេះ អង្គជំនុំជម្រះនឹងពិចារណានៅពេលបញ្ចប់កិច្ចពិភាក្សាដេញដោលពោលគឺនៅពេលដែលពិនិត្យពិចារណាលើភស្តុតាងទាំងមូល។

[០៩:១៧:២៣]

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការបន្ត។

សូមអញ្ជើញលោក នួន ជា។

**លោក នួន ជា៖**

សូមគោរពលោកប្រធាន! ដោយសុខភាពខ្ញុំ វាចេះតែទន់ខ្សោយទៅៗ ខ្ញុំសូមស្នើដូចតទៅនេះ៖

មួយ សូមធ្វើសវនាការពេលព្រឹក មួយពេលព្រឹក ឯពេលរសៀលខ្ញុំសុំ ខ្ញុំទៅមិនរួចទេ ពីព្រោះសុខភាពវាចេះតែទន់ខ្សោយទៅៗ វាប៉ះពាល់ដល់បេះដូង ដល់ខួរក្បាល។ ដូច្នោះខ្ញុំស្នើសម្រាក ខ្ញុំស្នើផ្អាកថ្ងៃរសៀល សុំធ្វើមួយពេល ពេលព្រឹក។ ស្នើលោកប្រធានមេត្តាអនុញ្ញាត បើអនុញ្ញាតបាន។

[០៩:១៨:៣៥]

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោក នួន ជា ដែលបានបង្ហាញនូវជំហរច្បាស់លាស់អំពីការចូលរួមនៅក្នុងការឆ្លើយទៅនឹងសំណួរផ្សេងៗ ហើយដោយសារបង្ហាញអំពីស្ថានភាពនៃសុខភាព។ អង្គជំនុំជម្រះនឹងពិចារណាលទ្ធភាពនេះ ចាប់ពីពេលនេះទៅ ទៅថ្ងៃមុខ ដើម្បីទុកលទ្ធភាពឲ្យលោកមានកម្លាំងសមល្មមសម្រាប់នឹងបន្តការឆ្លើយតបទៅនឹងសំណួរទាំងឡាយ ដែលនឹងសួរដេញដោលនៅក្នុងសំណុំរឿងនេះ។

សូមអញ្ជើញលោកសហព្រះរាជអាជ្ញា!

[០៩:១៩:១៩]

**លោក វីល្លៀម ស្មីត៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម។ ពីថ្ងៃសុក្រនោះ យើងបានទទួលដំណឹងថា សាក្សីនឹងត្រូវស្តាប់នៅព្រឹកនេះ ប៉ុន្តែយើងមិនបានឃើញ។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមផ្អាកបន្តិច។ សហព្រះរាជអាជ្ញា សូមអង្គុយចុះសិន!

ដោយអម្បាញ់មិញនេះ ខាងលោកចៅក្រម ហ្សង់ម៉ាក បានបង្ហាញថាគាត់ស្តាប់នូវការបកប្រែជាភាសាបារាំងនូវសេចក្តីសម្រេច ដែលខ្ញុំបានអានអម្បាញ់មិញនេះ អំពីសេចក្តីសម្រេចលើបណ្តឹងជំទាស់ឯកសារអេឡិចត្រូនិច ដើម្បីឲ្យបានកាន់តែច្បាស់លាស់សូមប្រគល់វេទិកាទៅលោកចៅក្រមហ្សង់ម៉ាក ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់លាស់ថែមទៀត អំពីភាសាបារាំង ដែលលោកយល់ថាមិនទាន់ច្បាស់នេះ។ សូមអញ្ជើញ!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ, លោកប្រធាន ខ្ញុំចង់បំភ្លឺខ្លឹមសារនៃសេចក្តីសម្រេចដែលបានចេញជាផ្ទាល់មាត់ ដោយអង្គជំនុំជម្រះព្រឹកនេះ គឺថាអង្គជំនុំជម្រះឆ្លើយតបទៅនឹងការជំទាស់របស់ភាគីការពារក្តី ដែលទាក់ទងទៅនឹងការទង់បដិវត្តមួយលេខ។ ហើយអ្វីដែលអង្គជំនុំជម្រះបានចង់លើកឡើងនោះ គឺថា បើយើងយោងទៅតាមវិធានផ្ទៃក្នុង គឺថាវាវិធាន ៨៧(១) នៃវិធានផ្ទៃក្នុង គឺថាធាតុផ្សំនៃភស្តុតាងនេះ គឺថាអាចបញ្ចូលទៅក្នុងការជំនុំជម្រះបាន ពិភាក្សាគ្នាបាន ហើយនិងតម្លៃភស្តុតាងនឹងត្រូវបានពិនិត្យនៅពេលក្រោយទៀត។

នេះសេចក្ដីសម្រេច ខ្លឹមសារនៃសេចក្ដីសម្រេច គឺយ៉ាងដូច្នេះឯង គឺថាយើងអាចចាត់ទុកថាភស្តុតាងនេះអាចដាក់ចូលទៅក្នុងការពិភាក្សាដេញដោលគ្នាបាន។

[០៩:២១:៣២]

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម ដែលបានបញ្ជាក់កាន់តែច្បាស់ថែមទៀត។ សូម--

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៣:០០]

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍៖**

លោកស្មីត ទាក់ទងទៅនឹងមតិរបស់លោក ដែលលើកឡើងខាងដើមនោះ ខ្ញុំដូចជាពិនិត្យឃើញថា លោកនឹងសួរត្រឡប់លំដាប់លំដោយឡើងវិញ មែនទេ? អ៊ីចឹងគឺថា តាមសេចក្ដីពន្យល់នោះគឺយើងពិនិត្យឃើញថា យ៉ាងហោចណាស់ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់នោះ គឺមិនមានសុខភាពល្អទេ គាត់មិនអាចធ្វើដំណើរមកបាន ហើយដែលត្រូវទទួលការព្យាបាល ហើយបូកផ្សំជាមួយមតិយោបល់ដែលលោកនួន ជា បានលើកឡើងនៅព្រឹកនេះផងដែរ ធ្វើឲ្យអង្គជំនុំជម្រះយល់ថា ប្រហែលថា យើងត្រូវអនុវត្តទៅតាមលំដាប់លំដោយនេះ។ ហើយខ្ញុំសង្ឃឹមថា លោកអាចអនុវត្តទៅតាមនីតិវិធីនេះបាន ដោយសារថាយើងមានការកែប្រែមួយ ដែលថា អាចនឹងបត់បែន។

[០៩:២៤:០០]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកស្រីចៅក្រម ប៉ុន្តែចំពោះសាក្សី W-185, W-123 នោះគឺថាយើងបានត្រៀមរៀបចំហើយ ទាក់ទងទៅនឹងមតិរបស់មេធាវីការពារលោក នួន ជា ដែលលើកឡើងទាក់ទងទៅនឹងសេចក្ដីថ្លែងការណ៍របស់នាយករដ្ឋមន្ត្រីនោះ ដែលថាអង្គជំនុំជម្រះនោះ គឺត្រូវពិនិត្យលើសេចក្ដីថ្លែងការណ៍នោះដែរទេ ថាតើជាភារកិច្ចចៅក្រមឯករាជ្យ ថាតើត្រូវពិនិត្យមើលលើភស្តុតាង ឬមើលទៅលើសេចក្ដីថ្លែងការណ៍ ឬក៏ការអះអាងផ្សេងៗ ដែលថាស្ថិតនៅក្រៅសំណុំរឿងហ្នឹង។ ហ្នឹងជាមតិឆ្លើយតបទៅនឹងមេធាវីការពារក្ដី។ សូមអរគុណ។

[០៩:២៤:៤៧]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៥:២៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក នួន ជា!

**លោក នួន ជា៖**

ខ្ញុំសូមជម្រាបឲ្យច្បាស់ថែម អំពីទង់បដិវត្ត។ ទង់បដិវត្តនេះ ដែលយកមកបង្ហាញឲ្យខ្ញុំមើលនេះ នែ៎ គឺវពុម្ព ក៏ប៉ុន្តែការជាក់ស្តែង ទង់បដិវត្តដែលធ្វើកាលពីសម័យនោះ សរសេរក្រដាសក្រមួនទេ សរសេរដៃ ហើយយកទៅអូសដាក់ទឹកខ្មៅ។ ដូច្នេះអក្សរវាខុសគ្នា។ អានេះអក្សរពុម្ព ឯខាងទង់បដិវត្ត ដែលចាប់ផ្តើមធ្វើនោះ វាសរសេរដៃទេ មានអ្នកសរសេរដៃផ្សេង។ ដូច្នោះខុសគ្នាឆ្ងាយណាស់ សរសេរដៃ ហើយនិងរ៉ៃ*ដាក់ទីឡូ* នេះ។ នេះខ្ញុំសូមជម្រាបលោកប្រធានឲ្យជ្រាប។ អានេះមិនមែនតែទង់បដិវត្ត យកមកបង្ហាញខ្ញុំនេះ អាហ្នឹងគឺថា រ៉ៃដាក់ទីឡូ ពីព្រោះកាលនោះមិនទាន់មានដាក់ទីឡូ ទេ សរសេរក្រដាសក្រមួន ហើយអូសនឹងក្តារមួយៗបន្ទះប៉ុណ្ណឹង បោះប្រហែលជា២០ ឬ៣០ ក្បាលប៉ុណ្ណឹងទេដើម្បីចែកគ្នាអាន។ សូមជម្រាបលោកប្រធាន។ ដូច្នោះអានេះមិនមែន-- ដែលយកមកនេះមិនមែនជាច្បាប់ដើមទេ។ ខ្ញុំសូមជម្រាបលោកប្រធានតែប៉ុណ្ណឹង សូមលោកប្រធានអធ្យាស្រ័យ។

[០៩:២៧:៣៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សូមគោរពតុលាការ។ សូមគោរពលោកប្រធាន។ ខ្ញុំយល់ថា នេះជាឆន្ទានុសិទ្ធិរបស់តុលាការសម្រេចថា យក ឬមិនយកនៅលើឆន្ទានុសិទ្ធិរបស់តុលាការ។ ក៏ប៉ុន្តែខ្ញុំចង់បន្ថែមទៅលើសម្តីរបស់លោក នួន ជា។ ធម្មតា ហើយជានីតិវិធីរបស់តុលាការប្រទេសកម្ពុជា ដោយក្នុងនេះចៅក្រមមានបួននាក់ជាខ្មែរ ហើយបានអនុវត្តរួចហើយឯកសារណា ដែលមិនមែនជាដើមយកទៅបង្ហាញតុលាការ តុលាការអត់ទទួលស្គាល់ទេ។ ខ្ញុំជឿថាអ៊ីចឹង រួចខ្ញុំបានអនុវត្តច្បាប់ហ្នឹង និងជាមេធាវីជាមួយតុលាការហ្នឹងជិត២០ឆ្នាំ ហើយពេលដែលយកឯកសារកូពីទៅជូន គឺថាទាល់តែយកឯកសារដើមយកមកបញ្ជាក់សិន ហើយបានតុលាការបោះត្រាលើហ្នឹងជូនថា ឥឡូវយកដើមត្រឡប់ទៅវិញចុះ ហើយយកអាកូពីមក

ប្រើការ។ ថាតើតុលាការយើងនេះ អនុវត្តខុសពីហ្នឹង ឬក៏តាមទម្លាប់ ឬក៏តាមច្បាប់នីតិវិធីរបស់តុលាការខ្មែរយើងដែរ?

[០៩:២៩:០៤]

ខ្ញុំអត់-- មិនច្បាស់ទេពីរឿងតុលាការអន្តរជាតិ ហើយតុលាការបរទេស ប៉ុន្តែខ្ញុំច្បាស់ណាស់ក្នុងតុលាការស្រុកខ្មែរ។ បើអ៊ីចឹងទេ ខ្ញុំក៏ក្នុងឋានៈជាមេធាវីរបស់លោក នួន ជា ខ្ញុំក៏សូមបដិសេធទាំងស្រុងចំពោះឯកសារកូពី ដែលយកមកបង្ហាញដោយព្រះរាជអាជ្ញា យកមកបង្ហាញចំពោះតុលាការ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី ដែលបានធ្វើការកត់សម្គាល់ និងបង្ហាញនូវជំហរដូច្នេះ ហើយកាលពីកន្លងទៅគឺមិនបានបង្ហាញជំហរច្បាស់លាស់ដូច្នេះទេ។ បញ្ហាដែលថាតើការអនុវត្តនៅក្នុងការយកឯកសារមកប្រើប្រាស់នៅចំពោះមុខអង្គជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វាដូចគ្នាទៅនឹងការប្រើប្រាស់ឯកសារទាំងឡាយនៅក្នុងតុលាការកម្រិតជាតិដែរឬទេ? បញ្ហានេះបើខ្ញុំមិនច្រឡំទេ ហើយមិនភ្លេចទេ គឺបានបង្ហាញរួចហើយ នៅថ្ងៃដែលលោក នួន ជា ជំទាស់ពីដំបូងដោយសារបញ្ហានៅទីនេះ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។ ឯកសារអេឡិចត្រូនិចនៅក្នុងសំណុំរឿងដ៏ធំធេងនេះ ការគណនារបស់គ្រប់គ្រងសំណុំរឿង គឺគណនាប្រមាណជិតទៅកន្លះលានទំព័រងណោះនៅក្នុងសំណុំរឿងនេះ។

[០៩:៣០:៤១]

ប្រសិនបើយើងយកឯកសារទាំងអស់ជាឯកសារដើម មកបង្ហាញនៅទីនេះ តើយើងប្រើប្រាស់មធ្យោបាយយ៉ាងដូចម្ដេច? ទីមួយ។ ទីពីរ ហេតុអ្វីបានជាយើងប្រើប្រាស់នូវប្រព័ន្ធអេឡិចត្រូនិច ហើយនិងប្រព័ន្ធកុំព្យូទ័រទាំងអស់គ្នា តាំងពីសំណុំរឿង០១មក ហើយរហូតដល់សំណុំរឿង០២ យើងបានធ្វើកិច្ចការទាំងអស់ គឺដោយសារពឹងផ្អែកទៅលើការមើលឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿងដែលបានរៀបចំតាមប្រព័ន្ធព័ត៌មានវិទ្យា ដែលជាឯកសារអេឡិចត្រូនិច។

ទោះបីយ៉ាងណាក៏ដោយលោកបានគិតហើយ ហើយលោកអាចមើលនៅក្នុងសំណុំរឿងដែលនៅចំពោះមុខរបស់លោក ទាំងឯកសារដែលលោកបង្ហាញក៏ដោយ ទំនងជាមិនមានឯកសារដើមទេ។ វាបង្ហាញមិនចេញទេឯកសារនៅទីនេះ ពីព្រោះឯកសារយកមកស្កេនបញ្ចូលទៅក្នុងសំណុំរឿង ហើយឯកសារដើមតម្កល់ទុកនៅឯកន្លែងតម្កល់ឯកសារនៃអង្គជំនុំជម្រះ ឬមួយក៏នៅកន្លែងបណ្ណសារដ្ឋាននៃ

អង្គភាពដែលពាក់ព័ន្ធនឹងបញ្ហាដែលយើងបានយកមកនេះ។

នេះជាបញ្ហាដែលយើងបានប្រើប្រាស់ អ៊ីចឹងហើយបានអង្គជំនុំជម្រះគឺមិនអាចធ្វើអ្វីឲ្យខុសពីអ្វីដែលយើងបានគិតពិចារណា ហើយនិងអភិវឌ្ឍនៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាថ្មី ដែលគេប្រើប្រាស់នៅក្នុងតុលាការអន្តរជាតិនានា។ តុលាការអន្តរជាតិនានាក៏គេប្រើដូចហ្នឹងដែរ ព្រោះយើងយកមកតាមទម្រង់យើងយកមន្ត្រីដែលជំនាញទាំងអស់នោះ យកមកអនុវត្តដូចគ្នានឹងតុលាការអន្តរជាតិដែលប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិច ទៅលើលក្ខណៈ-- ចរិតលក្ខណៈនៃសំណុំរឿងដែលធំធេង។ ហើយនេះជាបញ្ហា។ ហើយបញ្ហាដែលអង្គជំនុំជម្រះបានសម្រេចរួចហើយលើបញ្ហានេះ។ អ៊ីចឹងអង្គជំនុំជម្រះមិនអាចកែប្រែអ្វីបានទៀតទេ ហើយផ្អែកលើមូលដ្ឋាននៃបទប្បញ្ញត្តិដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ដែលអនុវត្តនៅអង្គជំនុំជម្រះវិសាមញ្ញនេះ។

សូមអញ្ជើញផ្តល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះ នួន ជា ជាបន្ត។

[០៩:៣៣:១៥]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោក នួន ជា ប្រហែលជាពេលវេលាមួយសមស្របហើយ ដែលអនុញ្ញាតឲ្យខ្ញុំសូមធ្វើការបញ្ជាក់ អំពីប្រវត្តិសាវតារខ្លះៗទៅនឹងឯកសារទង់បដិវត្ត ដែលទើបតែលើកឡើងអម្បាញ់មិញនេះ។ តើវាជាការត្រឹមត្រូវដែលថាបក្សបានចាប់ផ្តើមបោះពុម្ពទង់បដិវត្ត បន្ទាប់ពីសមាជបក្សលើកទី១ នៅក្នុងឆ្នាំ១៩៦០ តើនេះជាការត្រឹមត្រូវដែរឬទេ?

[០៩:៣៣:៥៧]

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន។ មិនត្រឹមត្រូវទេ ព្រោះទង់បដិវត្តនេះធ្វើមុនកិច្ចព្រមព្រៀងហ្សឺណែវ។ ក្រោយ ពីព្រោះក្រោយកិច្ចព្រមព្រៀង-- អត់ទោស! ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ សហភាពការណ៍វាច្របូកច្របល់ច្រើនណាស់។ ពួកទៅសារភាពក៏មាន ពួករត់ចោលជួរក៏មាន ពួកទៅចូលខ្មាំងវិញក៏

មាន។ ហេតុដូច្នោះ ពេលនោះគណៈអចិន្ត្រៃយ៍ត្រូវមានវិធីដោះស្រាយសតិអារម្មណ៍ឲ្យបក្ខជនទាំងអស់ឲ្យនឹងន។ ដូច្នោះហើយបានជាគិតធ្វើឯកសារទង់បដិវត្ត។ ក៏ប៉ុន្តែ ដូចបានជម្រាបហើយ យើងកាលណោះគ្មានមធ្យោបាយអ្វីក្រៅពីសរសេរក្រដាសក្រមួនទេ ហើយយកបោះពុម្ព ហើយយកចែកអ្នកអានផ្សាយតាំងពីលើទៅដល់ក្រោមរៀនសូត្រឯកសារនេះ ដើម្បីកសាងទស្សនៈ គោលជំហរ សតិអារម្មណ៍ឲ្យរក្សាទុកជាធាតុអ្នកស្នេហាជាតិ ស្នេហាបដិវត្តន៍ ស្នេហាប្រជាជនតទៅទៀត កុំឲ្យខ្ចាត់ខ្ចាយ។ ដូច្នោះមានអី មានតែធ្វើឯកសារហ្នឹង បានចាប់ផ្តើមធ្វើឯកសារទង់បដិវត្តហ្នឹងឡើង។ នេះខ្ញុំសូមជម្រាបប្រវត្តិរបស់វាៗអ៊ីចឹង។

ក្រោយពីធ្វើទង់បដិវត្តហើយ ដូចជាក្រោយរំដោះមានរោងពុម្ព យើងធ្វើទង់ក្រហម ឯទង់ក្រហមហើយនិងទង់បដិវត្តនេះ ខ្លឹមសារវាប្រហាក់ប្រហែលគ្នា។ គ្រាន់តែទង់ក្រហមនេះ វាប្រាំទង់ ឯទង់បដិវត្តមានទង់តែមួយ។ នេះខ្ញុំសូមជម្រាបលោកប្រធានឲ្យជ្រាប។ ខ្ញុំសូមអស់។

[០៩:៣៧:១០]

**ស៖** សូមអរគុណលោក នួន ជា ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចទៀត ដើម្បីឲ្យបានច្បាស់។ លោកបានលើកឡើងថា ទង់បដិវត្ត ត្រូវបានបោះពុម្ពផ្សាយនៅក្នុងទសវត្សរ៍ឆ្នាំ១៩៥០ បន្ទាប់ពីកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ។ ហើយនៅក្នុងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យ និងបានបោះពុម្ពផ្សាយនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ តើត្រឹមត្រូវទេ?

**ឆ៖** ទង់បដិវត្តបោះមុនកម្ពុជាប្រជាធិបតេយ្យ។ កាលណោះមិនទាន់ដាក់ឈ្មោះជាកម្ពុជាប្រជាធិបតេយ្យនៅឡើយទេ។

**ស៖** ក្នុងអំឡុងពេលមុនឆ្នាំ ១៧ មេសា ឆ្នាំ១៩៧៥ តើលោកមានការបោះពុម្ពផ្សាយឯកសារទង់បដិវត្តនេះដែរឬទេ?

**ឆ៖** មុនថ្ងៃ១៧ មេសា ១៩៧៥ តាមខ្ញុំចាំដូចមាន តែមានសម្ងាត់។ អង្កាល់ណោះធ្វើសម្ងាត់ដូចខ្ញុំបានជម្រាបដូចអ៊ីចឹងហើយ។ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ សភាពការណ៍សតិអារម្មណ៍ សភាពការណ៍គោលជំហរអី ខ្ញុំនិយាយតែដដែលចុះ បើលោកប្រធានអនុញ្ញាត។ វាខ្ចាត់ខ្ចាយ ដូច្នោះយើងត្រូវប្រមូលឡើងវិញ។ ដូច្នោះទង់បដិវត្តនេះវាមានមុន ប៉ុន្តែឆ្នាំ ខែណា ខ្ញុំមិនចាំទេ។

[០៩:៣៩:២២]

**ស៖** អ្វីដែលខ្ញុំសួរលោកនេះ តើលោក នួន ជា ថាតើមានរយៈពេលដែលឯកសារនេះបាន

សរសេរត្រូវបានផ្សព្វផ្សាយដោយបានសរសេរដោយដៃ និងតើមានអំឡុងពេលណាដែលឯកសារនេះ ត្រូវបានបោះពុម្ពផ្សាយ ឬក៏វាយជាអក្សរពុម្ពដើម្បីបោះឲ្យបាននូវទង់បដិវត្តនេះ។ ដូច្នេះ សំណួររបស់ខ្ញុំ ដែលចង់សួរនេះ គឺថានៅក្នុងអំឡុងពេលដែលមានរោងពុម្ពនោះ គឺថាឯកសារនេះត្រូវបានបោះពុម្ពក្នុង លក្ខណៈជាឯកសារមួយដែលត្រូវបានវាយជាអក្សរពុម្ព។ តើត្រឹមត្រូវទេ?

**ឆ៖** ពេលដែលមានរោងពុម្ព មានទង់ក្រហម ឯទង់បដិវត្តផ្កាក ប្រែជាទង់ក្រហមវិញ។ ទង់ក្រហមនេះ ទង់មានព៌ណក្រហម តាមខ្ញុំចាំ។

**ស៖** សំណួរខ្ញុំ ចង់សួរថានៅក្នុងអំឡុងពេលដែលមានរោងពុម្ព តើឯកសារទង់បដិវត្តត្រូវបាន បោះពុម្ពក្នុងលំនាំជាឯកសារវាយជាអក្សរពុម្ព ឬក៏បោះជាឯកសារសរសេរដោយដៃ?

**ឆ៖** ឈប់សរសេរដោយដៃហើយ ខ្ញុំសូមគោរពលោកប្រធាន។ ឈប់សរសេរដោយដៃហើយ បោះរោងពុម្ពវិញហើយ។

**ស៖** ដូច្នេះ ជារយៈពេលមុនថ្ងៃ១៧ មេសា ១៩៧៥ ដែលត្រូវឯកសារនេះសរសេរដោយដៃ រៀបចំឡើង។ តើត្រឹមត្រូវទេ?

[០៩:៤១:២៧]

**ឆ៖** មុន ពីព្រោះរំដោះភ្លាមមិនទាន់បានរៀបចំបានភ្លាមទេ។ ពីព្រោះត្រូវរកអ្នកចាប់ពុម្ព ត្រូវ រកអ្នកជំនាញខាងបោះពុម្ព បោះអីនេះ ប្រហែលជាពីរបី-បួនប្រាំខែ ក្រោយតាមខ្ញុំចាំ។ ពីព្រោះវាយូរ ហើយខ្ញុំៗ ខួរក្បាលខ្ញុំក៏វាអន់ដែរ វាភ្លេច។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធានសាជាថ្មី។ ខ្ញុំស្តាប់ទៅដូចជាសហព្រះរាជអាជ្ញា គាត់វង្វេងទេក៏មិនដឹង គាត់សួរត្រឡប់ចុះត្រឡប់ឡើង។ លោក នួន ជា បានបញ្ជាក់ហើយថា ទង់បដិវត្តសរសេរជាដៃៗ មុនរំដោះ មានន័យថា ១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹងដោយដៃ ហើយអត់បានច្រើនទេ បានបួនដប់ម្ភៃ-សាមសិបក្បាលប៉ុណ្ណឹងទេ។ ក្រោយបដិវត្តន៍ ១៧ មេសា ៧៥ អាហ្នឹងបានធ្វើទង់ក្រហម ហ្នឹងវាយដាក់ ទីឡូ។ ខ្ញុំសូមជួយបំភ្លឺឲ្យច្បាស់ បញ្ជាក់ ពីព្រោះអីថ្ងៃនេះលោក នួន ជា បានប្រាប់ខ្ញុំថា គាត់ពីព្រឹក គេវាស់ឈាម គាត់ឃើញ ១៦.១/២ ពេទ្យវាស់ឈាមគាត់ ម្ល៉ោះហើយតាមខ្ញុំមើលកន្លែងខ្លះគាត់ចាប់

ព្រះរាជអាជ្ញាអត់សួរបាន។ ម្ល៉ោះហើយសូមឲ្យព្រះរាជអាជ្ញាសួរចំកន្លែងណា គាត់ឆ្លើយ ហើយកុំសួរត្រឡប់មកក្រោយវិញ ដើម្បីកុំឲ្យបន្ត។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ប៉ុន្តែលោកមេធាវី គប្បីប្រើពាក្យពេចន៍ឲ្យបានសមរម្យ មិនគប្បីប្រើពាក្យប្រមាថទៅភាគីម្ខាងថា វង្វេងអី ដូច្នេះទេ។ យើងបានរំឭកហើយ មុននឹងដេញដោល ប៉ុន្តែរហូតដល់ម៉ោងនេះ នៅតែការប្រើពាក្យពេចន៍មិនទាន់សមរម្យនៅឡើយ។ យើងសង្ឃឹមថា លើកក្រោយប្រហែលជាលោកបានយល់អំពីបញ្ហានេះហើយ។ ការជជែកវែកញែកច្បាប់ មិនមែនសំខាន់ទៅការប្រមាថទៅភាគីម្ខាងហ្នឹង សម្រាប់មានប្រយោជន៍ដល់ខ្លួននោះទេ។

[០៩:៤៤:២៨]

លោកព្រះអាជអាជ្ញាអាចបន្តបាន ហើយលោកមេធាវីក៏គាត់មិនបានធ្វើការអីឲ្យបានច្បាស់លាស់ដែរ ជាការជំទាស់ ក៏មិនមែនដែរ គ្រាន់ជាការសង្កេតប៉ុណ្ណោះ។ អ៊ីចឹង គឺលោកអាចសួរបានដើម្បីបញ្ជាក់អំពីបញ្ហានេះឲ្យបានច្បាស់លាស់ ពីព្រោះបញ្ហានេះជាចំណុចមួយដែលភស្តុតាងដែលត្រូវដេញដោលនៅក្នុងសំណុំរឿងនេះ។ មិនមែនតែរឿងមួយហ្នឹងទេ បានន័យថាមានរឿងច្រើនទៀត ឯកសារជាច្រើនទៀតត្រូវដេញដោលនោះ។

[០៩:៤៥:១០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ត្រឡប់ទៅបញ្ហាមួយទៀតដែលលោកនិយាយអំពីការបោះពុម្ពផ្សាយនូវឯកសារទង់បដិវត្តមែន មានឯកសារដែលលោកលើកឡើងថា មានទង់ប្រាំគឺនៅលើឯកសារទង់បដិវត្ត ហើយមានឯកសារមួយទៀត យើងហៅថា “ទង់ក្រហម” មានទង់តែមួយទេ នៅលើឯកសារនេះ។ ចុះចំពោះ-- មានឯកសារពីរនៅលើឯកសារមួយយើងហៅថា ទង់យុវជនបដិវត្តន៍ មានទង់ពីរ តើត្រឹមត្រូវទេលោក?

**ឆ៖** គោរពលោកប្រធាន លោកព្រះរាជអាជ្ញាសួរដដែលៗ តើលោកប្រធានឲ្យខ្ញុំឆ្លើយដដែលៗទេ?

**ប្រធានអង្គជំនុំ៖**

លោក មកពីលោកឆ្លើយជាមួយគាត់មិនទាន់ច្បាស់ដែរ។ ដូច្នេះលោកអាចឆ្លើយឲ្យចំនឹងសំណួរស្តាប់សំណួរឲ្យបានសឹមឆ្លើយ។ ឆ្លើយឲ្យត្រូវនឹងសំណួរដែលគេសួរ នេះជាគោលដៅនៃការសួរឆ្លើយ

នៅក្នុងតុលាការ។ ចំពោះចម្លើយ ឬសំណួរឥតប្រយោជន៍ ឬយ៉ាងណានោះអង្គជំនុំជម្រះគិតថាចេះពិចារណាហើយនៅពេលដែលបកស្រាយអំពីភស្តុតាង ដើម្បីសម្រេចសេចក្តីនោះ។

អញ្ជើញឆ្លើយនឹងសំណួរ!

**លោក នួន ជា៖**

**ឆ៖** គោរពលោកប្រធាន! ពេលមានរោងពុម្ពហើយ ឈប់ធ្វើទង់បដិវត្តហើយ។ ធ្វើទង់ក្រហមវិញជំនួសទង់បដិវត្ត ឯទង់បដិវត្តឈប់។ ខ្ញុំឆ្លើយខ្លីប៉ុណ្ណឹង។

[០៩:៤៧:១៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សំណួរខ្ញុំគឺថាមានឯកសារមួយទៀត យើងហៅថាជាឯកសារមួយ គឺឯកសារសម្រាប់យុវជនយុវនារីបដិវត្តន៍ ហើយឯកសារនេះគឺមានទង់ពីរ តើត្រឹមត្រូវទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានចាំទេ។

**ស៖** លោក នួន ជា ខ្ញុំសូមបង្ហាញលោកនូវឯកសារបញ្ជាមួយទាក់ទងទៅនឹងទង់បដិវត្តដែលបានបង្ហាញជូនលោកហើយដាក់ជូនទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ នៅក្នុងខែធ្នូ ១៩៦០ ទៅដល់ ១៩៧៦ គឺឯកសារ D243/1.9 --/2.1.9 ហើយខ្ញុំក៏មានជាឯកសារនៅលើក្រដាស ដើម្បីបង្ហាញជូនលោក នួន ជា បានផងដែរ។

លោកចៅក្រម លោកប្រធាន សូមអនុញ្ញាតបង្ហាញលើស្គ្រីនបន្តិចបានទេ ព្រោះខ្ញុំមើលអត់ឃើញមានបង្ហាញនៅលើស្គ្រីន?

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាបង្ហាញឯកសារដែលប៉ុនប៉ងក្នុងការបង្ហាញចុងក្រោយនេះ នៅលើអេក្រង់ទូរទស្សន៍ ដើម្បីឲ្យអង្គជំនុំជម្រះ និងភាគីបានពិនិត្យ។

**លោក ម៉ៃខល ផេសមិន៖**

សូមអធ្យាស្រ័យអង្គជំនុំជម្រះខ្ញុំអត់បានឃើញឯកសារនេះបង្ហាញនៅលើអេក្រង់ទេ នៅកុំព្យូទ័ររបស់ខ្ញុំនេះ។ អ៎! ចេញមកហើយ សូមអរគុណច្រើន ឃើញហើយ។

[០៩:៥០:៤៩]

**សួរដោយលោក ខេល លីសាក់៖**

**ស៖** ឯកសារដែលខ្ញុំកំពុងនេះបង្ហាញនេះ គឺថាលោកស្រីចៅក្រម ខាត់រាយច៌ បានបង្ហាញជូនមកលោក ហើយដាក់ជូនទៅតុលាការនូវកាលពេលមុន ដែលយើងឃើញថាមានទង់ប្រាំនៅលើក្របមុខនៃឯកសារនេះ។ នេះគឺទំព័រក្របខាងមុខសម្រាប់ការបោះពុម្ពផ្សាយឯកសារទង់បដិវត្តដែលមានទង់ប្រាំនៅលើក្របខាងមុខ ដូចដែលលោករៀបរាប់នោះ មែនទេ?

**លោក នួន ជា៖**

**ជ៖** សូមគោរពលោកប្រធាន! បើខ្ញុំចាំមិនខុសទេនែ៎ ទង់បដិវត្តនេះបោះពណ៌ក្រហមដែរ មិនមែនពណ៌ខ្មៅទេ។

**ស៖** លោក នួន ជា ជាការត្រឹមត្រូវ នេះគឺជាឯកសារថតចម្លង វាពណ៌សខ្មៅអ៊ីចឹងហើយ ហើយគឺថាឯកសារដើម លោកបានលើកឡើងថា ទង់នោះគឺមានពណ៌ក្រហម អ៊ីចឹងមែនទេ លោក?

[០៩:៥២:១៧]

**ជ៖** ជម្រាបលោកប្រធាន ទង់បដិវត្តនេះ វាមានពណ៌ក្រហម។ ពណ៌ក្រហមនេះ គឺពណ៌របស់ទង់។ អ៊ីចឹងហើយបានហៅថា “ទង់ក្រហម”។

**ស៖** ហើយឯកសារនេះ បោះពុម្ពផ្សាយបែបជាព្រឹត្តិបត្រ មានន័យថា ដូចជាសៀវភៅមួយអ៊ីចឹង គឺថាបើកទៅស្រួលអានអ៊ីចឹង។ បើសិនណា បើយើងមើលទៅទំព័រទៅបន្តបន្ទាប់នៃឯកសារនេះ យើងនឹងឃើញថា-- ប៉ុន្តែអត្ថបទដើមតែម្តង អត្ថបទឯកសារនេះតែម្តងគឺមុននឹង-- ដូចលោកបានលើកឡើង មុនពេលយើងឈប់សម្រាកសវនាការលើកមុន គឺថាបោះពុម្ពបែបជាសៀវភៅមួយកូនក្បាលតែម្តង។ តើត្រឹមត្រូវទេ?

**ជ៖** សូមជម្រាបលោកប្រធាន សូមអនុញ្ញាតឆ្លើយ។ បោះជាសៀវភៅ។

**ស៖** ហើយលោកអាចមើលទៅទំព័រចុងក្រោយបំផុតនៃឯកសារនេះ លោក នួន ជា នឹងនោះលោកនឹងឃើញហើយ។ ខ្ញុំសូមមេត្តាឲ្យមានការបង្ហាញឯកសារនេះ គឺទំព័រចុងក្រោយដែលមាន ERN ខ្មែរ គឺ00060058 ឯកសារ ERN 0008363058។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទៅបើកឯកសារជូនលោក នួន ជា មើលឯណោះ។ ឲ្យចំនូវឯកសារដែលសហព្រះរាជអាជ្ញាបានដាក់ឲ្យពិនិត្យទំព័រនោះ ដែលព្រះរាជអាជ្ញាដាក់ឲ្យពិនិត្យ។

[០៩:៥៤:៤០]

*(មន្ត្រីតុលាការរៀបចំឯកសារបង្ហាញជូនជនជាប់ចោទ)*

[០៩:៥៥:៣៦]

**លោក នួន ជា៖**

**ឆ៖** អក្សរពុម្ពនេះ វាតូចណាស់ ក៏ប៉ុន្តែអក្សរពុម្ពដែលវាយទង់បដិវត្តនោះវាធំ វាធំជាងនេះ អក្សរ ខ្ញុំនិយាយពីអក្សរ។ នេះតូចនេះ មិនមែន បើតាមខ្ញុំចាំមិនមែនអក្សរពុម្ពនេះទេ។

**សួរដោយលោក ឌេល លីសាក់៖**

ឯកសារដែលខ្ញុំចង់បង្ហាញជូន ទំព័រដែលខ្ញុំបង្ហាញជូនទំព័រចុងក្រោយគឺមិនមានអក្សរទេ។ គ្រាន់តែមានលេខទំព័រ គឺមានរូបតូចមួយនៃទង់ជានិមិត្តរូបនេះ តើលោកមើលឃើញទេ។ ទំព័រហ្នឹងគឺមិនមានជាអក្សរអីទេ គឺជាភាសាខ្មែរមាន ERN 00063058។

**ស៖** សំណួរខ្ញុំសួរទៅលោកនោះ លោក នួន ជា គឺថាទំព័រនេះបានបង្ហាញនៅលើអេក្រង់កុំព្យូទ័រហើយ។ សំណួរខ្ញុំសួរថា តើព្រឹត្តិបត្រទង់បដិវត្តនៅទំព័រចុងក្រោយ មានរូបទង់តែមួយទេ។ ដោយក្នុងនោះគឺមានរូបកណ្តៀវ និងរូបញញួរមួយនៅក្នុងទង់នេះ។ តើត្រឹមត្រូវទេលោក?

**ឆ៖** គោរពលោកប្រធាន! បញ្ហានេះវាយូរណាស់ហើយ ខ្ញុំចាំមិនបានទេ។

**ស៖** ត្រឡប់ទៅនឹងសំណួរទាក់ទងនឹងមហាសន្និបាតបក្សលើកទីមួយ។ ខ្ញុំដឹងថានៅក្នុងសេចក្តីថ្លែងបើករបស់លោក គឺថាមានបញ្ហាបីដែលត្រូវបានសម្រេចនៅក្នុងខែកញ្ញា ១៩៦០ គឺមហាសន្និបាតខែកញ្ញា ១៩៦០ ជាលើកទីមួយហើយ ហើយលក្ខន្តិកៈទីពីររបស់បក្ស ដែលទាក់ទងទៅនឹងការបង្កើតគណៈកម្មាធិការដឹកនាំបក្សនេះ។ ខ្ញុំចង់សួរទៅលោក គឺសំណួរទីមួយ សំណួរទាក់ទងទៅនឹងការចាត់តាំងគណៈកម្មាធិការដឹកនាំបក្ស-- ថ្នាក់ដឹកនាំបក្ស។ ហើយនៅក្នុងសេចក្តីថ្លែងបើកម្តងទៀតនៅក្នុងខែរបស់ខែធ្នូ របស់លោក គឺលោកបានបញ្ជាក់ថា ទូ សាមុត ត្រូវបានតែងតាំងជាលេខាបក្ស ហើយលោកត្រូវបានតែងតាំងជាអនុលេខាបក្សនៅក្នុងមហាសន្និបាត ទសវត្សរ៍ឆ្នាំ១៩៦០។ ហើយខ្ញុំសុំដកស្រង់សម្តី “គឺយើងបានចាត់តាំងគណៈកម្មាធិការមជ្ឈិមបក្ស” បញ្ចប់ដកស្រង់សម្តី។

លោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ ដែលទាក់ទងទៅនឹងសមមិត្តរបស់លោកដែលត្រូវបានចាត់តាំងឲ្យធ្វើជាថ្នាក់ដឹកនាំបក្សនៅក្នុងមហាសន្និបាតឆ្នាំ១៩៦០?

**ឆ៖** សូមគោរពលោកប្រធាន! សំណួររបស់ព្រះរាជអាជ្ញា ខ្ញុំក្តាប់មិនអស់ទេ ក៏ប៉ុន្តែបើឲ្យខ្ញុំនិយាយ ខ្ញុំរៀបរាប់ជម្រាបលោកប្រធានបាន។ បើអនុញ្ញាតឲ្យខ្ញុំនិយាយរៀបរាប់។

[១០:០០:០០]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញ!

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន ឆ្នាំ១៩៥៩ ស៊ីវ ហេង ដែលជាលេខាបក្ស ទៅចូលជាមួយ លន់ នល់ ព្រោះកាលនោះ ត្រូវបង្ក្រាបរាតត្បាតច្រើន ហើយ ស៊ីវ ហេង នេះមានបញ្ហាជីវភាពជីអីផង។ ដូច្នោះបក្សវាគ្មានលេខា។ ដល់គ្មានលេខាបក្សនោះ កាលនោះ ក្រោយកិច្ចព្រមព្រៀង ហ្សឺណែវ ហ្នឹង នៅសល់តែប៉ុន្មាននាក់ទេ មានលោកតាទូ សាមុត, មានសាឡុត ស, មានម៉ី ម៉ាន់, មានខ្ញុំបាទ នួន ជា នេះឯង គិតគ្នាថា បក្សយើងក្នុងឆ្នាំ១៩៦២ នេះន៎ែ ត្រូវផ្តាច់ខ្លួនឲ្យផុតពីបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលវៀតណាមគ្រប់គ្រង។ អានេះបើនិយាយពីបក្សនោះវាវែងណាស់ ពីដើមមក ប៉ុន្តែខ្លាចខាតពេល។

ពីដើម ជាបក្សកុម្មុយនីស្តឥណ្ឌូចិន មានវៀតណាម លាវ ខ្មែរ។ ឯវៀតណាមនេះ គេធ្វើជាមេ បើនិយាយឲ្យចំមេ។ មកក្រោយទៀត បានចែកបក្សនេះជាបី ដល់ចែកបក្សនេះជាបី គឺមានបក្សកុម្មុយនីស្តឥណ្ឌូចិនវៀតណាម ដែលហៅថា "បក្សឡៅដុង" បក្សកុម្មុយនីស្តកម្ពុជា ហៅថា "បក្សប្រជាជនបដិវត្តន៍កម្ពុជា" បក្សលាវ ហៅថា "បក្សបដិវត្តន៍ឡាវ"។ ដូច្នោះវាអស់ វាអស់ ប៉ុន្តែធាតុពិតនៅតែវៀតណាមគ្រប់គ្រងដដែល។ នេះខ្ញុំសូមជម្រាបអ៊ីចឹង។

[១០:០២:៤៦]

ឥឡូវខ្ញុំ សូមជម្រាបអ៊ីចេះទៀត លោកតាទូ សាមុត, សាឡុត ស ហៅថា ប៉ុល ពត ខ្ញុំ ហើយកាលនោះមាន ម៉ី ម៉ាន់ ដែរ ប៉ុន្តែឥឡូវគាត់ខូចទៅហើយ ពិគ្រោះគ្នាថា យើងចង់រំដោះខ្លួនឲ្យផុតអំពីអំណាចគ្រប់គ្រងរបស់វៀតណាម។ វៀតណាមកាលនោះ កាលនោះវៀតណាមគេគ្រប់គ្រង គេចាត់ចែង អ្វីៗទាំងអស់សារាចរណ៍អីៗណែនាំទាំងអស់មកពីហាណូយ មកពីភាគខាងជើង។ ដល់អ៊ីចឹង បានគិតគ្នារៀបចំចែកភារកិច្ច។ លោកតាជាចាស់ព្រឹទ្ធាចារ្យ ប៉ុន្តែនៅមិនទាន់មានទទួលនាទីជាអ្វីនៅ ឡើយទេ ពីព្រោះខ្ញុំមកមិនទាន់ទេ ពីព្រោះខ្ញុំចូលបដិវត្តន៍ឆ្នាំ៥១ ហើយ។ ដល់ដូច្នោះ បានចាត់ចែងថា លោកតាធ្វើប្រធាន ខ្ញុំទទួលខាងមើលការខុសត្រូវក្តាប់សភាពការណ៍នៅជនបទ ឯប៉ុល ពត, ម៉ី ម៉ាន់

ក្តាប់សភាពការណ៍នៅទីក្រុង ដើម្បីរៀបចំមាគ៌ានយោបាយជាយុទ្ធសាស្ត្រ មាគ៌ានយោយជាយុទ្ធវិធី ដូចជាខ្ញុំបានជម្រាបពីលើកមុនមកហើយ។ ដល់ទៅពិចារណាទៅឃើញថា នៅជនបទការជិះជាន់ធ្ងន់ណាស់។ ស្រូវ១០០ថាំងខ្ចី យកការ៣០ថាំង។

**ប្រធានអង្គជំនុំ៖**

អាហ្នឹងដូចជាលោកបាន-- លោក នួន ជា លោកបាននិយាយរួចហើយ អំពីបញ្ហាហ្នឹង។ សំណួររបស់សហព្រះរាជអាជ្ញា ទំនងជាមិនតម្រូវឲ្យលោក នួន ជា ឆ្លើយនូវចម្លើយបកក្រោយអ៊ីចឹងទេ បញ្ហាគឺចង់ដឹងអំពីសមាសភាពនៃគណៈមជ្ឈិមបក្សដែលឆ្លងកាត់មហាសមាជនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០។ តើមហាសមាជនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ហ្នឹង មានសមាសភាពប៉ុន្មាននាក់ចូលរួម? ហើយប៉ុន្មាននាក់ដែលត្រូវគណៈមជ្ឈិម សម្រេចយកជាចាត់តាំងជាអ្នកដឹកនាំបក្សសម័យនោះ ហើយអ្នកណាខ្លះ?

[១០:០៦:៤០]

**លោក នួន ជា៖**

**ឆ៖** បើមានប្រសាសន៍ឲ្យខ្លីអ៊ីចឹង ខ្ញុំតាម។ ខ្ញុំគោរពលោកប្រធាន។ ចំនួនឈ្មោះ ខ្ញុំមិនចាំទេ។ ក៏ប៉ុន្តែមជ្ឈិមបក្សមាន ១) លោកតា ទូ សមុត ជាលេខាបក្ស។ ៣) នួន ជា ជាអនុលេខាបក្សទទួលភារកិច្ចខាងអប់រំ ហើយនិងទាក់ទងជាមួយបក្សវៀតណាម។ ៣) សាឡុត ស ទទួលខាងបញ្ញាជនបក្សដែលជាពួកបញ្ញាជននោះ។ ឯ ម៉ៃ ម៉ាន់ កាលនោះគាត់ក៏ ជម្រាបទៅ ខ្ញុំដូចជាថាយកផ្ទៃក្នុងបក្សខ្លួនឯងមកបកទៅចុះ គាត់ឈប់ពីព្រោះគាត់មានគ្រួសារទៅគាត់ពិបាក។ ដូច្នោះនៅសល់តែបីនាក់ហ្នឹង ឯក្រៅពីនេះ អ្នកបីនាក់នេះធ្វើការតទៅទៀត មានតែបីនាក់ ហើយបានពង្រីកបីនាក់នេះទៅទាក់ទងជាមួយកម្មាភិបាលចាស់ ដូចជាខ្ញុំជម្រាបមកទៀតហើយមកពីមុនហើយ។ ដូច្នោះខ្ញុំមិនបាច់ជម្រាបទៀតទេ ទាក់ទងបានកម្មាភិបាលខាងបូព៌ា ទាក់ទងកម្មាភិបាលខាងនិរតី ទាក់ទងកម្មាភិបាលខាងពាយ័ព្យ ទាក់ទងខាងកម្មាភិបាលខាងនែ៏ឧត្តរអីៗអស់នេះ។ និយាយអ៊ីចឹង ខ្ញុំមិននិយាយទៀតទេ ព្រោះនិយាយរួចមកហើយ។

[១០:០៨:៤៣]

**ប្រធានអង្គជំនុំ៖**

អរគុណ។ លោកសហព្រះរាជអាជ្ញា សូមបន្តសំណួរទៀត ហើយដើម្បីឲ្យពន្លឿននូវកិច្ចពិភាក្សា

ដេញដោលភស្តុតាងដែលនៅច្រើនណាស់ បើធៀបជាមួយនឹងអង្គហេតុដែលយើងបានសម្រេចចោទប្រកាន់ចំពោះជនជាប់ចោទ ហើយត្រូវធ្វើសវនាការដេញដោល។ ដូច្នេះសូមព្រះរាជអាជ្ញាកំណត់នូវការសួរឲ្យខ្លី អង្កន់នូវសំណួរឲ្យខ្លីឲ្យច្បាស់ដើម្បីងាយក្នុងការស្ដាប់ ហើយឆ្លើយ។ ទីពីរ កត់សម្គាល់ឃើញផងដែរថា ការបកប្រែភាសាសូមប្រយ័ត្នប្រយែងក្នុងការបកប្រែភាសា ឲ្យកាន់តែច្បាស់ថែមទៀតនូវសំណួរដែលសួរ កាលបើបកប្រែភាសាហ្នឹងមិនច្បាស់លាស់នូវសំណួរ ដែលសួរទេវាអាចធ្វើឲ្យសំណួរដែលតម្រូវឲ្យឆ្លើយជាក់លាក់នោះ បែរជាទៅធ្វើអត្ថាធិប្បាយវិញ វាអាចធ្វើការឃ្លាតឆ្ងាយពីតម្រូវការនៃការសំណួរ។ ដូច្នេះវានឹងអាចពង្រីកនៃការពេលវេលាក្នុងការដេញដោលនេះ វែងអន្លាយមិនខានទេ។

សូមអញ្ជើញសហព្រះរាជអាជ្ញាបន្តការសួរ!

[១០:១០:១០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក អៀង សារី ត្រូវបានតែងតាំងជាសមាជិកត្រៀម ហើយនិងសមាជិកពេញសិទ្ធិនៅក្នុងសន្និបាតឆ្នាំ១៩៦០ ដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន! ខ្ញុំសូមឆ្លើយ។ លោក អៀង សារី ជាគណៈអចិន្ត្រៃយ៍។ ខ្ញុំនឹកឃើញហើយ សុន សេន ជាគណៈអចិន្ត្រៃយ៍ដែរ។ ឯក្រៅពីនេះតាមភាគមាន សោ ភឹម មាន តាម៉ុក ដែលរួមមកជាមជ្ឈិម។ សូមចប់។

**ស៖** តើ សោ ភឹម ហើយនិង តាម៉ុក ត្រូវបានតែងតាំងជាគណៈអចិន្ត្រៃយ៍នៅក្នុងឆ្នាំ១៩៦០ នោះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន! សោ ភឹម ត្រូវចាត់តាំងមុន តាម៉ុក ចាត់តាំងក្រោយទេ។ តាម៉ុក ចាត់តាំងក្នុងឆ្នាំ១៩៦៣។

**ស៖** តើលោកនៅចាំទេ ថាមានអ្នកណាដែលទទួលការតែងតាំងទៅគណៈមជ្ឈិមនៅក្នុងឆ្នាំ ១៩៦០ នោះ? ខ្ញុំជូនឈ្មោះមួយពីរ ដើម្បីឲ្យលោកនឹកឃើញឡើងវិញ ដូចជា កែវ មាស។ តើ កែវ មាស នេះត្រូវបានចាត់តាំងនៅក្នុងសន្និសីទឆ្នាំ១៩៦០ ហ្នឹងដែរឬទេ ជាគណៈមជ្ឈិមនោះ?

**ឆ៖** សូមជម្រាបលោកប្រធាន! ដំបូងឡើយ កែវ មាស នៅក្នុងគណៈមជ្ឈិមដែរ ប៉ុន្តែក្រោយ

មកគណៈពិនិត្យឃើញថា កែវ មាស ចេញចំហ នៅក្នុងក្រុមប្រជាជន។ ដូច្នោះ មកធ្វើការសម្ងាត់ជាមួយបក្សមិនបានទេ។ ដូច្នោះឲ្យឈប់។

[១០:១៣:២៧]

**ស៖** ថាតើបក្សបានបញ្ឈប់គាត់ចេញពីគណៈមជ្ឈិមនៅពេលណាដែរ?

**ឆ៖** ខ្ញុំមិនចាំថ្ងៃខែទេ ប៉ុន្តែពេលក្រោយប្រហែលជាមួយឆ្នាំ។

**ស៖** តើ វន វេត ត្រូវបានចាត់តាំងឲ្យធ្វើជាសមាជិកគណៈមជ្ឈិមនៅឆ្នាំ១៩៦០ នោះដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ មាន វន វេត ដែរ ក្នុងឆ្នាំ១៩៦០។

**ស៖** ចុះកម្មាភិបាលមកពីកោះកុង ឈ្មោះថា សាត ឈ្មោះ ចុង តើគាត់វត្តមាន ហើយត្រូវបានចាត់តាំងឲ្យធ្វើជាសមាជិកគណៈមជ្ឈិមទេ នៅឆ្នាំ១៩៦០នោះ?

[១០:១៤:៥១]

**ឆ៖** សូមជម្រាបលោកប្រធាន។ អ្នកអស់នេះជាគណៈកម្មាធិការភាគ មិនទាន់ចូលមជ្ឈិមទេ។

**ស៖** ដើម្បីជួយឲ្យលោកនឹកចងចាំនោះ ខ្ញុំនឹងលើកឈ្មោះមួយចំនួនឲ្យលោក នួន ជា បានដឹង។ ឥឡូវនេះខ្ញុំចង់បង្ហាញរូបថតជូនលោកនៅក្នុងសំណុំរឿងឯកសារ D313/1.2.237 ហើយ ERN លេខ P00416593 លោកប្រធានសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ ដើម្បីភាគីនិងជនជាប់ចោទលោកបានមើល។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

[១០:១៦:៣៥]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមលោក អៀង សារី មានបញ្ហាសុខភាព គាត់សូមអនុញ្ញាតជួបពិគ្រោះជាមួយវេជ្ជបណ្ឌិតប្រចាំទីនេះជាបន្ទាន់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អនុរក្សមន្ទីរឃុំឃាំងនាំគាត់ទៅបន្ទប់ពិនិត្យ។

*(ជនជាប់ចោទ អៀង សារី ចាកចេញពីបន្ទប់សវនាការ)*

[១០:១៨:១៨]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអនុញ្ញាតនិយាយម្តងទៀត។

**លោក នួន ជា៖**

**ជ៖** ដូចជា កុយ ធួន ខ្ញុំមើលច្បាស់។ ណៃ សារ៉ាន់ ខ្ញុំមើលច្បាស់។ ហើយក្រៅពីនេះ អំ ហើយ និងមួយទៀត គេប្រែឈ្មោះថ្មី ខ្ញុំមើលមិនច្បាស់ទេ។

**ស៖** លោក នួន ជា យើងពិនិត្យមើលរូបថតនេះចាប់ពីជួរខាងក្រោយ ខាងលើ គឺនៅខាងចុងស្តាំបំផុត សាឡុត ស (ប៉ុល ពត) តើមែនឬទេ?

**ជ៖** ខាងស្តាំបំផុត អង្គុយកៅអីៗ? គោរពលោកប្រធាន ខ្ញុំសូមសួរ។ នៅឈរ--

**ស៖** បាទ ខ្ញុំសួរអ្នកដែលរូបដែលឈរនៅខាងចុងស្តាំបំផុតនៅខាងក្រោយ តើ ប៉ុល ពត មែនឬទេ?

[១០:១៩:៤៧]

**ជ៖** ដូចមិនមែនទេ គោរពលោកប្រធាន។

**ស៖** តើលោកនៅស្គាល់រូបលោកនៅក្នុងរូបថតនេះដែរឬទេ?

**ជ៖** សូមគោរពលោកប្រធាន រូបខ្ញុំ ខ្ញុំមិនស្គាល់។

**ស៖** លោក នួន ជា ជាថ្មីម្តងទៀត នៅជួរខាងក្រោយរូបម្នាក់ដែលជាមនុស្សទីបួន បន្ទាប់ពី កុយ ធួន តើជារូបរបស់លោកទេ រាប់ពីឆ្វេងមកទីបួន បន្ទាប់ពី កុយ ធួន?

**ជ៖** រាប់ពីឆ្វេង។ រូបនេះ សូមគោរពលោកប្រធាន ដូចមិនមែនរូបខ្ញុំទេ ប៉ុន្តែមានម្នាក់ប្រហាក់ប្រហែលរូប ដែលមានរូបរាងដូចខ្ញុំ ជាសាស្ត្រាចារ្យ។

**ស៖** ឥឡូវនេះលោកបញ្ជាក់ថា លោកស្គាល់ លោក កុយ ធួន នៅក្នុងរូបថតនេះ។ តើមែនទេ? រីឯរូបម្នាក់ អ្នកដែលឈរទីបីរាប់ពីឆ្វេងដៃមក គឺរូប កុយ ធួន តើមែនឬទេ?

**ជ៖** សូមជម្រាបលោកប្រធាន! មែន។

**ស៖** ចំពោះរូបមួយដែលឈរនៅរូបទីពីរ រាប់ពីឆ្វេងមក តើរូបហ្នឹងរូប តាម៉ុក ឬ?

**ជ៖** សូមគោរពលោកប្រធាន កាលនោះគាត់នៅក្មេង ខ្ញុំមិនចាំដែរ។

**ស៖** ខ្ញុំសួរអ្នកផ្សេងទៀត អ្នកដែលឈរទីបីរាប់ពីខាងស្តាំ តើអ្នកពាក់វ៉ែនតាហ្នឹង តើរូបហ្នឹង សុន សេន ឬក៏អ្នកណា?

**ឆ៖** សូមគោរពលោកប្រធាន រូបនេះដូចជាមិនមែន សុន សេន ទេ។

**ស៖** តើលោកបានឃើញលោក សោ ភឹម ទេ នៅក្នុងរូបថតនេះ? តើគាត់ជាមនុស្សម្នាក់ ដែលជាអ្នកអង្គុយនៅកណ្ដាលគេក្នុងរូបថតនេះឬទេ?

**ឆ៖** សូមគោរពលោកប្រធាន ដូចមិនឃើញ។

**ស៖** តើលោកនៅចាំទីកន្លែងដែលគេថតរូបនេះដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

[១០:២៤:០៧]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបង្ហាញរូបថតមួយទៀត ដែលគេថតនៅកន្លែងមួយ ដែលនៅខាងក្រោយនោះមានអាគារមានទីតាំងដែលអាចឲ្យលោកនឹកឃើញ។ ខ្ញុំសូមអនុញ្ញាតឲ្យតុលាការបង្ហាញរូបថត D313/ ERN P00146592 បាទ។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត។ សូមអញ្ជើញ!

[១០:២៥:៣០]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា តើលោកស្គាល់ទីតាំងនៃរូបថតនេះទេ? ជាពិសេសតើនេះជាមន្ទីរមួយរបស់បក្សនៅក្នុងស្ទឹងជីនិតដែរឬទេ? នៅដើមទសវត្សរ៍ឆ្នាំ៧០ នោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** ខ្ញុំសូមសួរលោកអំពីរូបភាពដែលគេដាក់តាំងនៅលើវេទិកានៅក្នុងរូបថតនេះដែរ។ តើត្រូវដែរឬទេ មនុស្សពីរនាក់នៅក្នុងរូបបង្ហាញហ្នឹងនៅខាងឆ្វេងដៃហ្នឹង តើម៉ាក ហើយនិងអ៊ីងហ្គែរ ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំស្គាល់ ព្រោះគាត់មានពុកមាត់ជាសញ្ញា។

**ស៖** ហើយរូបទាំងពីរនេះនៅក្នុងរូបថតនេះ នៅខាងស្ដាំដៃនៃរូបភាពនៅខាងវេទិកានេះ តើឡេនីន និង ស្តាលីន ដែរឬទេ? តើត្រូវទេរូបហ្នឹងបាទ?

[១០:២៧:១២]

**ឆ៖** សូមជម្រាបលោកប្រធាន ក្នុងទីនេះដូចមិនឃើញមាន។

**ស៖** តើលោកមិនបានឃើញរូបថតនៅខាងស្តាំបាទ ខាងស្តាំនៃរូបថត។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមិនឃើញរូបថតហ្នឹងទាំងស្រុងនៅលើអេក្រង់ទេលោកប្រធាន។

**លោក នួន ជា៖**

**ឆ៖** អ៊ំរ!បើខាងនេះឃើញ ស្តាលីន។ សូមគោរពលោកប្រធាន ខាងស្តាំដៃម្នាក់ទៀតនរណាទេ ខ្ញុំមិនមើលមិនច្បាស់ទេ។ ប៉ុន្តែបើ ស្តាលីន ខ្ញុំចំណាំពុកមាត់។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើលោកអាចជម្រាបប្រាប់យើងទេ ហេតុអីបានជាដាក់តាំងរូបថតមានម៉ាកហេហ្គិន ឡេនីន និងស្តាលីន នៅក្នុងវេទិការបស់ផ្លូវការរបស់បក្សបែបនេះ?

**លោក នួន ជា៖**

**ឆ៖** សូមគោរពលោកប្រធាន នេះជាប្រពៃណីរបស់បក្សកុម្មុយនីស្តទូទៅទូទាំងសកលលោក។

**ស៖** ថាតើ ស្តាលីន ហើយនិង ឡេនីន ចាត់ទុកថាជាតួអង្គគំរូនៃបដិវត្តន៍របស់លោកដែរឬទេ?

**ឆ៖** សូមគោរពលោកប្រធាន ការរៀនសូត្រតាមលទ្ធិម៉ាក-ឡេនីន ប៉ុន្តែការប្រតិបត្តិទៅតាមសភាពការណ៍ជាក់ស្តែងនៃប្រទេសកម្ពុជា មិនមែនយកតាមទ្រឹស្តីម៉ាក-ឡេនីន ទាំងដុលយកមកអនុវត្តទេ។

[១០:២៩:៣០]

**ស៖** តើត្រូវទេ អ្នកដែលឈរ ដែលនិយាយនៅលើវេទិកានៅក្នុងរូបថតនេះ តើជារូបរបស់ ប៉ុល ពត ឬ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំសម្លឹងយូរហើយ ប៉ុន្តែដូចអង្គាល់នោះគាត់នៅក្មេង ខ្ញុំចាំមិនបានដែរ។

**ស៖** តើលោកនៅនឹកឃើញរូបខ្លួនឯងដែលអង្គុយនៅលើវេទិកានៅខាងស្តាំដៃ នៅខាងស្តាំដៃ ប៉ុល ពត ទេនៅក្នុងរូបថតនេះ? គឺរូបនៅខាងស្តាំដៃនៃរូបថតនេះ។

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំ ព្រោះវាយូរឆ្នាំមកហើយ។

**ស៖** សំណួរមួយចុងក្រោយ យើងមើលរូបថតនេះ តើលោកស្គាល់ថាតើជាកិច្ចប្រជុំ ឬក៏ជាមហាសន្និបាតបក្ស ឬក៏ជាកិច្ចប្រជុំរបស់គណៈមជ្ឈិម?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ។

**ស៖** លោកបានបញ្ជាក់ថា សោ ភឹម ត្រូវបានតែងតាំងឲ្យធ្វើជាគណៈអចិន្ត្រៃយ៍ឆ្នាំ១៩៦០ ថា តើលោកបានជួបលោក សោម ភឹម ដំបូងនោះនៅពេលណា?

**ឆ៖** សូមជម្រាបលោកប្រធាន។ ខ្ញុំជួប សោ ភឹម ដំបូងនៅបូព៌ា។

**ស៖** តើលោកចាំទេ ជួបនៅពេលណាក្នុងឆ្នាំខែណាដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនចាំទេ ព្រោះយូរណាស់ហើយ ជិតកន្លះសទវត្សរ៍ទៅហើយ។

**ស៖** តើលោក និងសោ ភឹម បានទទួលវគ្គសិក្សានយោបាយជាមួយគ្នាទេ នៅក្នុងវៀតណាម គឺឆ្នាំ១៩៥៣ ឬក៏៥៤?

**ឆ៖** សូមជម្រាបលោកប្រធាន។ មិនដែរទេ។

[១០:៣២:៥៥]

**ស៖** ថាតើលោកជាអ្នកជ្រើសតាំង សោ ភឹម ដើម្បីឲ្យកសាងបក្សនៅក្នុងភូមិភាគបូព៌ា ដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន មិនមែនខ្ញុំចាត់តាំង សោ ភឹម ទេ គឺគណៈមជ្ឈិមចាត់តាំង។

**ស៖** តើលោកបានជ្រើសតាំងគាត់ឲ្យចូលបក្ស ហើយក្រោយមកបានចូលទៅគណៈមជ្ឈិម។ តើបែបហ្នឹងឬទេ លោក នួន ជា?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនបានចាត់តាំង សោ ភឹម ចូលបក្សទេ។ ហើយមិនបានចាត់តាំងគាត់ចូលមជ្ឈិម ព្រោះគាត់ជាអ្នកតស៊ូចាស់យូរហើយ មុនខ្ញុំទៅទៀត។

[១០:៣៤:០១]

**ស៖** តើលោកអាចរៀបរាប់ជូនតុលាការបានទេ អំពីទំនាក់ទំនងរវាងលោក និងលោក សោ ភឹម នោះណា?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំអាចជម្រាបបានដោយអន្លើៗ។ ន៎ែ!ក្រោយ នេះសូមថយក្រោយបន្តិចបើលោកប្រធានអនុញ្ញាត។ ក្រោយកិច្ចព្រមព្រៀងហ្សឺណែវ សោ ភឹម នេះ ឬក៏អ្នកដឹកនាំសំខាន់ៗត្រូវសត្រូវរក។ សោ ភឹម នេះមកធ្វើជាង ជាងឈើ ជាងឈើផ្ទះនៅភ្នំពេញ។ ដូច្នោះ រកស្ទាក់ទាក់ទងជាមួយប៉ុល ពត ទេ មិនមែនជាមួយខ្ញុំទេដំបូងឡើយ។

**លោក អាង ឧត្តម៖**

សូម--

**ប្រធានអង្គជំនុំ៖**

អញ្ជើញៗ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន បន្ទាប់ពីលោកវេជ្ជបណ្ឌិតបានពិនិត្យសុខភាពលោក អៀង សារី ហើយ លោក អៀង សារី ស្នើសុំអនុញ្ញាត លោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់ ដោយសារគាត់មិនអាចទ្រាំទ្រអង្គុយទីនេះបន្តទៀត សូមអនុញ្ញាតឲ្យគាត់ចូលរួមសវនាការនៅបន្ទប់រង់ចាំខាងក្រោម សម្រាប់ពេលព្រឹកនេះ។ សូមអរគុណ និងចាប់ពីពេលនេះតទៅ សូមអរគុណ។

[១០:៣៦:១២]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតតាមការស្នើសុំរបស់លោកជនជាប់ចោទតាមរយៈមេធាវី ដែលលះបង់សិទ្ធិមិនចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ ដោយទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួន ស្ថិតនៅក្រោមបន្ទប់សវនាការតាមរយៈឧបករណ៍សោតទស្សន៍។ ប៉ុន្តែក្រុមមេធាវីការពារក្តីជនជាប់ចោទត្រូវប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមៗនូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយមានការចុះហត្ថលេខា ឬផ្តិតមេដៃច្បាស់លាស់ពីជនជាប់ចោទ អៀង សារី។

[១០:៣៦:៤៨]

ហើយបន្ទាប់ពីគ្រូពេទ្យពិនិត្យរួច អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់ខាងក្រោម ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍ សម្រាប់ជនជាប់ចោទចូលរួមតាមដានសវនាការពីចម្ងាយ ហើយនិងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់សោតទស្សន៍ សម្រាប់ជនជាប់ចោទអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយបាន។

សូមបន្តៗ សូមអញ្ជើញត!

**លោក នួន ជា៖**

*(ឮមិនច្បាស់)*

[១០:៣៧:២៥]

**ប្រធានអង្គជំនុំ៖**

អាចបន្តបានទេ?

បាទ, ឥឡូវគឺដល់ម៉ោងសមល្មមនឹងសម្រាកផងដែរ។ អ៊ីចឹងអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់មួយ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការពិភាក្សាដេញដោលតទៅទៀត។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៨ នាទី ដល់ម៉ោង ១១:០៣ នាទី)*

[១១:០៣:១១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ! អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការពិភាក្សាដេញដោល។

ជាបន្ត សូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរចំពោះជនជាប់ចោទ នួន ជា។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា យើងបានពិភាក្សាគ្នាអំពីការប្រជុំលើកទី១ របស់បក្សកុម្មុយនីស្តកម្ពុជានៅឆ្នាំ៦០ តើលោកចាំទេថាតើអ្នកចូលរួមក្នុងសន្និបាតហ្នឹងមានសមាជិកប៉ុន្មាននាក់ដែរតំណាងមកពីខាងណានៅក្នុងពេលនោះបាទ?

**លោក នួន ជា៖**

**ឆ៖** សូមជម្រាបលោកប្រធាន។ ពេលនោះឆ្នាំ១៩៦០ វានៅក្នុងសភាពការណ៍សម្ងាត់ ដូច្នោះការប្រជុំនេះជ្រើសរើសយកតែប្រធានភាគមកប្រជុំ តាមខ្ញុំចាំចំនួនប្រហែលជា៦-៧នាក់ ដែលគេជា

តំណាងឲ្យភាគរបស់គេ។

**ស៖** ពីមុនលោក នួន ជា នៅពេលដែលលោកបានពិភាក្សាជាមួយ ខឹម នន់ លោកបានបញ្ជាក់ថា មានមនុស្សតំណាង១០ ឬក៏១៥នាក់ ដែលបានចូលរួម។ ហើយខ្ញុំក៏បានកត់សម្គាល់ដែរថា នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៧ នៅក្នុងទង់បដិវត្តនោះក៏មានសេចក្តីថ្លែងការណ៍មួយ ដែលដកស្រង់ថា គឺមានតំណាង១៤នាក់ ដែលជាតំណាងឲ្យជនបទ ៧នាក់តំណាងឲ្យទីក្រុង ហើយទាំងអស់គ្នា១៤ D243/2.1.12 អង់គ្លេស ERN 000486226 ភាសាបារាំង ERN 00492811 ហើយខ្មែរ ERN 0006365 រហូតទៅដល់ 616។ តើតាមការចងចាំរបស់លោក ថាតើតំណាងទាំងអស់នុ៎ង គឺប្រហែលជា២០នាក់ទេ ដែលចូលរួមនៅក្នុងសន្និបាតលើកទីមួយនោះ?

[១១:០៦:៥១]

**ឆ៖** សូមជម្រាបលោកប្រធាន ថាខ្ញុំមិនចងចាំទេ ព្រោះវាយូរឆ្នាំណាស់មកហើយ។

**ស៖** នៅក្នុងករណីណាក្តីលោកបានឯកភាព លោកបានយល់ថា គឺមានតំណាងមួយចំនួនតូចដែលត្រូវបានគេកោះហៅឲ្យមកចូលរួមប្រជុំក្នុងសន្និបាតនោះ។ តើត្រឹមត្រូវឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំមិនយល់សំណួរ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាតាំងសំណួរអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ឲ្យច្បាស់លាស់។

[១១:០៧:៤៩]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើត្រូវដែរឬទេ? គឺមានអ្នកដែលចូលរួមហ្នឹង គឺមានចំនួនតិច ដែលគេកោះហៅមកចូលរួម គឺប្រហែលជា៧ ឬក៏១០ជាងប៉ុណ្ណឹង។ តើអាចត្រឹមត្រូវទេ ចំនួនហ្នឹង?

**លោក នួន ជា៖**

**ឆ៖** ខ្ញុំសូមសួរវិញ ប្រជុំអី? សន្និបាតអី? គោរពលោកប្រធាន ខ្ញុំសូមសួរ បញ្ជាក់ឲ្យច្បាស់។ ប្រជុំ ឬសន្និបាត?

**ស៖** លោក នួន ជា យើងនិយាយអំពីសន្និបាត ដែលរៀបចំឡើងនៅខែកញ្ញា ឆ្នាំ១៩៦០។

**ឆ៖** សូមជម្រាបលោកប្រធាន។ បើនិយាយពីសន្និបាត ឆ្នាំ១៩៦០ ចំនួនប្រហែល៦-៧ នាក់ប៉ុណ្ណឹង។

[១១:០៩:២១]

**ស៖** ថាតើសន្និបាតនោះរៀបចំនៅកន្លែងណាដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន។ សន្និបាតនោះរៀបចំនៅវ៉ារទេះភ្លើង នៅផ្ទះនែ ខ្ញុំភ្លេចឈ្មោះហើយ ឥឡូវគាត់ខូចទៅហើយ។

**ស៖** តើនៅផ្ទះ អ៊ុក សុគន្ធ នោះឬទេ?

**ឆ៖** បាទ, ត្រូវហើយ។

**ស៖** តើ អ៊ុក សុគន្ធ ដែលក្រោយមក គាត់បានក្លាយទៅជាតំណាងកម្ពុជាប្រជាធិបតេយ្យនៅយូណេស្កូ នៅប៉ារីស តើមែនឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន! ខ្ញុំក្តាប់មិនបានទេ។

**ស៖** ថាតើគាត់ជា អ៊ុក សុគន្ធ ដដែល ដែល ខៀវ សំផន បានលើកឡើងនៅក្នុងមតិយោបល់គាត់នៅខែមុខថាជាមនុស្សដែលបញ្ចុះបញ្ចូលឲ្យលោក ខៀវ សំផន ចូលរួមក្នុងក្រុមមួយ ម៉ាគី នៅប៉ារីស តើមែនទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ខ្ញុំក្តាប់មិនបានទេ ខ្ញុំមិនចាំទេ។

[១១:១១:១៥]

**ស៖** ថាតើសន្និបាតនោះប្រព្រឹត្តទៅរយៈពេលប៉ុន្មានដែរ? យូរប៉ុនណាដែរ?

**ឆ៖** សូមជម្រាបលោកប្រធាន សន្និបាតនោះប្រហែលបីថ្ងៃ។

**ស៖** តើត្រឹមត្រូវទេ ថាតំណាងទាំងអស់នោះ បានមកស្នាក់នៅ ហើយសម្រាកនៅផ្ទះលោក អ៊ុក សុគន្ធ ហ្នឹងទាំងបីយប់ទាំងបីថ្ងៃរហូតដែរឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ត្រូវហើយ។

**ស៖** លោកបានប្រាប់យើងអំពីមនុស្សមួយចំនួនដែលលោកបានចង្អុលថា អ្នកដែលចូលរួម ថាតើវិធីដែលជ្រើសតាំងឲ្យចូលទៅក្នុង ចូលរួមនៅក្នុងមហាសន្និបាតហ្នឹង គឺថាយើងជ្រើសរើសរបៀបម៉េច? គេបោះឆ្នោតជ្រើសរើសឲ្យចូលក្នុងគណៈហ្នឹង ឬក៏គេតែងតាំងរបៀបម៉េច?

**ឆ៖** សូមជម្រាបលោកប្រធាន តាមខ្ញុំចាំគឺខាងភូមិភាគគេ ៗជ្រើសរើសមក ឲ្យមកប្រជុំ មកសន្និបាត រួចទៅសន្និបាតជ្រើសរើសថែមទៀត។

[១១:១៣:១១]

**ស៖** តើរបៀបក្នុងការចាត់តាំងដូចជាដំណើរការសមូហភាវូបនីយកម្ម ដូចដែលលោកបានរៀបចំពី-- រៀបរាប់ពីកាលពីខែមុននោះឬទេ?

**ឆ៖** សូមជម្រាបលោកប្រធាន ការរៀបចំចាត់តាំងជាសមូហភាព ទាល់តែសមូហភាពយល់ស្រប។

**ស៖** ខ្ញុំចូល សូមចូលទៅដល់សំណួរមួយអំពីមាគ៌ាបក្សដែលបានអនុម័តនៅក្នុងមហាសន្និបាតលើកទីមួយនោះ។ នៅក្នុងសេចក្តីថ្លែងបើកនោះ គឺលោកបានបញ្ជាក់ថាបញ្ហាដែលសម្រេចពិភាក្សានៅក្នុងសន្និបាតនោះ គឺការវិភាគនៃធាតុពិតនៃសង្គមកម្ពុជា ហើយនិងវិធីលុបបំបាត់ពួកសក្តិភូមិ។ នៅក្នុងចំណុចនេះ ខ្ញុំចង់បង្ហាញលោក សេចក្តីថ្លែងការណ៍មួយចុះថ្ងៃ ចុះខែកញ្ញា ឆ្នាំ១៩៧៧ ដែលបញ្ជាក់អំពីការវិភាគអំពីសង្គមកម្ពុជានៅក្នុងដែលលើកឡើងក្នុងឆ្នាំ១៩៦០។ លោក លោកស្រីចៅក្រម ខ្ញុំសូមអនុញ្ញាតដាក់បង្ហាញនៅលើអេក្រង់ ឯកសារ D243/2.1.12 អង់គ្លេស ERN1229 បារាំង ERN498, ERN6139។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ!

**លោក នួន ជា៖**

មើលមិនឃើញទេ សូមជម្រាប គោរពលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

គេមិនទាន់ដាក់ទេអ៊ំ។ លោក នួន ជា គេមិនទាន់ដាក់ទេ ចាំបន្តិចទៀត។ ចាំឲ្យរៀបរយ មន្ត្រីច្បាប់ទៅ មន្ត្រីតុលាការទៅសម្របសម្រួលដើម្បីឲ្យ-- ទៅមើលកុំព្យូទ័រគាត់ផង។

[១១:១៦:៤៨]

**សួរដោយលោក ឌេល លីសាក់៖**

លោក នួន ជា នៅក្នុងសេចក្តីដកស្រង់ចេញពីទស្សនាវដ្តីទង់បដិវត្ត ខ្ញុំនឹងអានជូនលោក ហើយសួរលោកអំពីចំណុចទីមួយនៅក្នុងចំណុចលេខ១០ នេះ។ ជាសេចក្តីថ្លែងការណ៍មួយនៅក្នុងនោះ គឺថាប្រជាពលរដ្ឋ៨០ភាគរយ គឺស្ថិតនៅក្នុងម្ចាស់ដីខ្លាំងជាងគេ គឺស្អេកស្កះ ជាពិសេស និងសេចក្តីដកស្រង់ទីពីរដែលខ្ញុំនឹងបង្ហាញចេញអំពីទស្សនាវដ្តីទង់បដិវត្តឆ្នាំ៧៧ ដែរ។ គឺសេចក្តីដកស្រង់លេខ១១ នៅក្នុងទំព័រ ERN463 បារាំង-- ខ្មែរERN-- សេចក្តីដកស្រង់ដែលខ្ញុំចង់សួរលោកអំពីនោះ គឺនិយាយដូច

ខាងក្រោមនេះ៖

ការទំនាស់នេះគឺជាចំណុចស្លាប់រស់ គឺជាការទំនាស់ដ៏ជ្រៅក្នុងសង្គមកម្ពុជាដែលប៉ះពាល់ដល់ប្រជាជន ៨៥ភាគរយ ដោយហេតុនេះហើយ ដែលមហាសន្និបាតលើកទីមួយបានចាត់ទុកថា ជាទំនាស់ដ៏ធំធេងមួយនៅក្នុងសង្គម។

**ស៖** សំណួរដែលខ្ញុំសួរលោកនោះគឺ តើលោកអាចពន្យល់ជូនតុលាការបានទេថា តើមានន័យដូចម្ដេចពាក្យថា "ទំនាស់ស្លាប់រស់" ហើយនិង "ការខ្វែងគំនិតគ្នាស្លាប់រស់" នេះ តើមានន័យដូចម្ដេច?

**ឆ៖** សូមជម្រាបលោកប្រធាន ទាល់តែយកឯកសារដើមនោះឲ្យខ្ញុំមើលឲ្យច្បាស់។ លោកនិយាយសួរអ៊ីចឹង ខ្ញុំឆ្លើយម៉េចកើត? ពីព្រោះវាមិនច្បាស់។

[១១:១៩:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២០:០៨]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការទៅជិតនឹងលោក នួន ជា ហើយរៀបចំការបង្ហាញនូវចំណុចត្រង់អក្សរដែលមានគូសរង្វង់ពណ៌ក្រហមហ្នឹងជូនគាត់ ដើម្បីឲ្យគាត់មើល។ វាមានពីររង្វង់ វាពីរទំព័រខុសគ្នា មើលទំព័រទីមួយរួច សូមឆ្លងទៅទំព័រទីពីរ ទើបមើលយល់។

**លោក ខេល លីសាក់៖**

លោកប្រធាន ERN ភាសាខ្មែរនោះ ដែលគួរបង្ហាញនោះ គឺ 00063140។

**លោក នួន ជា៖**

**ឆ៖** ឲ្យខ្ញុំមើល ខ្ញុំទទួលមិនបានទេ ចាំទៅយកឯកសារដើម បានវាច្បាស់។ នេះឯកសារដើមថាមាននៅនេះ យកមកឲ្យខ្ញុំមើលមើល៍។ វាពិតជារបស់ខ្ញុំមែនទេ? បើក្រៅពីហ្នឹងខ្ញុំមិនទទួលទេ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៤:៣៤]

**លោក ខេល លីសាក់៖**

លោកប្រធានខ្ញុំគិតថា យើងស្ថិតនៅក្នុងថ្ងៃចុងក្រោយដែលយើងបានជូនឯកសារលើក្រដាសទៅគាត់នោះ មេធាវីរបស់គាត់អាចនឹងបញ្ជូនមកឲ្យគាត់មើល។ ខ្ញុំនឹងអាចសួរសំណួរទូទៅមួយទៀត

នៅពេលដែលយើងរង់ចាំឯកសារនៅលើក្រដាសនោះមកដល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១១:២៥:០៥]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណតុលាការ។ សំណួរដែលខ្ញុំសួរទៅលោក នួន ជា នោះគឺថានៅក្នុងឯកសារនេះ នៅក្នុងការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ការប្រើពាក្យថា "ទំនាស់បដិបក្ខ ក៏ទំនាស់ស្លាប់រស់នេះ" រៀបរាប់ពីទំនាក់ទំនងរវាងពលករ កសិករ នៅភាគីម្ខាងហើយម្ខាងទៀតជាសក្តិភូមិហើយនិងនាយទុនម្ចាស់ដី។ អ៊ីចឹងនៅក្នុងការបោះពុម្ពផ្សាយរបស់បក្សហ្នឹងគឺយើងឃើញមានប្រើពាក្យនេះ។ ក្រៅពីឯកសារជាក់លាក់នេះ តើលោកអាចពន្យល់តុលាការបានទេ ពាក្យថា "ទំនាស់បដិបក្ខ ឬក៏ទំនាស់ស្លាប់រស់" ដែលប្រើនៅទីនោះមានន័យដូចម្តេចបាទ?

[១១:២៦:០៤]

**ឆ៖** ជម្រាបលោកប្រធាន នេះជាការអធិប្បាយរបស់លោក ខ្ញុំទទូចហើយទទូចទៀតឲ្យយកឯកសារហ្នឹងមកឲ្យខ្ញុំមើលមើល៍! វាមែនទេ ជាឯកសាររបស់ខ្ញុំទេ ជាឯកសាររបស់បក្សកុម្មុយនីស្តកម្ពុជាទេ? អាហ្នឹងបានខ្ញុំទទួលបាន។ ប៉ុន្តែ បើលោកព្រះរាជអាជ្ញាអធិប្បាយតាមសម្តីរបស់លោកព្រះរាជអាជ្ញា មិនដឹងជាយកពាក្យសម្តីណាមកអធិប្បាយ។ មិនមែនខ្ញុំ មើលងាយមើលថោកអីទេ ខ្ញុំគោរពព្រះរាជអាជ្ញា ខ្ញុំគោរព ក៏ប៉ុន្តែអធិប្បាយវាមិនអស់សេចក្តី ព្រោះការសរសេរនោះវាផ្សេង ការអធិប្បាយវាផ្សេង ការនិយាយវាផ្សេង។ ខ្ញុំទទួលឯកសារកូពីនេះមិនបានទេ ទាល់តែយកឯកសារដើមមកបានខ្ញុំទទួលមើលឲ្យច្បាស់។ អានេះអក្សរតូចៗមួយ។

**ប្រធានអង្គជំនុំ៖**

ឥឡូវលោកកត់សម្គាល់លើខ្លឹមសារនៃសំណេរដែលបានបង្ហាញអម្បាញ់មិញហ្នឹង លោកមានយោបល់កត់សម្គាល់យ៉ាងដូចម្តេចចំពោះបញ្ហាហ្នឹង? សហព្រះរាជអាជ្ញាបានដាក់អម្បាញ់មិញ ហើយមាននៅក្នុងរង្វង់គូសក្រហម ចំណុចទាំងអស់ហ្នឹង តើលោកមានអត្ថាធិប្បាយ ឬក៏មានការកត់សម្គាល់យ៉ាងដូចម្តេចលើបញ្ហាហ្នឹង?

**លោក នួន ជា៖**

សូមជម្រាបលោកប្រធាន ឯកសារដើម ខ្ញុំទទូចហើយទទូចទៀតថា សូមយកឯកសារដើម មិនយកឯកសារកូពីទេ។ មិនដឹងជាកូពីខុស ឬត្រូវយ៉ាងម៉េចខ្ញុំមិនដឹងទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ លោកសហព្រះរាជអាជ្ញាបន្តសំណួរផ្សេងទៀត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោក នួន ជា តើលោកកំពុងតែបដិសេធថា បក្សនៅក្នុងការរៀបរាប់អំពីទំនាក់ទំនងរវាងកសិករ ហើយនិងសក្តិភូមិ ឬក៏ម្ចាស់ដី ដោយប្រើពាក្យថាទំនាស់បដិបក្ខ ឬក៏ទំនាស់សម្លាប់រស់។ តើលោកធ្លាប់បានឮសួរពាក្យពេចន៍នេះទេ ពីមុនមកហ្នឹង?

**ឆ៖** ខ្ញុំទទូចហើយ ទទូចទៀត លោកយកឯកសារណាមកនិយាយ? យកមកឲ្យខ្ញុំមើលមើល៍ ឬលោកនិយាយខ្លួនលោក។

**ស៖** លោក នួន ជា ខ្ញុំសួរលោកថា តើលោកដែលឮពាក្យថា "ទំនាស់បដិបក្ខ ឬក៏ទំនាស់ស្លាប់រស់" នេះដែរឬទេ? លោកធ្លាប់ឮពាក្យពេចន៍នេះដែរឬទេពីមុននោះ?

**ឆ៖** ដែលលោកសួរពីមុននោះ ពីអង្កាល់ណា?

**ស៖** តើលោកធ្លាប់ឮពាក្យនេះដែរឬទេ? ខ្ញុំគ្រាន់តែចង់បានថា តើធ្លាប់ ឬក៏មិនធ្លាប់?

[១១:៣១:៤៨]

**ឆ៖** ខ្ញុំធ្លាប់អានឯកសារផ្សេងខ្លះ ទំនាស់វាមានទំនាស់ផ្ទៃក្នុង វាមានទំនាស់បដិបក្ខ។ ទំនាស់បដិបក្ខហ្នឹង គឺទំនាស់រវាងខ្មាំង ហើយនិងម្ចាស់-- ពួកខ្មាំងឈ្លានពាន ហើយនិងប្រទេសដែលត្រូវឈ្លានពាន។ នេះហៅថា "ទំនាស់បដិបក្ខ" តាមខ្ញុំយល់។ ឯទំនាស់ផ្ទៃក្នុងនេះ គឺទំនាស់ក្នុងប្រជាជនពីរឿងបន្តិចបន្តួចទេ។

**ស៖** បើសិនជាខ្ញុំយល់ច្បាស់ចម្លើយរបស់លោកនោះ គឺថាលោកមានទំនាស់ពីរ គឺទំនាស់ផ្ទៃក្នុង និងទំនាស់បដិបក្ខ ឬក៏ទំនាស់ស្លាប់រស់នេះ តើត្រឹមត្រូវដែរឬទេលោក?

**ឆ៖** ឲ្យខ្ញុំថាត្រឹមត្រូវ ក៏ខ្ញុំថាមិនត្រឹមត្រូវ ថាត្រឹមត្រូវ មិនថាត្រឹមត្រូវ ពីព្រោះលោកអធិប្បាយមិនល្អិត។

[១១:៣៣:១៨]

**ស៖** លោកទើបតែរៀបរាប់អម្បាញ់មិញនេះ គឺថាលោកប្រើពាក្យថា ទំនាស់ផ្ទៃក្នុងដែលលោកយល់ឃើញថា វាជាទំនាស់តូចតាចទេ លោកទើបលើកឡើងអម្បាញ់មិញនេះ មែនទេ?

**ឆ៖** បាទ, មែន។

**ស៖** ហើយលោកបានលើកឡើងទៀតថា មានទំនាស់មួយទៀត យើងហៅថាទំនាស់បដិបក្ខដែលជាទំនាស់ធ្ងន់ធ្ងរដែលវាជាទំនាស់មួយកើតឡើងរវាងទំនាស់ រវាងកសិករ ពលករ ហើយនិងម្ចាស់ដីតើត្រឹមត្រូវទេ?

[១១:៣៣:៥៣]

**ឆ៖** មិនត្រឹមត្រូវទេ។ ខ្ញុំនិយាយពាក្យថាទំនាស់បដិបក្ខនេះ គឺរវាងពួកឈ្លានពាន ហើយនិងប្រទេសដែលត្រូវឈ្លានពាន។ នេះជាទំនាស់បដិបក្ខស្លាប់រស់ ព្រោះវាបាត់បង់ប្រទេសជាតិ ឯទំនាស់ក្នុងប្រជាជនដូចគ្នា មិនមែនជាទំនាស់ស្លាប់រស់ទេ ដោះស្រាយគ្នាដោយការចរចាគ្នា ដោយការអីបានប្រឹក្សាគ្នាទៅ ប្រជុំពិភាក្សាគ្នាដោះស្រាយ។

ដូច្នោះ វាទាល់តែមានឯកសារយកមកបញ្ជាក់ឲ្យច្បាស់ ដើម្បីខ្ញុំអធិប្បាយជូន។

[១១:៣៤:៥៥]

**ស៖** ខ្ញុំមិនបានសួរលោកយោងទៅលើឯកសារជាក់លាក់ណាទេ ក្នុងឋានៈលោកជាអនុលេខាបក្សគឺថា លោកមានវត្តមាននៅក្នុងសមាជនេះ។ ខ្ញុំគ្រាន់តែសួរសំណួរមួយសាមញ្ញទេ ថាតើបក្សបានសន្និដ្ឋានរវាងទំនាស់រវាងកសិករ ហើយនិងទំនាស់រវាងម្ចាស់ដី និងទំនាស់បដិបក្ខ ឬទំនាស់ស្លាប់រស់នេះ។ ខ្ញុំសួរតែចំណុចនេះទេ។

**ឆ៖** សូមជម្រាបលោកប្រធាន អំមិញលោកព្រះរាជអាជ្ញាមានប្រសាសន៍ថា ទំនាស់រវាងកសិករនិងម្ចាស់ដី។ ក្នុងឯកសារវាមាននិយាយល្អិត មិនមែនម្ចាស់ដីធម្មតាទេ ម្ចាស់ដីបរិវារបរទេសម្ចាស់ដីឃោរឃៅ។ បើថានិយាយម្ចាស់ដីទទេនោះវាខុស។ វាគ្មាន-- មិនមាន-- ទំនាស់ម្ចាស់ដី និងកសិករសម្រួលគ្នាបាន ប៉ុន្តែបើម្ចាស់ដីនោះវាធ្វើបរិវារចក្រពត្តិ បរិវារពួកឈ្លានពានអាហ្នឹងវាបម្រើពួកឈ្លានពានហើយ អាហ្នឹងហើយដែលជាទំនាស់បដិបក្ខស្លាប់រស់។ ប៉ុន្តែបើលោកនិយាយមួយកំណាត់ៗអីចឹង បានជាខ្ញុំទាមទារហើយទាមទារទៀត យកឯកសារមកឲ្យខ្ញុំមើលមើល៍ ហើយលោកនៅតែអធិប្បាយតាមទស្សនៈរបស់លោក។

[១១:៣៦:៤៩]

**សៈ** ថាតើដោយសារតែលទ្ធផលនៃការទំនាស់គ្នាស្លាប់រស់នេះ គឺទោះបីជាទំនាស់បែបណាក៏ដោយថាតើគេដោះស្រាយទំនាស់នេះដោយរបៀបណា?

**ឆៈ** សូមជម្រាបលោកប្រធាន ការដោះស្រាយទំនាស់បដិបក្ខវាផ្សេង ការដោះស្រាយទំនាស់ផ្ទៃក្នុងវាផ្សេង វាមិនដូចគ្នាទេ។ ការដោះស្រាយរវាងខ្មាំង ហើយនិងប្រទេសដែលត្រូវឈ្លានពានហ្នឹងវាផ្សេង។ ដូច្នោះលោកសួរមួយកំណាត់អ៊ីចឹង ខ្ញុំឆ្លើយយ៉ាងម៉េចឲ្យច្បាស់។ ខ្ញុំឆ្លើយ-- លោកសួរមួយកំណាត់។

**សៈ** លោកទើបតែនិយាយអម្បាញ់មិញថា មានដំណោះស្រាយទៅលើវិវាទផ្ទៃក្នុង ឬក៏ទំនាស់ផ្ទៃក្នុង ឬទំនាស់ស្លាប់រស់នេះ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះថាតើទំនាស់ផ្ទៃក្នុង គេដោះស្រាយដោយរបៀបណា? ហើយទំនាស់បដិបក្ខ ឬទំនាស់ស្លាប់រស់នេះគេដោះស្រាយដោយរបៀបណា?

[១១:៣៨:១៦]

**ឆៈ** ទំនាស់-- ខ្ញុំសូមសួរលោកវិញ។ គោរពលោកប្រធាន។ ទំនាស់ផ្ទៃក្នុងហ្នឹង ទំនាស់រវាងអ្នកណា និងអ្នកណា? ឯទំនាស់បដិបក្ខហ្នឹង ទំនាស់រវាងអ្នកណា និងអ្នកណា? បញ្ហានេះ វាមិនមែនស្រួលទេ វាស្មុគស្មាញ ការដោះស្រាយទំនាស់វាស្មុគស្មាញ។ ដូច្នោះទាល់តែល្អិតបន្តិច។ មិនមែនចេះតែដោះស្រាយៗ តាមចិត្តយើងចង់ឯណា។

**សៈ** ខ្ញុំសួរទៅអ្វីដែលលោកទើបតែថ្លែងពីរនាទីបីមុននេះ ថាតើការដោះស្រាយទំនាស់ផ្ទៃក្នុង ឬក៏ទំនាស់បដិបក្ខនេះ គេដោះស្រាយដោយរបៀបណា? ហើយខ្ញុំសួរទៅលោកថាតើលោកមានន័យថាម៉េច ហើយដោះស្រាយដោយរបៀបណា?

[១១:៣៩:២៦]

**ឆៈ** ខ្ញុំសូមសួរលោកវិញ ដោះស្រាយទំនាស់អី?

**សៈ** ពីរបីនាទីមុននេះលោកបានលើកឡើងថា គេដោះស្រាយទំនាស់នោះដោយរបៀបណា លោកទើបលើកឡើង ទោះបីវាជាទំនាស់ផ្ទៃក្នុងក្តី ឬក៏ទំនាស់បដិបក្ខក្តី។ ហេតុដូច្នេះឯងបានជាខ្ញុំសួរទៅលោកថាតើលោកចង់មានន័យថាម៉េច ការដោះស្រាយហ្នឹង? ថាតើទំនាស់ ខុសៗគ្នាបែបនេះត្រូវបានដោះស្រាយដោយរបៀបណា?

**ឆៈ** លោកសួរឲ្យច្បាស់អ៊ីចឹង។ ការដោះស្រាយទំនាស់ផ្ទៃក្នុង គឺដោះស្រាយដោយការប្រជុំ ដោយការរៀនសូត្រ ដោយការពិភាក្សាគ្នាជាមូលដ្ឋាន ដោយការចរចាគ្នា រកហេតុរកផល មូលហេតុនៃ

ទំនាស់ៗហ្នឹងមកអី? មូលហេតុនៃទំនាស់មកពីអី? បច្ច័យអាក្រក់ បច្ច័យល្អរបស់ទំនាស់ហ្នឹងមកពីអី? យ៉ាងម៉េច? ហើយត្រូវដោះស្រាយយ៉ាងម៉េច? អាហ្នឹងវាមានល្អិតទៅទៀតបានជាខ្ញុំទាមទារយកឯកសារមកមើលមើល៍ វាសរសេរយ៉ាងម៉េច? ហើយលោកសួរ អ្នកណាចេះតែសួរហ្នឹង។ ឯទំនាស់បដិបក្ខ ក៏អ៊ីចឹងដែរ ទំនាស់បដិបក្ខត្រឹមណា? ជួនណាផ្ទៃក្នុងយើងក៏មានទំនាស់បដិបក្ខ ដូចទំនាស់ពីរឿងដីរឿងធ្លីសព្វថ្ងៃហ្នឹង អាហ្នឹងបើតាមខ្ញុំមើល វាទំនាស់ លោតទឹកស្លាប់ប៉ុន្មាននាក់ទៅហើយ អាហ្នឹងទំនាស់ដោះស្រាយយ៉ាងហ្នឹង។ លោកយកការជាក់ស្តែងនៅសង្គមឥឡូវនេះយកមកប្រៀបធៀបមើលមើល៍។

**សះ** ខ្ញុំសូមអានឯកសារពីរផ្សេងទៀត ដែលបក្សជាអ្នកចេញផ្សព្វផ្សាយឯកសារនេះ ហើយខ្ញុំសូមសួរទៅលោក ឲ្យលោកពន្យល់នៅក្នុសារាចរណ៍ គឺនិយាយអំពីការពង្រឹងវណ្ណៈកម្មករ វណ្ណអធនរបស់បក្ស ហើយលើកឡើងអំពីថាកំហុសតូចតាច វាអាចនាំឲ្យឈានទៅដល់ទំនាស់បដិបក្ខ។ នៅក្នុងស្ថានភាពបែបនេះយើងមិនអាចរស់នៅជាមួយគ្នា និងធ្វើការជាមួយគ្នាបានទេ។ សូមបន្តដកស្រង់សម្តីទៀត ទំនាស់ទាំងនេះត្រូវដោះស្រាយទៅតាមប្រភេទទំនាស់ និងស្ថានភាពនៃទំនាស់ ទោះបីជាវាជាទំនាស់ផ្ទៃក្នុងក្តី ឬក៏ជាទំនាស់ស្លាប់រស់ក្តី។ ហើយឯកសារ D366/7156 និងឯកសារជាខ្មែរ 00442476 ហើយជាភាសាអង់គ្លេស 00743812 និងជាភាសាបារាំង 00721105។ ខ្ញុំសូមយោងទៅលើឯកសារនិយាយអំពីខែវិច្ឆិកា ឆ្នាំ១៩៧៦ ដែលថា គឺគេបានចូលរួមក្នុងបដិវត្តន៍ ហើយបើសិនណាជាមានការចង់ផ្តួលរំលំបក្ស គឺថាវាជាទំនាស់បដិបក្ខ យើងត្រូវតែចាត់វិធានការ។ ហើយនេះ គឺជាឯកសារ D243/1/8 និងឯកសារ ERN ជាភាសាខ្មែរ 0000499 ជាភាសាខ្មែរ 00455312 និងជាភាសាបារាំង 00411949។ តើត្រឹមត្រូវទេលោក នួន ជា ពាក្យថា ទំនាស់បដិបក្ខ ឬទំនាស់ស្លាប់រស់នេះ ជាទំនាស់មួយដែលថា អ្នកគួរភាគីទំនាស់មិនអាចរស់នៅជាមួយគ្នា និងធ្វើការជាមួយគ្នាបាននោះ មែនឬទេ?

[១១:៤៤:២៤]

**ជះ** ខ្ញុំទទូចហើយ ទទូចទៀត ទាល់តែយកឯកសារមកពិនិត្យឲ្យហ្មត់ចត់ ពីព្រោះការសរសេរការនិយាយហ្នឹង វាមានអធិប្បាយរបស់វា វាមិនមែនមានតែខ្លីប៉ុណ្ណឹង ហើយយើងយល់ផ្សេងទេ ព្រោះមនុស្សយើង មនុស្ស១០នាក់ ទស្សនៈខុសគ្នាទាំង១០នាក់។ លោកទស្សនៈផ្សេង ខ្ញុំទស្សនៈផ្សេង លោកនិយាយតាមទស្សនៈរបស់លោក ខ្ញុំនិយាយតាមទស្សនៈរបស់ខ្ញុំ។ ដូច្នោះឲ្យវាឯកភាពគ្នាយ៉ាងម៉េចបាន?

បានជាខ្ញុំទទូចហើយទទូចទៀត យកមកមើល យកឯកសារមកមើល ឲ្យខ្ញុំពិនិត្យពិចារណាមើល ថាតើជាឯកសាររបស់ខ្ញុំមែនឬមិនមែន?

[១១:៤៥:២៨]

**ស៖** លោក នួន ជា ខ្ញុំចូលទៅគោលនយោបាយរបស់បក្ស ឯកសារមួយផ្សេងទៀត។ នៅក្នុងសេចក្ដីថ្លែងបើករបស់លោក លោកបានរៀបរាប់ថាតើបក្សបានអនុម័តនូវផែនការយុទ្ធ-- គោលនយោបាយយុទ្ធសាស្ត្រ ហើយដែលក្រោយមកគឺថាត្រូវបានកែប្រែនៅក្នុងការពិភាក្សានៅក្នុងឆ្នាំ១៩៥៨ ជាមួយលោក ខឹម នួន គឺថាយើងគោលនយោបាយសម្រាប់នៅតាមមូលដ្ឋាន និងសម្រាប់ទីក្រុង មានគោលនយោបាយយុទ្ធសាស្ត្រ តើលោកមានន័យថាម៉េច? គោលនយោបាយយុទ្ធសាស្ត្រសម្រាប់ជនបទ និងសម្រាប់ទីក្រុងនេះ?

**ឆ៖** លោកថាខ្ញុំនិយាយជាមួយ នួន ណា? ខ្ញុំមិនដែល-- ខឹម នួន ណា ខ្ញុំមិនដែលស្គាល់ផង? ស្អី ងួន?

[១១:៤៦:៤៥]

**ស៖** យើងបាននិយាយពីឈ្មោះនេះច្រើនដងមកហើយ ថាលោកមានការជជែកគ្នាលេងជាមួយលោក ខឹម ងន់ នៅក្នុងឆ្នាំ១៩៥៨។ តើលោកនៅចាំបានទេ ថាលើកឡើងថាបក្សគឺថាត្រូវមានគោលនយោបាយសម្រាប់មូលដ្ឋាន និងគោលនយោបាយយុទ្ធសាស្ត្រសម្រាប់ទីក្រុង? តើលោកមានចាំថាលោកមានថ្លែងចំណុចនេះឡើងទេ?

**ឆ៖** ខ្ញុំសូមបញ្ជាក់ ខឹម ងន់ ៗ ឬអ្នកណា?

**ស៖** បាទ ឈ្មោះនេះហើយ ឈ្មោះ ខឹម ងន់ នេះហើយ ដែលខ្ញុំកំពុងតែនិយាយ ប៉ុន្តែខ្ញុំសួរអំពីសេចក្ដីថ្លែងការណ៍របស់លោក អំពីសម្ដីរបស់លោក។

**ឆ៖** តាមមាគ៌ា អានេះខ្ញុំត្រឡប់ទៅនិយាយខាងមាគ៌ាវិញតែងដែល ៗ។ ដូច្នោះខ្ញុំមិននិយាយទេ។ មាគ៌ាយុទ្ធសាស្ត្រ មាគ៌ាយុទ្ធវិធី ខ្ញុំអធិប្បាយអស់ហើយ ដល់លោកសួរខ្ញុំទៀតនាំតែខាតពេលទេ។

[១១:៤៨:៤១]

**ស៖** លោក នួន ជា ថាតើហេតុផលអ្វីបានជាបក្សបានសម្រេចប្រើប្រាស់ស្រុកស្រែ ឬក៏ថាជនបទនោះគឺថាជាមូលដ្ឋានចម្បងជាជាងទីក្រុង ជាជាងទីប្រជុំជននោះ?

**ឆ៖** សូមជម្រាបលោកប្រធាន ការដែលបក្សយកជនបទចុងកាត់មាត់ញក ជាសំខាន់ ពីព្រោះប្រជាជននៅចុងកាត់មាត់ញកក្រីក្រលំបាកវេទនាតោកយ៉ាក។ ដូច្នោះ ត្រូវឲ្យប្រជាជនចុងកាត់មាត់ញកភ្ញាក់រឭក ចេះធ្វើរបរដាំដុះរកទទួលទាន។ ដូច្នោះត្រូវកែប្រែ ការកែប្រែជីវភាពត្រូវកែប្រែពីចុងជនបទចុងកាត់មាត់ញកមកវិញ មកមុន ពីព្រោះអ្នកនៅទីក្រុង ឬនៅទីប្រជុំជនគេមានល្មមទទួលទានហើយ ឯនៅចុងកាត់មាត់ញកក្រីក្រណាស់ លោកអញ្ជើញទៅមើលចុះ។ នៅរលាក់កងជើង នៅឱរ៉ាល់ នៅស្អីៗនោះ ក្រលំបាកវេទនា រហេមរហាម អ្នកណាយកចិត្ត-- កាលណោះ អ្នកណាយកចិត្តទុកដាក់ជួយ? គ្មានទេ រកតែខោអាវស្លៀកពាក់គ្មានផង។ ដូច្នោះត្រូវចាប់ផ្តើមធ្វើការងារពន្យល់ អធិប្បាយ ឃោសនាឲ្យប្រជាជនចុងកាត់មាត់ញកយល់បណ្តើរៗមក។ នេះគឺជាវិធីដំណើរការ។

**ស៖** ថាតើមានហេតុផលណាដែលៗថាបក្សបានសម្រេចយកទីជនបទធ្វើជាមូលដ្ឋានបង្អែកជាជាងយកទីក្រុង។ តើអាចមានហេតុផលណាផ្សេងទៀតទេ?

**ឆ៖** ហេតុផលដូចជាខ្ញុំសូមគោរពលោកប្រធាន។ ហេតុផលដែលយកជនបទ ចុងកាត់មាត់ញកធ្វើជាមូលដ្ឋានបង្អែក ពីព្រោះដើម្បីឲ្យ មួយ គ្មានខ្មាំង។ ខ្មាំងទៅមិនដល់ទេ ចុងកាត់មាត់ញកនោះវានៅតែទីប្រជុំជនទេ ដូច្នោះដំណើរការស្រួលឲ្យការតស៊ូ។ ពីរ ដូចខ្ញុំជម្រាបអ៊ីចឹង ប្រជាជនក្រីក្រលំបាកវេទនាណាស់ ដូច្នោះធ្វើឲ្យប្រជាជនមានហូបមានចុក មានស្លៀកមានពាក់មុនគេ។ ហើយចេះតែធ្វើមកបណ្តើរៗមក ព្រោះនៅទីក្រុងគេល្មមមានហូបមានចុកហើយ។

[១១:៥២:២១]

**ស៖** ខ្ញុំសូមអានឲ្យលោកស្តាប់នូវឯកសារទង់បដិវត្តខែកញ្ញា ឆ្នាំ១៩៧៧។ ខ្ញុំសូមដកស្រង់សម្តី៖ "គោលនយោបាយប្រតិបត្តិការរបស់យើង គឺសម្រាប់យកទីប្រជុំជនមកធ្វើជាមូលដ្ឋានបង្អែក"។ ហេតុអ្វីបានជាយើងយកទីប្រជុំជន ទីជនបទជាជាងទីក្រុង? ទីក្រុងមិនអាចប្រើប្រាស់ជាមូលដ្ឋានបង្អែកបានទេ ដោយសារប្រជាជនច្រើន មានប្រជាជនច្រើន ទីក្រុងតូច ខ្មាំងនៅគ្រប់ទីកន្លែងទាំងអស់ តាំងពីទាហាន នគរបាល បណ្តាញខ្មាំង ផ្សេងៗទៀត ក៏ដូចជាបណ្តាញជនក្បត់គឺថាគឺនៅទីប្រជុំជន។ នេះគឺមក-- ឯកសារ D4243/1.12 (ស៊ីក) ឯកសារ ERN ខ្មែរ 0063150 អង់គ្លេស 00-- បារាំង 0094912 ដែលខ្ញុំសួរទៅលោកថា ហេតុអ្វីបានជាគេសម្រេច បក្សសម្រេចយកទីប្រជុំជនមកធ្វើជាមូលដ្ឋានបង្អែកជាជាងទីក្រុង ទៅវិញនោះ?

[១១:៥៣:៥២]

**ឆ៖** ដូចជាខ្ញុំនិយាយដដែលៗ សូមឲ្យលោកយកឯកសារមកឲ្យខ្ញុំមើលមើល៍។ ឲ្យខ្ញុំឃើញនឹងភ្នែករបស់ខ្ញុំមើល។ បានខ្ញុំឆ្លើយបាន។

**ស៖** លោក នួន ជា ខ្ញុំអាចបង្ហាញទំព័រនេះបាន បើសិនលោកចង់ឆ្លើយ។ ប៉ុន្តែបើលោកស្នើសុំឲ្យដាក់ឯកសារដើមនោះ គឺយើងខ្ញុំមិនអាចធ្វើដូច្នេះបានទេ នេះជាសេចក្តីសម្រេចរបស់តុលាការ។ ប៉ុន្តែបើសិនណា ខ្ញុំអាចបង្ហាញជូននូវទំព័រមួយនៃឯកសារដែលយើងបានថតចម្លងនោះ គឺថាខ្ញុំអាចបង្ហាញជូនបាន។

[១១:៥៤:៤៨]

**ឆ៖** ខ្ញុំក្តាប់នូវសំណូមពររបស់តុលាការគឺ មួយ ស្វែងរកការពិត។ ពីរ រកយុត្តិធម៌។

នេះដែលខ្ញុំស្តាប់លោកប្រធានប្រកាស ទិសគោលដៅ នៃតុលាការនេះ។ ដូច្នោះទាល់តែមានឲ្យច្បាស់លាស់មក បើគ្រាន់តែថា និយាយមាត់ទទេអ៊ីចឹងវាមិន-- វាខុសអំពីគោលដៅដែលចង់រក ការស្វែងការពិត ចង់រកយុត្តិធម៌។ ចុះបើមិនយកមកឲ្យមើលធ្វើម៉េចដឹង អ្នកណា មិនដឹងអ្នកសរសេរយុត្តិធម៌ ឬមិនយុត្តិធម៌ អ្នកណាសរសេរ។ ខ្ញុំក៏ចង់ឲ្យតុលាការនេះ រក ស្វែងរកការពិតដែរ ហើយស្វែងរកការពិតមានប្រយោជន៍ និងយុត្តិធម៌សម្រាប់យុវជនជំនាន់ក្រោយនេះន៎ៃ ដើម្បីរៀនសូត្រ ដកពិសោធន៍។

**ស៖** លោក នួន ជា គឺថាខ្ញុំរីករាយនឹងបង្ហាញជូននូវទំព័រនេះ ហើយខ្ញុំសូមអានជូន ថាតើនេះវាជាសេចក្តីថ្លែងការណ៍ចេញពីគោលនយោបាយរបស់បក្សនោះមែនដែរឬក៏ទេនោះ? តើខ្ញុំសូម--

លោកប្រធានខ្ញុំសូមអនុញ្ញាត! គឺជាឯកសារ ERN ជាភាសាខ្មែរ 0063150។

សំណួររបស់ខ្ញុំសួរងាយទេ ថាតើវាជាសេចក្តីថ្លែងការណ៍ដែលចេញអំពីគោលនយោបាយរបស់បក្សនោះមែនដែរឬក៏ទេ? តើលោកមានបំណងចង់ឆ្លើយទៅនឹងសំណួរនេះទេ ក្រៅពីលោកស្នើសុំឲ្យបង្ហាញឯកសារដើមនោះ?

**ឆ៖** បើលោកបង្ហាញឯកសារដើមឲ្យខ្ញុំ ហើយបើពិតជាឯកសារដើមរបស់ខ្ញុំមែន ខ្ញុំទទួល។ ខ្ញុំសូមគោរពលោកប្រធាន។ ប៉ុន្តែបើលោកគ្រាន់តែនិយាយទទេ គ្មានឯកសារយកមកបញ្ជាក់ គ្មានភស្តុតាងយកមកបញ្ជាក់ ខ្ញុំទទួលយ៉ាងម៉េចបាន?

**លោក ខេល លីសាក់៖**

លោកប្រធាន តើខ្ញុំសូមការអនុញ្ញាតបង្ហាញនូវទំព័រពាក់ព័ន្ធនៅក្នុងឯកសារនេះ គឺជាភាសាខ្មែរ

ERN0063150 តើខ្ញុំសូមបង្ហាញនៅលើអេក្រង់បាន ឬក៏មិនបានលោកប្រធាន?

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៩:០៥]

**ប្រធានអង្គជំនុំ៖**

លោក នួន ជា អង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីព្រឹកមិញ ចំពោះឯកសារអេឡិចត្រូនិច ដែលប្រើប្រាស់នៅក្នុងសំណុំរឿងក្ដីនេះ។ ឯកសារទាំងអស់នេះ អង្គជំនុំជម្រះចាត់ទុកជាឯកសារភស្តុតាងដាក់នៅចំពោះមុខអង្គជំនុំជម្រះសម្រាប់ភាគីដេញដោល ដោយហេតុប្រព័ន្ធនៃការប្រើប្រាស់នៅក្នុងសំណុំរឿងនៅទីនេះ គឺប្រើប្រាស់ប្រព័ន្ធឯកសារអេឡិចត្រូនិច។ ហើយចាប់តាំងពីមុនពេល និងរហូតដល់ពេលសហចៅក្រមស៊ើបសួរ ស៊ើបអង្កេតបានចេញដីកាដំណោះស្រាយ មិនមានមេធាវី ឬភាគីណាមួយប្ដឹងមោឃភាពកិច្ចដំណើរការនីតិវិធី អំពីប្រភេទឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ ដែលបានបង្ហាញគ្រប់ៗគ្នា គ្រប់ភាគីទាំងអស់ ទាំងអង្គជំនុំជម្រះ តាមកញ្ចក់ទូរទស្សន៍ ដែលយើងប្រើប្រាស់តាំងពីដើមទីរហូតមកទីនេះ។ អ៊ីចឹងអង្គជំនុំជម្រះបានសម្រេចរួចហើយ ដោយសាររឿងក្ដីនេះមានឯកសារធំធេង ហើយដែលមានតែមធ្យោបាយប្រើប្រាស់តាមប្រព័ន្ធឯកសារអេឡិចត្រូនិច ហើយគ្រប់គ្រងដោយឯកសារអេឡិចត្រូនិចប៉ុណ្ណោះ ទើបអាចគ្រប់គ្រងសំណុំរឿងនេះបានល្អ ត្រឹមត្រូវហើយឆាប់រហ័សនៅក្នុងការធ្វើ ក្នុងការដោះស្រាយបញ្ហាឲ្យបានឆាប់រហ័ស និងទាន់ពេលវេលា។

[១២:០១:០៣]

ដូច្នេះ នៅក្នុងឯកសារចំពោះមុខដែលបានដាក់ដោយសហព្រះរាជអាជ្ញានេះ សូមលោក នួន ជា ពិនិត្យអាននូវឯកសារនេះ រួចហើយលោកឲ្យបញ្ចេញនូវមតិយោបល់ជុំវិញបញ្ហានៃខ្លឹមសារនៃឯកសារដែលបានដាក់ចំពោះមុខនេះ។ ថាតើលោកមានមតិយោបល់យ៉ាងដូចម្ដេចទៅលើខ្លឹមសាររបស់វា យើងគិតថាអ្វីៗដែលលោកបានជួបប្រទះ មានបទពិសោធន៍បានជួបប្រទះនៅក្នុងជីវិតរបស់លោក និងខ្លឹមសារនៃឯកសារដែលមានដោយគ្មានភាគីណាមួយប្ដឹងមោឃភាពកិច្ចដំណើរការនីតិវិធី នៅក្នុងអំឡុងពេលដែលច្បាប់កំណត់សិទ្ធិឲ្យនោះ គឺមានន័យថាជាឯកសារផ្លូវការដែលដាក់មកដេញដោលបានហើយ។

ចំណែកឯខ្លឹមសារគឺជាបទពិសោធន៍ដែលលោកបានជួបប្រទះនៅក្នុងជីវិតតស៊ូរបស់លោក។ តើលោកអាចអានបានទេ? បើលោកអានមិនបានទេ គឺអង្គជំនុំជម្រះនឹងចាត់ក្រឡាបញ្ជីឲ្យអាននូវខ្លឹមសារ

នៃឯកសារដែលដាក់ដោយសហព្រះរាជអាជ្ញានេះ ដើម្បីឲ្យយល់អំពីខ្លឹមសាររបស់វា។ តើលោកអាចធ្វើការកត់សម្គាល់លើបញ្ហានេះបានទេ?

[១២:០២:៣៨]

**លោក នួន ជា៖**

អរគុណលោកប្រធាន ដែលបានមានមតិយ៉ាងជាក់ច្បាស់ ដើម្បីរកការពិត និងយុត្តិធម៌។ តែខ្ញុំឲ្យខ្ញុំជឿ ទុកចិត្តលើតុលាការមួយភាគរយបានទេ? បើមិនឲ្យខ្ញុំមើលឯកសារដែល ឯកសារពិតឲ្យខ្ញុំឃើញផងមើល៍! ខ្ញុំគោរពតុលាការហើយ ព្រោះតុលាការជាបូជនីយស្ថាន ហើយបុគ្គលក្នុងតុលាការជាបូជនីយបុគ្គលដែលខ្ញុំគោរព។ ប៉ុន្តែខ្ញុំទទូចហើយ ទទូចទៀត ទទូចតាំងពីព្រឹករហូតដល់ថ្ងៃនេះ រហូតដល់ថ្មើរនេះ ហើយយកឯកសារមកឲ្យខ្ញុំមើលមើល៍! ហើយដាក់នេះមើលៗវាមិនឃើញទេ ហើយឯកសារហ្នឹង ខ្ញុំមើលអំមិញឃើញអក្សរតូចៗមួយ។ នេះសូមគោរពលោកប្រធាន។ សូមអរគុណលោកប្រធានជាអនេក។

[១២:០៤:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រមគឺថាកូនក្ដីរបស់ខ្ញុំគាត់កំពុងជំទាស់តវ៉ាទៅនឹងយថាភាពនៃឯកសារជាអេឡិចត្រូនិចនេះ។ គឺថាគាត់កំពុងជំទាស់តវ៉ាដើម្បីធ្វើម៉េចឲ្យទទួលបានឯកសារដើមមកបង្ហាញគាត់ ហើយគាត់បានជំទាស់ច្រើនដងហើយថាមិនឲ្យយើងទទួលយកឯកសារនេះទេ។ ដោយសារថាត្រូវតែរកឲ្យឃើញនូវយថាភាពនៃឯកសារនេះជាមុនសិន។ ខ្ញុំមិនមានន័យថាឯកសារនេះវាមិនមានយថាភាព ឬក៏-- ប៉ុន្តែយើងតវ៉ារកឯកសារដែលថាមានយថាភាព ហើយនៅ--ប្រហែលជាអាចផ្អាកការពិភាក្សាសួរដេញដោលទៅលើឯកសារនេះសិន ហើយសឹមយកបញ្ហានេះ មកពិភាក្សាដេញដោលសួរដេញដោលតទៅទៀតនូវសប្តាហ៍ក្រោយ បើមិនកំណត់យថាភាពបាននោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

មានភាគីណាចង់លើកឡើងអំពីបញ្ហានេះដែរឬទេ?

សូមអញ្ជើញបាទ!

[១២:០៥:៣៥]

**លោក វិណ្ណៀម ស្មីត៖**

មេធាវីការពារក្តីលើកឡើងត្រឹមត្រូវ គឺថាសប្តាហ៍ក្រោយ យើងអាចពិភាក្សាអំពីភាពអាចទទួលយកបាននូវឯកសារនេះ។ ហើយលោក លោកស្រីចៅក្រម ខ្ញុំសុំឲ្យលោក នួន ជា គឺថាគាត់មិនបានឆ្លើយទៅនឹងសំណួរមួយចំនួនទាក់ទងនឹងឯកសារនេះ ដោយសារតែគាត់លើកឡើងអំពីទម្ងន់នៃឯកសារនេះ។ ហើយទាក់ទងទៅនឹង ថាតើអត្ថបទនេះ ថតចម្លងចេញពីឯកសារដើម ឬក៏អត់នោះ ដែលទាមទារឲ្យបង្ហាញនេះ ដើម្បីឲ្យទទួលយកឯកសារថតចម្លងដាក់ក្នុងសំណុំរឿងបាន។ ខ្ញុំសូមជម្រាបជូនថា លោកប្រធាននៅក្នុងតុលាការអន្តរជាតិ គឺថាមិនត្រូវឲ្យបង្ហាញដាក់ជូនឯកសារដើមមកតុលាការទេ លុះណាតែមានវិមតិសង្ស័យទៅលើឯកសារថតចម្លងណាមួយ នោះទើបតុលាការស្នើសុំឲ្យបង្ហាញនូវឯកសារដើមនេះ។

[១២:០៦:៣៦]

ហើយមុននឹងជនជាប់ចោទលើកឡើងអំពីបញ្ហានេះ ការបញ្ជាក់បង្ហាញណាមួយថាឯកសារនេះ ឬក៏ឯកសារដទៃទៀត ដែលសហព្រះរាជអាជ្ញាបានដាក់ជូននោះ គឺថាជាការពិតហើយ គឺយើងបានថតចម្លងចេញពីឯកសារដើម គឺហេតុដូច្នេះឯង បានជាមិនតម្រូវឲ្យយកឯកសារដើមមកដាក់ជូននៅក្នុងឯកសារនេះទេ។ ហើយនេះ គឺយើងបានយោងទៅលើយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិនានា ហើយហេតុផលមួយទៀតនោះ គឺដោយសារថា សវនាការនេះវាអាចគឺថាមានការផ្អាក ឬក៏យ៉ាងនោះ នៅពេលដែលមានជនជាប់ចោទ គឺថាជំទាស់តវ៉ាថា មិនទទួលយកឯកសារនោះ ឬក៏ឲ្យបង្ហាញឯកសារដើម ដោយមានមូលដ្ឋានច្បាស់លាស់ ដើម្បីសន្និដ្ឋានថា ដែលជំទាស់ថា ឯកសារនេះគឺជាឯកសារមិនមែនចេញពីឯកសារដើមទេ។ ខ្ញុំចង់ឃើញឯកសារដើម ចង់ឃើញឯកសារប្រភពដើមតែម្តងនោះ។ នោះទើបឲ្យតុលាការបង្ហាញជូននូវឯកសារណានេះ បើមិនដូច្នេះទេ គឺថាគេនឹងអាចបន្តសវនាការតទៅមុខទៅទៀតបាន។

[១២:០៧:៥២]

ដោយសារតែយើងមានឯកសារជាងមួយសែនឯកសារ ហើយមានឯកសារជាង ៤.០០០ច្បាប់ទៀត។ បើសិនណា ជនជាប់ចោទ គាត់ស្នើសុំឲ្យបង្ហាញនូវឯកសារដើមជាង៤.០០០ច្បាប់នេះ ដោយ

មិនផ្ដល់មូលដ្ឋានសំអាងហេតុណាមួយក្នុងការទាមទារនោះទេ។ ដោយគ្រាន់តែនិយាយថា ចង់ឃើញឯកសារដើម។ នោះបញ្ជាក់ឲ្យឃើញថា យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិមិនបានគាំទ្រទៅដល់ការបដិសេធនេះទេ។ ហើយធ្វើការបែបនេះ គឺថាការស្វែងរកយុត្តិធម៌គឺនឹងមិនអាចផ្ដល់បានក្នុងរយៈពេលមួយឲ្យបានឆាប់រហ័សនោះទេ។

លោក លោកស្រីចៅក្រម មេធាវីការពារក្ដីរបស់ នួន ជា គាត់មានឱកាសធ្វើដូច-- គាត់មានការឱកាសក្នុងការសរសេរឲ្យបាន-- ជំទាស់តវ៉ាឲ្យបានពេញៗនៅលើចំណុចទាំងអស់នេះ។ ហើយក្រោយមកគឺថាជនជាប់ចោទ គ្រាន់តែបដិសេធថា សុំឲ្យបង្ហាញឯកសារដើមមកជូនតុលាការ។

[១២:០៩:០៣]

នេះគឺជា-- បើធ្វើបែបនេះ មានន័យថា ដំណើរការជំនុំជម្រះក្ដីគឺមិនបានប្រព្រឹត្តទៅជឿនលឿន ការស្វែងរកយុត្តិធម៌មិនអាចបានជឿនលឿននោះទេ។ លើកលែងតែប៉ុណ្ណោះទេ លុះណាតែឯកសារនេះគឺថាមិនមានឈ្មោះ មិនមានស្អីច្បាស់លាស់ដែលត្រូវថតចេញពីឯកសារដើម។ ហើយនៅក្នុងពេលនោះគឺថាមេធាវីការពារក្ដី ក៏មិនបានលើកឡើងពីចំណុចនេះពីមុននេះឲ្យបានច្បាស់លាស់នោះដែរ។ ហើយប្រសិនណា ជាជនជាប់ចោទមិនបដិសេធមិនឆ្លើយដោយសំអាង តែថាវាជាឯកសារថតចម្លង។ ពេលនោះ គឺយើងខ្ញុំសូមជូនជាយោបល់ថា ឯកសារមួយចំនួនគឺថានឹងមិនមានបន្ទុកធ្ងន់ធ្ងរនៅក្នុងសំណុំរឿងនោះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! សូមអញ្ជើញលោកមេធាវី។

[១២:១០:០៣]

**លោក ម៉ៃខល កាណាវាស៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ក៏ដូចជាអស់លោក លោកស្រីទាំងអស់នៅក្នុងបន្ទប់សវនាការ។ ខ្ញុំមានចំណុចពីរបីដែលត្រូវលើកឡើង សហព្រះរាជអាជ្ញារងអន្តរជាតិខកខានមិនបានលើកឡើងដែលទាក់ទងទៅនឹង-- ថាតាមធម្មតាតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺថាបានសួរថាតើឯកសារនេះបានមកពីណា? ទោះបីមិនតម្រូវឲ្យបង្ហាញឲ្យដាក់នូវឯកសារដើមនៅចំពោះមុខសាក្សីដោយសាក្សីនីមួយៗក៏ដោយ ក៏ប៉ុន្តែ ធម្មតាគេសួរអ្នកដែលរក្សាទុកឯកសារនោះឲ្យគាត់មកឆ្លើយ។ យើងខ្ញុំបានដាក់សារណាដោយបញ្ជាក់ថា យើងខ្ញុំសុំឲ្យបង្ហាញយថាភាពឯកសារទាំងអស់មុននឹងយក

ឯកសារនោះមកធ្វើការពិភាក្សាដេញដោល ហើយនិង-- ខ្ញុំដឹងថានៅសប្តាហ៍ក្រោយ យើងនឹងជំទាស់តវ៉ាគ្នាទៅលើចំណុចនេះ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាត្រូវតែបង្ហាញថា តើឯកសារនេះសហព្រះរាជអាជ្ញាបានមកពីណា ហើយថតចម្លងពីពេលណា ថតចម្លងចំណុចណា។ នេះគឺជាចំណុចទីមួយរបស់ខ្ញុំ។

[១២:១១:២៤]

ចំណុចទីពីរ គឺទាក់ទងទៅនឹងសក្ខីកម្ម ដែលយើងបានយកមកពិភាក្សាដេញដោលគ្នានេះ ហើយខ្ញុំក៏សុំអធ្យាស្រ័យដែលខ្ញុំបានចូលមកសវនាការយឺតព្រឹកមិញនេះ ក៏ប៉ុន្តែទាក់ទងទៅនឹងឯកសារឆ្នាំ--សមាជ១៩៧៦។ ក្រោយមកសហព្រះរាជអាជ្ញាសួរទៅដល់គោលនយោបាយទៀត ហើយដោយមិនបានសួរថា តើពិភាក្សាគ្នា តើលោក នួន ជា បានពិភាក្សាអ្វីខ្លះមុននឹងឈានចេញទៅដាក់គោលនយោបាយ។ ក្រោយមក ក៏គាត់លោតទៅលើរយៈពេល១៧ឆ្នាំ ក្រោយទៀត ក្រោយមកដើម្បីបង្ហាញឲ្យឃើញថាឯកសារនេះ វាគាំទ្រទៅដល់ឯកសារដែលបានបោះពុម្ពផ្សាយ ចេញផ្សាយនៅក្នុងឆ្នាំទសវត្សរ៍១៩៦០។ ហេតុដូច្នេះហើយបានជាខ្ញុំសូមស្នើដល់អង្គជំនុំជម្រះថា នេះជាការខាតបង់ពេលវេលា បោះបង់ពេលវេលាចោលហើយ ដោយការខកខានមិនបានពិភាក្សាថា រយៈពេលបីថ្ងៃនៅក្នុងសមាជទសវត្សរ៍ឆ្នាំ១៩៦០ ពិភាក្សាគ្នាអីខ្លះ? ដាក់ចេញគោលនយោបាយអ្វីខ្លះដែរ? ហើយថាតើមានកម្មវិធីនយោបាយអីខ្លះដែលយកមកប្រជុំពិភាក្សាគ្នានេះ គួរតែនឹងសួរចំណួរបែបនេះពីចំណុចដើម។ ហើយបានយើងចាប់ផ្តើមសួរលម្អិតលម្អន់ បង្ហាញលោក នួន ជា ទៅនឹងឯកសារមួយចំនួនដែលទាក់ទងទៅនឹង។

[១២:១២:៥៦]

ដូច្នេះសម្រាប់ជាយោបល់ខ្ញុំ គឺថាមិនជាការត្រឹមត្រូវទេដែលនិយាយទសវត្សរ៍៦០ ហើយក្រោយមកនិយាយពីគោលនយោបាយ ដើម្បីយកទៅធ្វើការជំទាស់តវ៉ាគាំទ្រទៅដល់ឯកសារនៅទសវត្សរ៍១៩៦០។ ពីព្រោះក្នុងរយៈពេល១៧ឆ្នាំនេះ គឺថាវាមានការកែប្រែច្រើនណាស់ ស្ថានភាពកែប្រែច្រើនណាស់ ដូច្នេះគួរណាស់តែមានពិភាក្សា-- ពីព្រោះសំណួរភាគច្រើន គឺថាជាសំណួរបែបនាំមុខ ដែលវានាំឲ្យឈានទៅដល់ការឯកសារមួយគាំទ្រទៅដល់ឯកសារមួយ។

ដូច្នេះការតវ៉ាជំទាស់ទៅឯកសារនេះ គឺជាការត្រឹមត្រូវ ហេតុដូច្នេះបានជាមានវត្តមានមេធាវីការពារក្តីនៅទីនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំះ**

សូមអញ្ជើញមេធាវី នួន ជា!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណអង្គជំនុំជម្រះ។ ខ្ញុំសូមលើកសង្ខេបទេ សហព្រះរាជអាជ្ញាលើកឡើងថា កូនក្ដីខ្ញុំមិនបានជំទាស់តវ៉ាជាក់លាក់ទៅលើឯកសារដែលគាត់ជំទាស់ គឺទង់បដិវត្តនេះឯង។ មានចំណុចមួយចំនួនដែលបង្ហាញឲ្យឃើញថា ជាឯកសារមិនបានថតចម្លងចេញពីឯកសារដើម។ ដូច្នេះវាមិនមានយថាភាពទេ។ ពីព្រោះយើងនិយាយគ្នាតាំងពីទង់បដិវត្តមុនឆ្នាំ១៩៧៥។ ហើយបន្ទាប់មកក៏ត្រូវ បន្ទាប់ពីឆ្នាំ ១៩៧៥ ក៏យើងបោះពុម្ពជាឯកសារវាយពុម្ព ហើយមានទង់ពណ៌ក្រហម។ ហើយឯកសារចុងក្រោយជាឯកសារអេឡិចត្រូនិច កូនក្ដីខ្ញុំបានលើកឡើងថានៅក្នុងឯកសារអេឡិចត្រូនិចថតចម្លងនេះ ឬក៏ថាមកពីណានេះ គឺអក្សរតូចៗពេក គាត់មិនអាចអានបានទេ ខុសពីឯកសារដើម។ អ៊ីចឹងគាត់នៅចាំបានថាឯកសារដើមហ្នឹងគឺវាមានអក្សរធំជាងនេះ។ ដូច្នេះខ្ញុំគិតថាការជំទាស់របស់កូនក្ដីខ្ញុំនេះ គឺជាការជំទាស់មួយសមហេតុសមផលហើយ ដើម្បីធ្វើម៉េចឲ្យមានការបង្ហាញនូវឲ្យមានការធ្វើយុត្តិកម្មផ្សេងទាក់ទងទៅនឹងឯកសារនេះ ដើម្បីចង់បង្ហាញថាឯកសារថតចម្លងនេះគឺជាឯកសារមួយដែលមានយថាភាពត្រឹមត្រូវនេះ ដោយសារថាយើងខ្ញុំមិនអាចបង្ហាញថា ឯកសារនេះមកពីណាទេ គឺខាងអយ្យការទេជាអ្នកចោទប្រកាន់ត្រូវបង្ហាញឯកសារនេះ ថាមកពីខាងណា។

[១២:១៥:២៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវី!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ។

ខ្ញុំបាទសូមធ្វើការកត់សម្គាល់ជាលក្ខណៈទូទៅ ដោយសារនីតិវិធីនៃការបង្ហាញឯកសារនេះវាពាក់ព័ន្ធរឿងទូទៅដែរ។ ដូច្នេះវាអាចពាក់ព័ន្ធទៅនឹងករណីលោក ខៀវ សំផន នៅក្រោយៗទៀតបាទ។

ជាបឋម ខ្ញុំកត់សម្គាល់ឃើញថា ការកំណត់ទៅលើភាពត្រឹមត្រូវ ភាពដើមនៃឯកសារមិនមែនសំដៅទៅលើការកូពី ចម្លងទេ។ ការកូពី ចម្លងវាជាមធ្យោបាយមួយសម្រាប់ឲ្យយើងងាយស្រួលក្នុងការធ្វើការ ដូចលោកប្រធានមានប្រសាសន៍ថា យើងប្រើប្រព័ន្ធអេឡិចត្រូនិច ដូច្នេះការកូពី វាអាចប្រើបាននៅក្នុងតុលាការយើងនេះ ដោយសារឯកសារច្រើន។ ប៉ុន្តែអ្វីដែលជាបញ្ហាសំខាន់នោះ សួរថាតើការកូពីការថតចម្លងនេះវាមានភាពត្រឹមត្រូវពិតប្រាកដ បង្ហាញពីភាពដើមនោះបានក្នុងកម្រិតណា? ជាក់ស្ដែង

បើយើងមើលឃើញឯកសារដែលតំណាងសហព្រះរាជអាជ្ញាបង្ហាញ មិនមែនត្រឹមតែជាការកូពីលើកទី១ទេ មែនទែនទៅវាកូពីៗតៗគ្នាអាចច្រើនដងទៀត។

[១២:១៦:៤៧]

ដូច្នេះ ភាពដើមរបស់វាយើងឃើញថា បាត់បង់មួយតាមលក្ខណៈជាយថាហេតុ។ ដោយឡែកការពិនិត្យទៅលើថាតើការថតចម្លងនេះត្រឹមត្រូវដោយរបៀបណានោះ ក៏មិនទាន់បានបង្ហាញដែរដូចលោកមេធាវី ម៉ៃខល កាណាវាស បានជម្រាបអម្បាញ់មិញនេះ ព្រោះយើងអត់បានថាតើអ្នកដែលរក្សាទុកឯកសារ អ្នកដែលធ្វើការថតចម្លងហ្នឹង បានធ្វើត្រឹមត្រូវដោយរបៀបណាដែលអាចឲ្យតុលាការយកមកធ្វើការដេញដោលបាន។ ទាក់ទងទៅនឹងសំណូមពររបស់លោក នួន ជា ដែលគាត់លើកថា គាត់មើលមិនឃើញអក្សរតូច ខ្ញុំយល់ថា អានេះវាជាបញ្ហាប្រែប្រួល នៃបច្ចេកទេសកូពី ក៏ថាបានដែរ ឧទាហរណ៍ នៅពេលដែលកូពីទៅវាមានបង្រួមពង្រីកអីអ៊ីចឹងទៅ ធ្វើឲ្យអក្សរហ្នឹងវាប៉ះពាល់តូចធំ។ ដូច្នេះមធ្យោបាយបើសិនជាយើងអាចបង្ហាញថា ឯកសារកូពីនេះវាត្រឹមត្រូវហើយ វាច្បាស់ហើយ ដូចអាដើមហើយ អ៊ីចឹងធ្វើម៉េចដើម្បីពិនិត្យទៅលើខ្លឹមសារ នៃអត្ថបទនេះបាន? បើលោក នួន ជា គាត់ចាស់គាត់មើលមិនឃើញ យើងអាចឲ្យមានអ្នកជំនួយអាន អាចឲ្យលោកមេធាវីរបស់គាត់ក៏បាន ក្រឡាបញ្ជីក៏បាន នែ៎អ៊ីចឹងអាចធ្វើការពិនិត្យទៅលើខ្លឹមសារនេះបានហើយ។ បាទ, សូមអរគុណ។

[១២:១៨:១៤]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញមេធាវីនាំមុខ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានដោយខ្លីទេ គឺថាជាមតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណីគឺថា យើងគាំទ្រគោលជំហររបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងពីអម្បាញ់មិញនេះ ទាក់ទងនឹងបញ្ហាឯកសារដែលយើងកត់សម្គាល់ឃើញថា ឯកសារនេះត្រូវបានដាក់នៅពេលដំណាក់កាលស៊ើបអង្កេតដែលជាដំណាក់កាលមួយ ដែលផ្តល់ឱកាសពិភាក្សាគ្នាទាក់ទងនឹងភាពពិតនៃឯកសារទាំងអស់នេះ ដូច្នេះយើងសង្កេតឃើញថា ឯកសារទាំងអស់នេះយើងបានថតចម្លងនៅពេលនោះ ហើយអ៊ីចឹងភាគីទាំងអស់ដឹងហើយពីរឿងថាថតចម្លងនេះ ដែលថាបានដាក់បញ្ចូលទៅក្នុងឯកសារហ្នឹង រាប់ខែរាប់ឆ្នាំមកហើយ។

**ប្រធានអង្គជំនុំ៖**

ចុងក្រោយសូមប្រគល់វេទិកាទៅសហព្រះរាជអាជ្ញាអន្តរជាតិ។ សូមអញ្ជើញ! ខ្លីបានហើយ ព្រោះជិតអស់ឌីវីឌីហើយ។

[១២:១៩:២៣]

**លោក វីណ្សៀម ស្មីត៖**

ខ្ញុំសូមសង្ខេបទេលោកប្រធាន! គឺមេធាវីការពារក្ដីគឺថា ស្នើសុំឲ្យមានការបង្ហាញយថាភាពឯកសារក្នុងកម្រិតជាអប្បបរមា នៅក្នុងកម្រិតអន្តរជាតិមានច្បាប់ដែលត្រូវបង្ហាញថាតើឯកសារនេះជាឯកសារ-- ដើម្បីឯកសារដើមឬក៏អត់នោះនូវការស្នើសុំនេះគឺសហព្រះរាជអាជ្ញា សូមយល់ស្របទៅលើចំណុចនេះ ដោយសារចំណុចនេះគឺថា យើងអាចលើកពិភាក្សាគ្នានៅសប្ដាហ៍ក្រោយបាន ប៉ុន្តែខ្ញុំសូមឆ្លើយតបសង្ខេបទៅនឹងការជំទាស់តវ៉ា ក៏ដូចជាទំហររបស់លោក នួន ជា ទៅលើឯកសារមួយនេះ ដែលថាឯកសារនេះមិនមែនជាឯកសារថតចេញពីឯកសារដើម ឬឯកសារដែលមានយថាភាពនោះទេ។ សហមេធាវីការពារក្ដីក៏បានលើកឡើងនូវវិមតិសង្ស័យមួយចំនួនទាក់ទងទៅនឹងឯកសារនេះ។ ឯកសារនេះគឺជាឯកសារមានឈ្មោះថា“ទង់បដិវត្ត” ហើយថ្ងៃនេះគឺថាគាត់បានផ្ដល់សក្ខីកម្មថា ឯកសារបានបោះពុម្ពផ្សាយក្រោយឆ្នាំ១៩៧៥ គឺបោះពុម្ពជាអក្សរពុម្ព។ ដូច្នេះទង់បដិវត្ត ឬក៏ទង់ក្រហមនេះ គឺពីមុនឆ្នាំ១៩៧៥ គឺជាឯកសារដែលសរសេរដោយដៃ ឯក្រោយឆ្នាំ១៩៧៥ ជាឯកសារវាយពុម្ព បង្ហាញនូវយថាភាពរឹងមាំជាងឯកសារមុនហើយ។

[១២:២០:៥៧]

ហើយយើង ការទំនាស់តវ៉ាថាឯក-- គាត់បានលើកឡើងថាឯកសារនេះមានពណ៌ស ពណ៌ខ្មៅ ស-ខ្មៅ បែបនេះ។ ការជំទាស់បែបនេះ គឺថាជាការជំទាស់មួយមិនបានការទេ ដោយសារកូពីវាត្រូវតែ ស-ខ្មៅ ដូច្នេះឯង។ អ៊ីចឹងទាំងមេធាវីការពារក្ដី ក៏ដូចជាសហព្រះរាជអាជ្ញា គឺថាយើងចង់បាន បើសិនណាមេធាវីការពារក្ដីរបស់លោក នួន ជា ចង់បានឯកសារដែលមានអក្សរធំជាងនេះ ងាយស្រួលអាន យើងអាចធ្វើបែបនេះបាន។ ប៉ុន្តែលោក នួន ជា គាត់បានជំទាស់ចំពោះយថាភាពនៃឯកសារនេះ។

[១២:២១:៤៣]

ទាក់ទងទៅនឹងវិធីសាស្ត្រនៃការសួរដេញដោលនេះ ថាតើសាក្សី ឬក៏ជនជាប់ចោទត្រូវទៅសួរសាក្សី និងជនជាប់ចោទ ដោយល្បិចរបៀបណានោះ គឺថាវាជាសិទ្ធិរបស់ភាគីនីមួយៗទេ ឲ្យតែសំណួរ

នោះច្បាស់ ងាយស្រួល ខ្លី ទៅជាឯកសារមុនឆ្នាំ១៩៧៥ ឬក្រោយ៧៥ ដើម្បីសួរថាតើគោលនយោបាយរបស់បក្សនៅក្នុងឆ្នាំ១៩៦០នោះ វាយ៉ាងម៉េចដែរ? ដើម្បីឲ្យបានជ្រួតជ្រាបអំពីប្រវត្តិសាវតារ។ ហើយនៅក្នុងគោលបំណង ដោយសារថា ដើម្បីជួយឲ្យជនជាប់ចោទគាត់បានចងចាំទាក់ទងទៅនឹងឯកសារមួយចំនួន ទោះបីបោះពុម្ពផ្សាយក្រោយឆ្នាំ១៩៧៥ក្តី ឲ្យតែឯកសារនោះវាពាក់ព័ន្ធទៅនឹងអ្វី វាបានយល់ស្របគ្នា អនុម័តចេញនៅមុនឆ្នាំ-- នៅក្នុងអំឡុងទសវត្សរ៍១៩៦០។ នេះជាវិធីសាស្ត្រមួយសមស្រប ក្នុងការចោទសួរ លើកតាំងសួរសំណួរបែបនេះ ដើម្បីសួរជនជាប់ចោទហើយ។ ប៉ុន្តែបើមានការព្រួយបារម្ភណាមួយនោះ គឺថាគួរតែលោកពីខាងដើមទីមកផង។ តែខ្ញុំយល់ឃើញថា នេះជាសំណួរសមស្របបំផុតហើយ ប៉ុន្តែប្រហែលជាដោយសារថា ជនជាប់ចោទ គឺថាគាត់ភ្លេច និងមិនអាចឆ្លើយទៅនឹងសំណួរមួយចំនួនបាន។ សូមអរគុណលោកប្រធាន។

[១២:២៣:១០]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ឥឡូវដល់ពេល-- អីទៀតហើយ? មានបញ្ហាអីផ្សេងទេ?

**លោក អាង ឧត្តម៖**

បាទ, បញ្ហាផ្សេងណាទាន! ទាក់ទងរឿងវត្តមានលោក អៀង សារី។ ព្រឹកមិញលោកប្រធានបានអនុញ្ញាតឲ្យលោក អៀង សារី បានចូលរួមសវនាការពីចម្ងាយរួចហើយ។ ដោយសារថា ស្ថានភាពសុខភាពគាត់មិនទាន់បានធម្មតាធូរស្រាលឡើងវិញ ខ្ញុំបាទសូមអនុញ្ញាតលោកប្រធានមេត្តាអនុញ្ញាតឲ្យគាត់បន្តចូលរួមបន្តសវនាការពីចម្ងាយ ហើយដូចព្រឹកមិញតទៀត សម្រាប់ពេលល្ងាចនេះ។ ហើយពាក្យសុំសម្រាប់រយៈពេលមួយថ្ងៃនឹងធ្វើបែបនេះ យើងខ្ញុំបានដាក់ស្នើជូនមកតុលាការហើយ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អនុញ្ញាតតាមការស្នើសុំ។

ឥឡូវដល់ពេលសម្រាកហើយៗ ជិតកន្លះម៉ោងហើយលើស។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះរហូតទៅដល់ម៉ោងមួយ សាមសិបនាទី រសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តសវនាការ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំខាងក្រោម ហើយឲ្យនាំគាត់ទាំងពីររូប

នេះមកកាន់សាលសវនាការវិញនៅរសៀលវិញនេះ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទីជាកំណត់។

សូមសម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:២៥ នាទី ដល់ម៉ោង ១៣:៣៩ នាទី)*

[១៣:៣៩:០៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ពិភាក្សាដេញដោលលើភស្តុតាង។ នៅរសៀលនេះ អង្គជំនុំជម្រះនឹងដំណើរការស្តាប់បន្តការស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប ដែលអង្គជំនុំជម្រះបានស្តាប់ក្នុងអំឡុងពេលដំបូងៗនៃដំណើរការសវនាការលើសំណុំរឿង០០២ ដោយមិនទាន់ចប់ ដោយមូលហេតុបញ្ហាសុខភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប។

ក្រឡាបញ្ជី តើឥឡូវនេះមានវត្តមានដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបហើយឬនៅ? រម៉ាម យុន ហើយនិង ក្លាន វ៉ិត។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន ដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបដែលអង្គជំនុំជម្រះបានកោះហៅនោះ គឺគាត់មានវត្តមានហើយ គឺនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅរបស់អង្គជំនុំជម្រះ។

បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណលោក ផារី ។

មន្ត្រីតុលាការនាំដើមបណ្តឹងរដ្ឋប្បវេណី រម៉ាម យុន ចូលមកកាន់បន្ទប់សវនាការ។

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន! កូនក្តីខ្ញុំដោយពេលឥឡូវនេះ គាត់អស់កម្លាំងពេក ម្ល៉ោះហើយសូមសិទ្ធិសម្រាកនៅខាងក្រោមស្តាប់។ គាត់មិនអាចអង្គុយបានយូរ ព្រោះអីអស់កម្លាំងពេកឥឡូវនេះ។ បើ

អនុញ្ញាតខ្ញុំបាទធ្វើក្រដាសស្នាមសម្រាប់ជូនតុលាការហើយ។ សូមអរគុណ។

[១៣:៤២:២២]

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ នួន ជា តាមរយៈមេធាវីជាតិការពារក្តីរបស់គាត់ ស្នើសុំមិនចូលរួមផ្ទាល់នៅក្នុងសវនាការ នៅក្នុងបន្ទប់សវនាការនេះ ដោយសុំដកខ្លួនទៅបន្តតាមដាននូវដំណើរការសវនាការពីចម្ងាយនៅបន្ទប់ខាងក្រោម។ អង្គជំនុំជម្រះយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ ដែលបានស្នើសុំតាមរយៈមេធាវីរបស់គាត់។ តែក្រុមមេធាវីជនជាប់ចោទត្រូវប្រគល់ជូនមកអង្គជំនុំជម្រះនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការដោយចុះហត្ថលេខា និងផ្តិតមេដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ នួន ជា ផង។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទៅកាន់បន្ទប់ខាងក្រោម ដែលរៀបចំទុកជាសម្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទអាចចូលរួម និងតាមដានកិច្ចដំណើរការសវ-នាការពីចម្ងាយ។ បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អាចបន្តការតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

[១៣:៤៣:៥៩]

**ប្រធានអង្គជំនុំ៖**

សួស្តី លោក រម៉ាម យុន! នៅថ្ងៃនេះអង្គជំនុំជម្រះកោះហៅលោកមកបន្តនូវការផ្តល់សក្ខីកម្មតពីមុន ដោយសារពីមុនលោកមានបញ្ហាសុខភាពមិនអាចដំណើរការចប់ចុងចប់ដើម។ ហើយថ្ងៃនេះអង្គជំនុំជម្រះធ្វើការកោះហៅលោកសាជាថ្មីដើម្បីមកផ្តល់សក្ខីកម្ម ដើម្បីបញ្ចប់នូវកិច្ចដំណើរការសម្រាប់លោកក្នុងនាមលោកជាដើមបណ្តឹងរដ្ឋប្បវេណី។ ដោយតាមដំណើរការសវនាការកាលពីលើកមុន គឺភាគីដែលបានទទួលសិទ្ធិក្នុងការសួរដំបូងគេបង្អស់ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងបន្ទាប់មកគឺសហព្រះរាជអាជ្ញាបានធ្វើរួចហើយ ហើយជាកិច្ចបន្តនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាទៅមេធាវីការពារក្តីទាំងបីក្រុម ដោយចាប់ផ្តើមពីមេធាវីក្រុម នួន ជា មុនគេ នៅក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ហើយអង្គជំនុំជម្រះសូមជម្រាបថាមេធាវីសម្រាប់ក្រុមនីមួយៗហ្នឹងមានពេលវេលា២៥នាទី ក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្ប-វេណី។ សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណច្រើនលោកប្រធាន។ លោក រម៉ាម យុន ត្រូវបានស្តាប់សក្ខីកម្មក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី មិនមែនជាសក្សីនោះទេ។ ខ្ញុំកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់បានផ្តល់ភស្តុតាងអំពីព្យសនកម្មដែលបានកើតឡើងចំពោះខ្លួន។ ដូច្នេះការផ្តល់សក្ខីកម្ម និងភស្តុតាងនោះគឺវាជាសេចក្តីថ្លែងការណ៍នៅក្នុងតុលាការ។ ដូច្នេះហើយ សេចក្តីប្រកាសនេះមិនមានតម្លៃជាភស្តុតាងនោះទេ។ ជាពិសេស នៅក្នុងសេចក្តីប្រកាសរបស់លោក រម៉ាម យុន នៅក្នុងខែធ្នូ។ ដោយសារហេតុនេះហើយ យើងខ្ញុំមិនមានសំណួរណាមួយដែលត្រូវតាំងសួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនោះឡើយ។ សូមអរគុណ។

[១៣:៤៦:៤៧]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីនាំមុខ!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន! ការផ្តល់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះមិនមាន-- ក្នុងបំណងក្នុងការទទួលយកសំណង ហើយយើងគឺថាដើមបណ្តឹងរដ្ឋប្បវេណីនេះផ្តល់ព័ត៌មានដើម្បីរកឃើញការពិត ក៏ដូចជាភាគីផ្សេងទៀតផងដែរ។

ដូច្នេះក្នុងឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណី គឺថាការផ្តល់សក្ខីកម្ម ត្រូវតែបន្តធ្វើទៅទៀត។ ម្យ៉ាងទៀតអង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងសេចក្តី សម្រេចជាច្រើន ខ្ញុំមិនចាំលេខឯកសារនោះទេ គឺថាដើមបណ្តឹងរដ្ឋប្បវេណីគឺជាក្រុមរួម ហើយនិងមានឋានៈខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅរាល់ដំណើរការកិច្ចនីតិវិធី។

[១៣:៤៧:៤៧]

អ៊ីចឹងដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានស្តាប់ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយគោរពទៅតាមវិធាន ហើយអង្គជំនុំជម្រះមិនទាន់ដាក់លើកជាបញ្ហាទាក់ទងទៅនឹងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណីនេះនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! ឥឡូវនេះ មេធាវីក្រុម នួន ជា មិនមានសំណួរអីទេ។ ឥឡូវនេះអង្គជំនុំជម្រះសូម

ផ្តល់វេទិកាទៅមេធាវីការពារក្តីលោក អៀង សារី បើសិនជាសំណួរអីសួរដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សូមអញ្ជើញ។

**លោក អាង ឧត្តម៖**

សូមក្រាបថ្វាយបង្គំព្រះតេជព្រះគុណ ព្រះសង្ឃគ្រប់ព្រះអង្គ សូមគោរពលោកចៅក្រមប្រធាន សូមគោរពលោក លោកលោកស្រីចៅក្រម សមាជិកក្រុមប្រឹក្សាអង្គជំនុំជម្រះសាលាដំបូង សូមគោរពអង្គសវនាការ។

[១៣:៤៩:០២]

ខ្ញុំសូមចាប់ផ្តើមចំណុចស្រដៀងនឹងសហមេធាវីរបស់លោក នួន ជា ដែរ ហើយក៏ផ្អែកទៅលើការណែនាំ និងកំណត់សម្គាល់របស់លោកប្រធានកាលពីសវនាការលើកមុនថា យើងគួរតែចែកតួនាទីឲ្យដាច់ៗគ្នារវាងដើមបណ្តឹងរដ្ឋប្បវេណី រវាងសាក្សី ហើយនិងអ្នកជំនាញ។

កាលពីសវនាការលើកមុន យើងកត់សម្គាល់ឃើញថាដើមបណ្តឹងរដ្ឋប្បវេណីពីររូប យើងបានប្រើពេលវេលាច្រើនជ្រុលក្នុងការសួរសំណួរ។ យើងបានប្រើពេលច្រើនជ្រុល ដោយសារយើងប្រាសចាកពីគោលការណ៍ ពីក្រឹត្យក្រម។ ពីព្រោះថា ដើមបណ្តឹងរដ្ឋប្បវេណី ឬគេហៅថាជនរងគ្រោះមានមុខនាទីត្រឹមតែមកបង្ហាញភស្តុតាងដូចលោកប្រធានបានបញ្ជាក់ថា ជាភស្តុតាងបង្ហាញពីព្យសនកម្មពីភាពរងគ្រោះ ពីភាពអន្តរាយដែលដើមបណ្តឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះបានរងទទួលតែប៉ុណ្ណឹង។ ប៉ុន្តែ កន្លងមកដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានសួរចម្លើយច្រើនហួសពីក្រឹត្យក្រមនេះ ដែលធ្វើឲ្យខាតពេលវេលាតុលាការច្រើន។

[១៣:៥០:៤៧]

ដោយឡែក សាក្សី គឺមានតួនាទីបង្ហាញភស្តុតាងពីឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នានា រីឯអ្នកឯកទេស គឺមានមុខងារជួយបង្ហាញ បំភ្លឺផ្លូវតុលាការពីចំណុចជាក់លាក់ណាមួយ ដែលទាំងតុលាការទាំងភាគីនានាមិនអាចយល់ធ្លុះជ្រៅបាន។ ប៉ុន្តែខ្ញុំបាទ ដើម្បីឈរលើគោលការណ៍នេះដែរ ខ្ញុំបាទសុំឲ្យតុលាការកុំទទួលយក និងចាត់ទុកជាមោឃៈនូវសក្ខីកម្មទាំងឡាយដែលដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយពេលមុន ទាក់ទងរឿងទាំងឡាយដែលតាមពិត គឺសាក្សីទេដែលត្រូវឡើងអះអាង។

អ៊ីចឹងពេលនេះខ្ញុំសូមសួរសំណួរ ដែលត្រឹមតែទាក់ទងមិនស៊ីជម្រៅទៅលើអង្គហេតុ ប៉ុន្តែ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

អញ្ជើញមេធាវី មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុន។

ឲ្យមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមុន។

[១៣:៥២:៣៥]

**លោក ពេជ អង្គ៖**

បាទ, សូមគោរពលោកចៅក្រមប្រធាន លោក លោកស្រីចៅក្រម។ អស់លោក លោកស្រី មានវត្តមាននៅទីនេះ ព្រះសង្ឃដែលមានវត្តមាននៅទីនេះ និងបងប្អូនទាំងអស់។ ខ្ញុំក្នុងនាមជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាំងអស់គ្នាសូមជំទាស់ចំពោះការលើកឡើងរបស់លោកមេធាវីការពារជនជាប់ចោទ អៀង សារី ដោយសារការលើកអំពីចំណុចចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវគោលដៅ។ ដើមបណ្តឹងរដ្ឋប្បវេណីដូចវិធាន២៣ នៃវិធានផ្ទៃក្នុងបានលើកហើយ គឺដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងការគាំទ្រ ការចោទប្រកាន់ដោយលើកពីអង្គហេតុដែលខ្លួនបានទទួលរង ដែលអង្គហេតុទាំងអស់នោះអាចមានតម្លៃជាភស្តុតាងសម្រាប់បំភ្លឺការពិត។ ក្រៅពីនោះ ដើមបណ្តឹងរដ្ឋប្បវេណីក៏ចូលរួមផងដែរនៅក្នុងការទាមទារសំណង ដែលខ្លួនបានទទួលរងពីព្យសនកម្មដែលពាក់ព័ន្ធទៅនឹងអង្គហេតុ ដែលត្រូវបានទទួលស្គាល់ដោយតុលាការ។

ដូច្នេះ គឺជាអ្វីដែលជាគោលដៅនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយអង្គជំនុំជម្រះទៀតសោត ក៏បានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីលើកអំពីអង្គហេតុដែលពាក់ព័ន្ធនឹងរឿងក្តី ករណី ០០២/០១ នេះ ជាពិសេសផ្នែកដែលពាក់ព័ន្ធបឋមនេះ ដើម្បីបង្ហាញជូនតុលាការ។ ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិនៅក្នុងការនិយាយរហូតទៅដល់អង្គហេតុដែលខ្លួនបានទទួលរង ហើយនិងរឿង-- បញ្ហាទាំងឡាយណា អង្គហេតុទាំងឡាយណាដែលខ្លួនបានជួបប្រទះ ដឹង នៅក្នុង-- ពាក់ព័ន្ធនឹងរឿងក្តីដែលយើងកំពុងតែពិនិត្យនេះ។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិនិយាយទាំងបញ្ហាអង្គហេតុ និងបញ្ហាដែលពាក់ព័ន្ធទៅនឹងព្យសនកម្មដែលខ្លួនបានទទួលរងផងដែរ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញសហព្រះរាជអាជ្ញា។

[១៣:៥៤:៤៥]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធានសូមអរគុណ។ ទិវាសួស្តី ខ្ញុំនឹងនិយាយដោយខ្លីៗ គឺថា ពេលនេះជាពេលដែលខាងភាគីការពារក្តីចោទសំណួរនោះទេ មិនមែនជាពេលដែលគាត់ត្រូវផ្តល់យោបល់លើលទ្ធភាពដែលថាសមត្ថភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនោះទេ គឺថាបញ្ហានេះយើងបានពិភាក្សា ហើយនិងបានសម្រេចដោយអង្គជំនុំជម្រះរួចហើយ។ ដូច្នេះ មិនត្រូវត្រឡប់មកនិយាយអំពីបញ្ហានេះនៅថ្ងៃនេះទៀតទេ។ អ៊ីចឹងក៏មិនមែនជាខាងភាគីការពារក្តីដែលសម្រេចថានេះការខាតពេលវេលា ឬក៏ចោទសំណួរទៅជនរងគ្រោះដែលមកទីនេះដើម្បីផ្តល់សក្ខីកម្មនោះទេ។ ហើយក៏មិនមែនជាតួនាទីរបស់ភាគីការពារក្តីដែលលើកឡើងថាអង្គជំនុំជម្រះមិនត្រូវយកដើមបណ្តឹងរដ្ឋប្បវេណីមកចោទសំណួរផ្តល់សក្ខីកម្មនោះទេ។ អ៊ីចឹង ជាការល្មើសមួយដែលគួរឲ្យកត់សម្គាល់ ហើយនិងពាក់ព័ន្ធទៅនឹងជនរងគ្រោះ។ អ៊ីចឹងខ្ញុំគិតថា មិនអាចទទួលយកបានទេ អាកប្បកិរិយាបែបនេះ។

[១៣:៥៥:៥១]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ហើយមេធាវីយើងសួរផ្តល់វេទិកាទៅមេធាវី ដើម្បីមានឱកាសនៅក្នុងការសួរសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ នេះជាវេទិកាដែលអង្គជំនុំជម្រះផ្តល់ឲ្យលោក ប្រសិនបើលោកអត់មានទេ លោកប្រាប់យើងឲ្យច្បាស់លាស់ ដើម្បីយើងប្រគល់វេទិកាបន្តទៅក្រុមមេធាវីដទៃទៀត។ ដើម្បីបន្តកុំឲ្យមាត់លោកថា ចំណាយពេលវេលាឥតប្រយោជន៍ ប៉ុន្តែលោកបែរជាចំណាយប្រឹងប្រែងពន្យារពេលវេលាក្នុងការនិយាយអ្វីដែលវាមិនចូលជាសាច់ការ។ តាមអ្វីដែលយើងបានផ្តល់វេទិកាឲ្យលោកគ្មានក៏គ្មានទៅ។ បង្ហាញឲ្យច្បាស់លាស់តែម្តង ដើម្បីឲ្យយើងបន្តវេទិកាទៅ ក្រុមមេធាវីផ្សេងទៀត។

**លោក អាង ឧត្តម៖**

សូមអរគុណហើយ។ សូមអភ័យទោសលោកប្រធាន ខ្ញុំបាទលើកនេះគ្រាន់តែជាការកត់សម្គាល់បឋម ពីព្រោះផ្អែកតែទៅលើ--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ-- ឥឡូវសូមអញ្ជើញមានសំណួរ ឬអត់ឥឡូវនេះ?

**លោក អាង ឧត្តម៖**

មួយ ដែលផ្អែកទៅលើឯកសារ D208/2 នៅក្នុងលេខ ERN00380956 ដោយហេតុថា ខ្ញុំមិនបានដឹងថា ដើមបណ្ដឹងរដ្ឋប្បវេណីពេលនេះ គាត់ចេះអាន ឬចេះសរសេរភាសាខ្មែរច្បាស់។ អ៊ីចឹងខ្ញុំសូមឲ្យលោកប្រធានចាត់ឲ្យមានការអានឯកសារនេះនៅលេខ ERN ដែលបានជម្រាបអំមិញនេះ។ ហើយខ្ញុំបាទនឹងសួរលោក រម៉ាម យុន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោក រម៉ាម យុន អាចអានអក្សរខ្មែរបានទេ?

**លោក រម៉ាម យុន៖**

វាភ្លេចខ្លះ ចាំខ្លះអ៊ីចឹង។ ខ្ញុំគោរពម៉ែឪ បងប្អូនទាំងអស់ យើងថ្ងៃនេះ ដើម្បីយើងរាយការណ៍ការងារយើងពីដើម។

**ប្រធានអង្គជំនុំ៖**

អ៊ំយើងសួរថាតើចេះអានទេ អក្សរខ្មែរនៅចំពោះមុខលោកនោះទេ?

**លោក រម៉ាម យុន៖**

បាទ។

[១៣:៥៩:០១]

**លោក ញ៉ែម សំណាង៖**

អ៊ំអាចអានបានទេ អ៊ំ?

**លោក រម៉ាម យុន៖**

អត់។

**ប្រធានអង្គជំនុំ៖**

បើអានមិនបានទេ អង្គជំនុំជម្រះចាត់ឲ្យក្រឡាបញ្ជីលោក ឌុច ផារី អានទូវឯកសារដែលមេធាវីការពារក្ដីស្នើសុំឲ្យអាន ហើយលោក រម៉ាម យុន ចាំ រង់ចាំស្ដាប់នូវការអានរបស់លោកក្រឡាបញ្ជី។ ក្រឡាបញ្ជីសូមអានឲ្យបានយឺតៗ។

**ក្រឡាបញ្ជី៖**

ទោះបីកិច្ចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី រម៉ាម យុន ត្រូវបានធ្វើចប់សព្វគ្រប់ក៏ដោយក្ដី

យើងកត់សម្គាល់ឃើញថា ការឆ្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីហាក់ដូចជាពុំសូវដឹងច្បាស់លើព័ត៌មាននៅក្នុងពាក្យបណ្តឹងរបស់ខ្លួន។ ហើយពេលខ្លះអង្គហេតុតែមួយមានព័ត៌មានខុសគ្នា ដែលហេតុផលនេះកំណត់ឲ្យយើងពិបាកក្នុងការជឿជាក់ ឬក៏ទុកចិត្តចំពោះព័ត៌មានរបស់ដើមបណ្តឹង។ ទោះបីជាបេសកកម្មដែលនៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសដោយមានយោងខាងលើ មិនត្រូវបានអនុវត្តចប់ពេញលេញនិងភាគីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ក្លាន រ៉ិត មិនអាចត្រូវបានរកឃើញក៏ដោយ ក៏យើងអាចសន្និដ្ឋានបានថា មកដល់ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៩ ដីកាចាត់ឲ្យស៊ើបសួរជំនួសខាងលើត្រូវប្រកាសបិទ។

**លោក អាង ឧត្តម៖**

សូមអនុញ្ញាតបញ្ចប់ត្រឹមហ្នឹងបានទាន!

**ប្រធានអង្គជំនុំ៖**

បានហើយ អង្គុយចុះ!

[១៤:០១:១៩]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក អាង ឧត្តម៖**

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោក រម៉ាម យុន ថាឃ្លាទីមួយ លោកបានស្តាប់ ហើយលោកបានយល់ទេ?

**លោក រម៉ាម យុន៖**

**ឆ៖** បាទ, ខ្ញុំយល់ខ្លះដែរ។ ស្តាប់ទៅដូចវាមិនច្បាស់ដែរ ពេលណាច្បាស់ៗទៅ តែកន្លែងណាក៏មិនច្បាស់ វាអ៊ីចឹង។ អានេះសូមគោរពបងប្អូនម៉ែឪទាំងអស់។ ថ្ងៃនេះយើងឆ្លៀតឱកាសអារឿងរ៉ាវយើងតាំងពីដើមមក រាយការណ៍ទាំងពីដើម។

**លោក ញ៉ែម សំណាង៖**

មេធាវីសួរសំណួរ។

**លោក រម៉ាម យុន៖**

បាទ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យពី១៧ មេសា ១៩៧៥ ដល់៦ មករា ១៩៧៩ លោកត្រូវ

បានតែងតាំងជាអនុលេខាតំបន់ មែនទេ?

**លោក វ៉ាម យុន៖**

**ឆ៖** បាទ។

**ស៖** លោកធ្លាប់បានបញ្ជូនមកភ្នំពេញប៉ុន្មានដងក្នុងកំឡុងពេលនោះ?

**ឆ៖** បាទ, កាលពីពេលនោះ ពីដើមបានទៅភ្នំពេញ ទៅរឿងការគេប្រជុំសន្និបាតធំ អញ្ជើញទៅរួមជាមួយគេអ៊ីចឹង អានោះមួយដង មានតែចំនួនមួយដងហ្នឹងហើយ។

**ស៖** សូមបញ្ជាក់ អ៊ីចឹងលោកមានប្រសាសន៍ថាបានមកទីក្រុងភ្នំពេញតែម្តងគត់។ តើមែនទេ?

**ឆ៖** ទៅប្រជុំភ្នំពេញហ្នឹងហ៎?

**ស៖** តែម្តងគត់មែនទេ?

**ឆ៖** បាទ, ម្តងគាត់ហ្នឹង។

[១៤:០៣:៥៤]

**ស៖** ម្តងនោះ តើលោកចាំកាលបរិច្ឆេទ។ ខ្ញុំចង់និយាយថាថ្ងៃខែឆ្នាំនៃការមកកាន់ភ្នំពេញទេ? ចាំទេ?

**ឆ៖** អត់ចាំផង ពីព្រោះវាច្របូកច្របល់ទៅ យូរទៅភ្លេចៗ ភ្នែកឃើញ ត្រចៀកវាអត់ចាំ។ ការងារគេ អាន៎ុងវាមានគេហៅប្រជុំអប់រំឃោសនា ហើយនិងដឹងក្រិត្យក្រមធំដុំ ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** សូមអរគុណ។ ខ្ញុំសូមលោកប្រធានមេត្តាអនុញ្ញាតឲ្យមានការអានឯកសារD22/43 លេខ ERN00279550 ចាប់ផ្តើមពីកថាខណ្ឌ ត្រឹមតែកថាខណ្ឌទីពីរប៉ុណ្ណោះ។ ចប់ត្រឹមខណ្ឌទីមួយ សូមអរគុណ។

[១៤:០៥:៥៦]

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការបញ្ចាំងឯកសារលើអេក្រង់ទូរទស្សន៍!

**លោក អាង ឧត្តម៖**

ឬក៏អានក៏បានលោកប្រធាន ដូចមុន។

**ប្រធានអង្គជំនុំ៖**

ផារី រកឃើញឬនៅ? អានៗអញ្ជើញអានទូរទំព័រលេខ ERN00279550 ត្រង់កថាខណ្ឌទីពីរ។

**ក្រឡាបញ្ជី៖**

ខែកញ្ញា ឆ្នាំ១៩៧៨។ រូបខ្ញុំត្រូវបានប្រធានប្រចាំភូមិភាគឦសានឈ្មោះ យ៉ា បានចាត់ឲ្យទៅកាន់ភ្នំពេញរួមដំណើរជាមួយមិត្ត ក្លាន រ៉ិត រស់នៅភូមិអ៊ិន ឃុំតាឡាវ ស្រុកអណ្ដូងមាស ខេត្តរតនគីរី ដែលមានឋានៈជាអនុលេខាប្រចាំស្រុកអណ្ដូងមាស បានធ្វើដំណើរតាមកាណូត ចេញពីស្រុកវ៉ឺនសៃ ខេត្តរតនគីរី ឆ្ពោះទៅកាន់ខេត្តស្ទឹងត្រែង ព្រោះនៅមានមិត្ត៦នាក់ទៀតកំពុងរង់ចាំខ្ញុំនៅទីនោះ។ មិត្តទីមួយឈ្មោះមិត្ត ភុង ជនជាតិព្រៅ មានស្រុកកំណើតនៅឃុំកាចាញ ស្រុកបានលុង ខេត្តរតនគីរី។ ឯមិត្តទីពីរឈ្មោះមិត្តផា ជនជាតិឡាវ ជាគណៈស្រុកស្រែគរ ខេត្តស្ទឹងត្រែង។ ទីបី ឈ្មោះមិត្ត យ៉ង ជនជាតិលន់ ជាគណៈស្រុកសៀមប៉ាង។ ទីបួន ឈ្មោះមិត្តប៉យ ជាគណៈស្រុក២១ ស្រុកវ៉ឺនសៃ។ ទីប្រាំ មិត្តវ៉ន ជាអនុប្រធានតំបន់ស្ទឹងត្រែងខេត្តស្ទឹងត្រែង និងមិត្តពីរនាក់ទៀតឈ្មោះ មិត្តយ៉ង់ មិត្តឆុម ។ ក្មេងងារក្នុងសម័យខ្មែរក្រហម ព្រមទាំងមានការជូនដំណឹងដោយតាខេង ជាប្រធានកងភូមិភាគឦសាន និងងារមួយទៀតជាប្រធានភូមិភាគឦសាន និងអង្គរក្សម្នាក់ទៀត ឈ្មោះ មាន ប្រដាប់ដោយកាំភ្លើងអាកាបត់មួយដើម និងអ្នកបើកកាណូតចំនួនពីរនាក់មិនស្គាល់ឈ្មោះ រួចក៏បើកឆ្ពោះទៅកាន់ទីក្រុងភ្នំពេញពីរយប់ពីរថ្ងៃទើបទៅដល់ទីក្រុងភ្នំពេញ។

[១៤:០៩:៣៨]

**ប្រធានអង្គជំនុំ៖**

អរគុណ។ អង្គុយចុះ!

[១៤:០៩:៥៥]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ខ្ញុំសូម-- សូមទោស។ លោក រម៉ាម យុន លោកបានស្ដាប់ឮលោកក្រឡាបញ្ជីបានអានសេចក្ដីថ្លែងរបស់លោកថា នៅខែកញ្ញា ឆ្នាំ១៩៧៨ រូបលោកត្រូវប្រធានប្រចាំភូមិភាគឦសាន ឈ្មោះ យ៉ា ចាត់ឲ្យទៅភ្នំពេញ។ តើលោកទទួលស្គាល់ថា នៅខែកញ្ញា ឆ្នាំ៧៨ ហ្នឹងលោកត្រូវបានចាត់ឲ្យមកភ្នំពេញមែនឬទេ?

**ឆ៖** បាទ កាលហ្នឹងហើយខ្ញុំ--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកសហព្រះរាជអាជ្ញា!

[១៤:១០:៥០]

**លោក វាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

លោកប្រធាន នៅក្នុងការផ្ដល់សក្ខីកម្មរបស់លោក រម៉ាម យុន នេះ ដើមបណ្ដឹងរដ្ឋប្បវេណីក៏ដូចជានឹងសហព្រះរាជអាជ្ញា ថាបានទទួលការបង្គាប់របស់អង្គជំនុំជម្រះថា មិនត្រូវចោទសំណួរនៅក្នុងរយៈពេលនេះទេ។ នេះគឺជា-- នេះគឺថាវាទាក់ទងទៅនឹងដំណាក់កាលបោសសម្អាត។ អ៊ីចឹងខ្ញុំមិនយល់ទេ ថាហេតុអ្វីបានភាគីការពារក្ដីចោទសំណួរទាក់ទងទៅនឹងបញ្ហាបោសសម្អាតនៅឆ្នាំ៧៨ នេះ? អ៊ីចឹង ក្រុមខាងភាគីការពារក្ដីនេះ តែងជំទាស់មិនឲ្យចោទសំណួរទាក់ទងទៅនឹងមូលហេតុដែលថាពួកអ្នកដែលគេបញ្ជូនមកភ្នំពេញនេះ។ អ៊ីចឹង ខ្ញុំមិនដឹងពីរបៀបចោទសំណួររបស់គាត់នេះទេ។

[១៤:១១:៤៨]

**លោក អាង ឧត្តម៖**

សូមអរគុណ។ សូមជម្រាប សូមបញ្ជាក់ថា ខ្ញុំបាទគ្រាន់តែចង់ទាញពីកាលបរិច្ឆេទពីការមកភ្នំពេញរបស់គាត់ទេ។ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់ថា ត្រូវចប់ត្រឹមណា ខ្ញុំសូមប្រាកដយកខណ្ឌទីមួយតែប៉ុណ្ណឹង។ ខ្ញុំអត់ចូលជ្រៅជាងហ្នឹងទេ ហើយបើខ្ញុំសួរសំណួរផ្សេងទៀត។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** លោក រម៉ាន យុន លោកថា ប្រធានភូមិភាគឈ្មោះ យ៉ា ចាត់ឲ្យលោកមកកាន់ភ្នំពេញ។ ឈ្មោះ យ៉ា នេះជាឈ្មោះបដិវត្តន៍ ឬក៏មិនមែន?

**លោក រម៉ាម យុន៖**

**ឆ៖** កាលហ្នឹង ខ្ញុំក៏មិនដឹងដែរ។

**ស៖** បាទ, សូមអរគុណ។ ហើយលោកស្គាល់ឈ្មោះផ្លូវការរបស់គាត់ទេ អ៊ំ?

**លោក ញ៉ែម សំណាង៖**

អញ្ជើញៗ!

**លោក រម៉ាម យុន៖**

**ឆ៖** បើយើងមិនស្គាល់ម៉េច យើងជា-- គាត់ យើងស្គាល់ យើងស្គាល់មុខមាត់ហ្នឹងហើយ។

**លោក អាង ឧត្តម៖**

សូមអរគុណ។ មុននឹងបញ្ចប់សំណួរខ្ញុំសូមលោកប្រធានអនុញ្ញាតអាន ឲ្យមានការអានឯកសារ

D22/43.2 ទាំងមូល ទាំងស្រុងតែម្តង។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការបង្ហាញឯកសារនៅលើអេក្រង់ទូរទស្សន៍ D22/43.2។

លោក ផារី រកឃើញហើយឬនៅ? បើបានឃើញហើយ សូមអញ្ជើញលោក ផារី អានទូវឯកសារទាំងស្រុងតាមសំណើសុំរបស់មេធាវីការពារក្តី។

[១៤:១៤:១៧]

**ក្រឡាបញ្ជី៖**

ជូនចំពោះអង្គភាពជនរងគ្រោះ។ ព័ត៌មានបន្ថែមពីជនរងគ្រោះ។ ឈ្មោះ រម៉ាម យុន ហៅ ខាំ ភី។

**ប្រធានអង្គជំនុំ៖**

បើកៗក្បាលមេគ្រូ!

**លោក អាង ឧត្តម៖**

លេខ ERN គឺ 00279543 លេខ D លេខឯកសារ D22/43.2។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៤:១៥:១៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន បើខ្ញុំសូមកត់សម្គាល់ដូចសហព្រះរាជអាជ្ញាអ៊ីចឹង គឺថាយើងចេញពីក្របខ័ណ្ឌនៃការជម្រះសេចក្តីនេះ គឺថាឯកសារនេះទាក់ទងទៅនឹងការបោសសម្អាត។ អ៊ីចឹងយើងមិនអាចចោទសំណួរលើចំណុចនេះបានទេ។

**ប្រធានអង្គជំនុំ៖**

ការសួរដេញដោលនេះដូចជាទំនងមិនដល់អង្គហេតុនៃការបោសសម្អាតទេ។ នេះការបង្ហាញនូវភាពត្រឹមត្រូវ ឬមិនត្រូវនៃកិច្ចដំណើរការពីព្រោះការសួររបៀបឆ្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ធៀបជាមួយនឹងឯកសារនៅក្នុងសំណុំរឿង ឃើញថា វាមានការឃ្លាតគ្នាឆ្ងាយ។ អ៊ីចឹងចង់បញ្ជាក់អំពីបញ្ហានេះឲ្យបានច្បាស់លាស់លើខ្លឹមសារនៃឯកសារ និងការដែលជួបផ្ទាល់មាត់នេះ ថាតើវាមានតម្លៃយ៉ាងដូចម្តេចទៅនៅចំពោះមុខអង្គជំនុំជម្រះនោះ? ដូច្នេះជំទាស់នេះគ្មានប្រសិទ្ធភាព។

ក្រឡាបញ្ជីអាននូវចំណុចឯកសារD22/43.2 ហើយត្រង់លេខERNជាភាសាខ្មែរ 00279543។

[១៤:១៦:៣០]

**ក្រឡាបញ្ជី៖**

ព័ត៌មានបន្ថែមទាក់ទងនឹងករណី ០០១/១៨.៧.២០០៧-អ.វ.ត.ក-ក.ស.ច.ប/អ.ប.ដ។ ដើមឆ្នាំ ១៩៧៩ ខ្មែរក្រហមចាប់មិត្តភក្តិស្គាល់គ្នាពេលប្រជុំកម្មាភិបាលខ្មែរក្រហមចំនួន១០នាក់ ពីស្ទឹងត្រែងទៅភ្នំពេញ។

១. រម៉ាម យុន ខ្លួនខ្ញុំផ្ទាល់ អនុតំបន់ស្រុកវើនសៃ។

២. ក្លាន រ៉ិត អនុស្រុក២១ ស្រុកអណ្តូងមាស។

៣. ភុង អនុតំបន់១៥ ស្រុកលំផាត់។

៤. ជា ឬ ផា ជនជាតិលាវ លេខាស្រុកស្នួរ ខេត្តស្ទឹងត្រែង។

៥. ប៉យ លេខាស្រុក២០។

៦. ប៉ឿន លេខាស្រុក២២។

៧. យ៉ុំ លេខាស្រុក សៀមប៉ាង។

៨. ឈុំ ប្រធានទាហានភូមិភាគឦសាន។

៩. ថាវន ជនជាតិលាវ អនុតំបន់ស្ទឹងត្រែង។

១០. សុវណ្ណ អនុស្រុកសៀមបាង។

[១៤:១៨:២៧]

ទៅដល់ភ្នំពេញ ខ្មែរក្រហមយកខ្ញុំទៅដាក់ផ្ទះមួយ មានរូបថតស្តេច ផែនទីប្រទេសផ្សេងៗ និងមានសុទ្ធតែកញ្ចក់ប្រហែលមួយខែ។ ខ្មែរក្រហមបានសួរពីប្រវត្តិរូបខ្ញុំម្នាក់ម្តងៗ ហើយឲ្យធ្វើស្លួនដាំដំឡូង។ មួយខែក្រោយមក គេបំបែកខ្លួនខ្ញុំមួយនាក់ ក្លាន រ៉ិត, រម៉ាម យុន, ភុង, ជា ទៅវត្តស្លែង មន្ទីរអប់រំ។ ចំណែកមិត្តភក្តិខ្ញុំប្រាំមួយនាក់ ត្រូវខ្មែរក្រហមចាប់យកទៅគុកទួលស្លែង ហើយបាត់ដំណឹងរហូត។ ខ្ញុំសូមប្តឹងពីការបាត់ខ្លួនរបស់មិត្តខ្ញុំប្រាំមួយនាក់នេះ។ រតនគីរី ថ្ងៃទី២០ ខែសីហា ២០០៨។ ស្នាមមេដៃ រម៉ាម យុន។

**ប្រធានអង្គជំនុំ៖**

អរគុណលោក ផារី។ អង្គុយចុះ!

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ខ្ញុំសូមសួរលោក រម៉ាម យុន លោកបានមានប្រសាសន៍ថាលោកបានមកភ្នំពេញតែម្តងគត់ ក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ តើការមកភ្នំពេញនោះ នៅខែកញ្ញា ឆ្នាំ១៩៧៨ ឬនៅដើមឆ្នាំ ១៩៧៩? សូមលោកឆ្លើយ។

**លោក រម៉ាម យុន៖**

**ឆ៖** រឿងហ្នឹងខ្ញុំ (សូមទោស) ថ្ងៃខែ ខ្ញុំវាអត់ចាំៗទេ។ ប៉ុន្តែតែនៅនុ៎ង ទៅនុ៎ងទៅ ខែអី ឆ្នាំអី ក៏ អត់ចាំ។

**ស៖** បាទ, សូមអរគុណ។ សូមលោកបញ្ជាក់ថា លោកបានមកភ្នំពេញតែម្តងគត់ មែនទេ?

**ឆ៖** បាទ។ ទៅម្តង។

**ស៖** សូមអរគុណ។ ម្តងដែលលោកមកហ្នឹង មិនដឹងជាថ្ងៃ (សុំទោស) មិនដឹងជានៅខែកញ្ញា ឆ្នាំ១៩៧៨ ឬក៏នៅដើមឆ្នាំ១៩៧៩ ទេ លោកមិនច្បាស់ថាមួយណាទេ មែនទេ?

**ឆ៖** អត់ស្គាល់ អត់ចងចាំផង។

**ស៖** សូមអរគុណ។

[១៤:២១:៤៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី។ ទទួលសិទ្ធិទេនុ៎ង មេធាវីហ្នឹងម៉េចទៅ? អ្នកណាប្រគល់សិទ្ធិ?

**លោក ពេជ អង្គ៖**

សូមលោកប្រធានអនុញ្ញាតឲ្យ បាណាបេ ណេគ្វី មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីធ្វើបទ អន្តរាគមន៍សូមលោកប្រធានអនុញ្ញាត។

[១៤:២២:១២]

**ប្រធានអង្គជំនុំ៖**

អនុញ្ញាតនៅក្នុងក្របខ័ណ្ឌជំទាស់ទៅនឹងសំណួរ មិនអនុញ្ញាតឲ្យធ្វើអត្ថាធិប្បាយបែបណាមួយ ដែលក្រៅពីពាក់ព័ន្ធនឹងសំណួរទេ។ ការតាំងសំណួររបស់ភាគីមួយ ភាគីមួយទៀតមានសិទ្ធិត្រឹមតែកត់

ជំទាស់នៅក្នុងការសួរប៉ុណ្ណោះ។ ចំណែកឯការសម្រេចនៅលើអង្គជំនុំជម្រះជាអ្នកសម្រេចជំទាស់មានប្រសិទ្ធភាព ឬគ្មានប្រសិទ្ធភាព? ឲ្យឆ្លើយ ឬមិនឲ្យឆ្លើយទៅនឹងសំណួរដែលសួរ។ ចំណែកឯការកត់សម្គាល់ផ្សេងពីនេះ មិនអនុញ្ញាតឡើយ។

[១៤:២២:៤៧]

**លោក បាណាបេ ណេគ្វី៖**

បាទ លោកប្រធាន ខ្ញុំសូមអរគុណ។ ខ្ញុំសូមគោរពដល់អង្គជំនុំជម្រះ និងភាគីការពារក្តីទាំងអស់ ខ្ញុំឡើងមកនិយាយនេះគឺថាក្នុងបំណងធ្វើការជំទាស់លើការ របៀបសួររបស់ភាគីការពារក្តីរបស់លោក អៀង សារី។

ខ្ញុំហាក់ដូចជាយល់ឃើញថា នៅពេលដែលស្តាប់គាត់ចោទសំណួរនោះ ហើយនៅពេលដែលគាត់បង្ហាញឯកសារមកដើមបណ្តឹងរដ្ឋប្បវេណីដែលយើងជាអ្នកការពារហ្នឹង យើងមេធាវីគ្មានព្រំដែននោះ។ យើងយល់ឃើញថា ការ-- គោលបំណងរបស់គាត់ធ្វើយ៉ាងណាកុំឲ្យ-- បំបាត់តម្លៃរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក៏ប៉ុន្តែខ្ញុំយល់ឃើញថាមធ្យោបាយរបស់គាត់ដែលគាត់ប្រើហ្នឹងគឺថាពុំមានប្រយោជន៍អីទេ ពីព្រោះថាមេធាវីរបស់លោក អៀង សារី ខំឆ្លៀតយកប្រយោជន៍ពីការបាត់បង់ការចងចាំរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្ញុំ។

អ៊ីចឹងសូមលោក គឹម ម៉េងឃី បានបញ្ជាក់ហើយថា ដើមបណ្តឹងរដ្ឋប្បវេណីនេះគឺថា គាត់ចាស់ហើយនិងរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង។ អ៊ីចឹងឬក៏ថាគាត់បាត់ការចងចាំច្រើន ហើយអ៊ីចឹងបានន័យថា ការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនេះ ជាការលំបាកណាស់។ នេះអ៊ីចឹងគឺថាមេធាវីរបស់លោក អៀង សារី ហ្នឹងបានបង្ហាញមកហើយពីលើកមុននោះ លើសភាពសុខភាពរបស់លោក រម៉ាម យុន។ អ៊ីចឹង ខ្ញុំគិតថាគួរតែទទួលស្គាល់ថាគាត់បាត់ការចងចាំអស់ទៅហើយ អ៊ីចឹងគឺថាមិនមានប្រយោជន៍អីទេក្នុងការលើកឡើង ដើម្បីបំបាត់តម្លៃរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ។

អ៊ីចឹងសូមឲ្យអង្គជំនុំជម្រះ សូមអញ្ជើញឲ្យមេធាវីខាង អៀង សារី នេះប្រើមធ្យោបាយចោទសំណួរផ្សេងទៅវិញទៅ។ នេះជាការជំទាស់របស់ខ្ញុំ។

[១៤:២៥:០៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៥:៣៩]

**ប្រធានអង្គជំនុំ៖**

ការជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋវេណីគ្មានប្រសិទ្ធភាពទេ។ មេធាវីការពារជនជាប់ចោទអាចបន្តសួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។

អង្គជំនុំជម្រះសូមជម្រាបភាគី និងសាធារណជនថា ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ គឺអង្គជំនុំជម្រះបានដកស្រង់យកចេញពីបញ្ជីឈ្មោះ ដើមបណ្ដឹងរដ្ឋប្បវេណីដែលមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់បញ្ជីឈ្មោះស្នើសុំឱ្យអង្គជំនុំជម្រះកោះហៅមកស្ដាប់សក្ខីកម្ម។ ដូច្នេះ ជាការជ្រើសរើសរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីចំពោះអ្នកដែលមានគុណសម្បត្តិស័ក្ដិសមក្នុងការផ្ដល់សក្ខីកម្មនេះរួចហើយ។

សូមអញ្ជើញ!

[១៤:២៦:៣៧]

**លោក អាង ឧត្ដម៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមសួរលោក រម៉ាម យុន ទាក់ទងនឹងឯកសារ D22/43.2 ដដែល។

**សួរដោយលោក អាង ឧត្ដម៖**

**ស៖** លោក រម៉ាម យុន លោកអះអាងនៅក្នុងឯកសារទាំងនេះថា នៅដើមឆ្នាំ១៩៧៩ ខ្មែរក្រហមបានចាប់រូបលោក និងមិត្តភ័ក្ដិចំនួន មួយចំនួនទៀត ១០នាក់នេះ មកភ្នំពេញ មែនទេ?

**ឆ៖** មែនតើ។

**ស៖** ទៅដល់ភ្នំពេញលោកបានមានប្រសាសន៍ទៀតថា ខ្មែរក្រហមបានយកទៅដាក់នៅក្នុងផ្ទះមួយមានរូបថតស្ដេច ផែនទីប្រទេសផ្សេងៗ និងមានសុទ្ធតែកញ្ចក់ ប្រហែលមួយខែ។ អ៊ីចឹងមែនទេ?

**លោក ញ៉ែម សំណាង៖**

អ៊ំឆ្លើយម្ដងទៀត អ៊ំអញ្ជើញឆ្លើយ។

**លោក រម៉ាម យុន៖**

**ឆ៖** មែនតើ។

**ស៖** នៅទីនោះ ខ្មែរក្រហមបានសួរពីប្រវត្តិរូបលោក និងមិត្តភ័ក្ដិម្ដងម្នាក់។ មែនទេ?

**ឆ៖** មែនហើយ។

**ស៖** សូមអរគុណ។ មួយខែក្រោយមក គេបំបែកលោក និងមិត្តភ័ក្តិពីគ្នា មែនទេ?

**ឆ៖** បាទ។

[១៤:២៨:២៨]

**ស៖** មានមួយចំនួន បានគេយកទៅវត្តស្លែង មួយចំនួនទៀត គេចាប់យកទៅគុកទួលស្លែង តើមែនទេ?

**ឆ៖** មែនតើ។ វាពិតអ៊ីចឹងហើយ។

**ស៖** អ៊ីចឹងព្រឹត្តិការណ៍នេះពិតជាបានកើតបន្តបន្ទាប់គ្នា បើគិតទៅតាមសម្ដីលោកថា ដើមឆ្នាំ៧៩ មកនៅភ្នំពេញមួយខែ បន្ទាប់ពីមួយខែហើយមួយខែទៀត គេបំបែកពួកលោក ហើយនិងអ្នកខ្លះបញ្ជូនទៅទួលស្លែង។ អ៊ីចឹងមែនទេ?

**ឆ៖** មែន។

**លោក អាង ឧត្តម៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទអស់សំណួរហើយ។ សូមអរគុណ។

[១៤:២៩:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្ដីឲ្យលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ប្រសិនបើមានសំណួរ ហើយសូមរំឭកចៀសវាងក្នុងការសួរច្រំដែល ហើយគប្បីសួរសំណួរខ្លីៗ ដើម្បីឲ្យងាយយល់ ហើយដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះងាយយល់ និងអាចឆ្លើយតបវិញបាន។ សូមអញ្ជើញ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ។ ខ្ញុំបាទអត់មានសំណួរសួរទៅលើសាក្សី រម៉ាម យុន នេះទេ។ បាទអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ឥឡូវនេះ តើអស់លោក លោកស្រីចៅក្រមមានសំណួរអ្វីសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះដែរឬទេ? សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

[១៤:៣០:៤៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោក រម៉ាម យុន។ សួរស្តី ខ្ញុំឈ្មោះចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ខ្ញុំជាចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង។ ខ្ញុំចង់ឲ្យលោកជម្រាបយើងទាំងអស់គ្នាថា តើថ្ងៃ១៧ មេសា ឆ្នាំ៧៥ហ្នឹងគឺមានជាថ្ងៃអីកាលបរិច្ឆេទអីច្បាស់លាស់ទេលោក? តើលោកដឹងទេ ថានៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ហ្នឹងមានព្រឹត្តិការណ៍អីកើតឡើង?

**លោក រម៉ាម យុន៖**

**ឆ៖** ភ្លាំងហើយវាយូរភ្លេចទៅៗ ព្រោះគេរំឭកឃើញ បើមិនឮគេរំឭកដូចវាស្ងាត់តែម្តង វាអត់ចេញគិតទេណាអ៊ីចឹង។

**ស៖** តើលោកដឹងទេថា ថ្ងៃនេះយើងជាថ្ងៃអីដែរ?

**ឆ៖** ថ្ងៃនេះ អត់ដឹងផង។ ថ្ងៃអីទេ អត់ដឹង។

**ស៖** លោក រម៉ាម យុន តើលោកឮខ្ញុំទេ? តើលោកបានដឹងឮអំពីការនិយាយអំពីការដួលរលំនៃទីក្រុងភ្នំពេញ ឬការវាយយកទីក្រុងភ្នំពេញដោយពួកខ្មែរក្រហម។ តើលោកមានធ្លាប់ឮគេនិយាយរឿងហ្នឹងទេ?

**ឆ៖** កាលហ្នឹងឮ។

**ស៖** តើលោកអាចរៀបរាប់អំពីស្ថានភាពដែលកើតឡើងនៅពេលហ្នឹងទេ ថាពេលណា កើតឡើងតាំងពេលថ្មីៗនេះ ឬក៏កើតឡើងតាំងពីពេលណា? តើលោកអាចដឹងទេថាមានចំនួនប៉ុន្មានឆ្នាំហើយដែលកើតឡើងរឿងហ្នឹងតាំងពីពេលណា រហូតដល់មកដល់ពេលថ្ងៃហ្នឹង? តើមានរយៈពេល៥០ឆ្នាំ ឬក៏២០ឆ្នាំ ឬក៏១០០ឆ្នាំ ឬក៏ប៉ុន្មានឆ្នាំដែរ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ?

**ឆ៖** អាហ្នឹងខ្ញុំចាំមិនបានទេ អត់ចាំឆ្នាំខែថ្ងៃ បើយើងឃើញៗ ចាំ អត់ចាំទេ។

**ស៖** លោក រម៉ាម យុន តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាតើលោកអាចបានចាំអ្វីបានច្បាស់លាស់បើធៀបទៅនឹងព្រឹត្តិការណ៍នោះ។ តើជារឿងដែលគេនិយាយប្រាប់លោក គ្រាន់តែប្រាប់លោក ឬក៏លោកជាសាក្សីដែលបានដឹងពីហេតុការណ៍ដែលបានកើតឡើងដែរឬទេ?

[១៤:៣៥:០៩]

**ឆៈ** កាលហ្នឹងយើងរាយការណ៍តាមយើងដឹងយល់ទេណ៎ា។ រឿងកន្លែងផ្សេងៗ ខ្ញុំអត់យល់កន្លែងខ្លួនឯងធ្វើខ្លួនឯងស្ដាប់បានអ៊ីចឹង។ ខ្ញុំសូមរាយការណ៍ថា គំនិតគោលជំហរសតិអារម្មណ៍ខ្ញុំតាំងពីតូចកើតធ្លាក់មកពីពោះម៉ែមក អត់ដែលធ្វើទេ ធ្វើធំ ធ្វើតូចទេ អ៊ីចឹង។ យើងអត់មានសមត្ថភាព គោលជំហរនយោបាយសតិអារម្មណ៍ វប្បធម៌ទាប អ៊ីចឹង។ អត់បានទេ។ រឿងនេះក៏ខ្ញុំរៀបរាប់វាវែងឆ្ងាយណាស់ណ៎ា រៀបរាប់តាំងពីខ្លួនឯង ដល់ម៉ែឪខាងក្រៅតាមឃុំ តាមស្រុក តាមភូមិ តាមពូជ តាមសាសន៍ អ៊ីចឹង។ រឿងនេះ សព្វថ្ងៃនេះ កាលតាំងពេលខ្ញុំទៅភ្នំពេញលើកមួយហ្នឹងណ៎ា ខ្លះគេអរខ្លះគេធុញដែរ។ ខ្លះគេអរយ៉ាងម៉េច? គេអររឿងខ្ញុំ អត់ចេះដាក់រឿងដាក់រ៉ាវដាក់ទិសអ៊ីចឹង។ ការជាក់ស្ដែងៗហើយ ឧបមា យើងទៅរាយការណ៍អង្គការពីគណៈឃុំ ដល់គណៈស្រុក ដល់គណៈតំឡូវគេថា គណៈខេត្ត ភូមិភាគ ចៅហ្វាយស្រុកអីនេះណ៎ា អ៊ីចឹង ហើយរាយការណ៍តាមហ្នឹង។

[១៤:៣៧:៤១]

កាលហ្នឹង ខ្ញុំក្ដាប់ច្រើនដែរក្នុងឃុំខ្លួនឯងនោះ។ ដឹកនាំធ្វើចម្ការធ្វើស្រែដាំដំឡូង ដឹកនាំខាងនយោបាយការសាមគ្គីសង្គមគ្នា អ៊ីចឹង។ ខ្លះវាចូលខ្លះវាអត់ចូលត្រជាក់ ខ្លះវាកើតខ្លះវាមិនកើត។ យូរៗអង្គការបន្ទោស អ្ហែ ស្រុកអណ្ដូងមាស វាអត់មានថ្លៃថ្នូរ។ ធ្វើអីក៏មិនកើត ធ្វើអីក៏មិនបាន អ៊ីចឹង។ យ៉ាងម៉េចយើងអប់រំហើយ ដាក់ផែនការហើយ ខ្លះគ្នាមានខ្លះគ្នាអត់ ហើយអ៊ីចឹង។ អាហ្នឹងរឿងនេះ ខ្ញុំឆ្ងល់មែនទែន។ តំណាងសហគមន៍នេះ អត់ឃើញទេម្ចាស់ចាត់ចែងមកពីខេត្តនោះ ភូមិភាគនោះអត់ឃើញទេ។ ស្រុកវាអត់ឃើញដែរ ឃើញតែមេឃុំមកទៅដឹកនាំផ្ទាល់មូលដ្ឋានខ្លួនឯង។ ការខុស ការត្រូវសុទ្ធមេឃុំគេយក *(ឮមិនច្បាស់)* អ៊ីចឹង។ បើគេថាឲ្យយើងទៅរាយការណ៍ជូនអង្គការ បើត្រូវបើវាតិច ម៉េចអន់ម៉េះ? រាយជូនការណ៍សាមគ្គីសង្គមវាជួយគ្នាទៅវិញទៅមកវាអត់មាន។ ម៉េចអត់មានបដិវត្តឃុំហ្នឹងភូមិហ្នឹងអ៊ីចឹង? យើងនិយាយតែម្ដង ហើយនៅមិនទាន់ស្ដាប់ទេ ពីរបីដងបានស្ដាប់។ ចង់សុំគេនិយាយបីបួនដង ប្រាំដង វាសុំគេខ្លះ។ ទៅៗរាយការណ៍អង្គការទៀត អង្គការថា "អ្ហែ! អត់ធ្វើ។ បើធ្វើវាបានហើយ ឃោសនាគេយល់ហើយ។" អត់ឃោសនាទេ អត់មានទិសផែនការដាក់ឲ្យគេ។ អ៊ីចុងៗទេ។ បើវាដាក់ វាអត់មាន វាហាត់ជាមួយ វាចេញញើសចេញឈាមដែរ ថាវាអត់ទៀត។ អ៊ីចុង។ អាហ្នឹងពិបាកណាស់អារឿងនេះ។

[១៤:៤០:៤៣]

បបួលទៅតាមអង្គការនេះ ម៉ែឪ អើវាស្ពាយអត់រួច ក្រោកមិនបាន វាធ្ងន់ពេកទៅណ៎ា ខ្ញុំដាក់តែបន្តិចៗ វាថា អ្ហែ! ដេញឲ្យធ្វើស្រែចម្ការអីទេ ខ្ចិលច្រអូសណាស់ អត់បានទេ រឿងនេះ ខ្ញុំចង់ងាប់ទៅណ៎ា វាឈឺក្បាលទៅណ៎ា អ៊ីចឹង។ អាហ្នឹងហើយរឿងនេះ។ ហ្នឹងគេថា មកពីណា? មកពីគណៈភូមិមិនឃោសនា មិនអប់រំ មិនដឹកនាំគេ។ ចេញទៅឃុំទៀត ឃុំអីនេះ វាមិនកើត ដឹកនាំកម្លាំងសហគមន៍ធ្វើអីមិនកើត ធ្វើអីគេមិនបាន។ ដល់ទៅស្រុកទៀត ស្រុកអានេះអន់ *(ឮមិនច្បាស់)* <u>ស្រួវ</u>អត់ គោលជំហរអ្នកនយោបាយ សតិអារម្មណ៍ អប់រំ ឲ្យគេជ្រាលជ្រៅ ឃើញគោលជំហរអ្នកនយោបាយដឹកនាំ អានេះអត់។ យ៉ាងម៉េច ដល់យើងនិយាយឲ្យអស់វាចេញអាចម៍របស់ឯង។ អ៊ីចឹង។ ទៅអង្គការ ៗបន្ទោស។ មកវិញ កម្លាំងសហគមន៍ខឹង។ ខឹងអីគ្នាហត់វីក្បាលទៅហើយ។ ដូចជាធ្វើអាអ្នកល្ងង់ អ្នកឆ្កួត។ មកយើងប្រើ មកយើងវ៉ៃ អ៊ីចឹង។

[១៤:៤២:៤១]

មួយទៀតអាពេលហ្នឹង គេថា អ្ហែ! អត់ចេះវ៉ៃទេ។ មិនចេះម៉េច! ដូចយើងរំដោះពួកវណ្ណៈជិះជាន់វ៉ៃយើង ហើយឲ្យយើងទៅវ៉ៃទៀត បន្ទោសដែរ។ បើមិនវ៉ៃ អ្ហែ! រណបគេ។ អារឿងនេះជំនាន់នោះខ្ញុំបិះចងកដែរណ៎ា! គិតចុះគិតឡើង ចងយ៉ាងម៉េច បើខ្ញុំងាប់គេរស់។ ទុកសិន អ៊ីចឹង អាហ្នឹងរឿងនេះ។

ដល់រំដោះនេះ ម៉ែឪភូមិកំណើតរកកូនចៅ ខ្ញុំទើបឃើញដែរ ខ្លះយកប្រពន្ធ ខ្លះវាបាត់បង់ដល់ណាដល់ណើ យើងដូចក្របីគោ ម្ចាស់អត់ទៅចាប់វា អ៊ីចឹង។ អាហ្នឹងហើយ យើងថា បើយើងនិយាយឲ្យខ្លាំង វាអស់កម្លាំង បើនិយាយខ្សោយ វាអត់កើតផែនការ អារឿងនេះ។ ទៅអង្គការ ៗបន្ទោសថា អន់ណាស់ ខ្សោយណាស់ *(ឮមិនច្បាស់)* ខ្លាំងណាស់។ អ៊ីចឹងទៀត ផ្លូវណាទៅ!

ថយក្រោយ គេវ៉ៃអាខាងក្រោយ បុកទៅមុខ គេវ៉ៃក្បាល ដូច្នេះ ស្លាប់រស់ នេះអារឿងនេះ។ អាហ្នឹងហើយម៉ែឪត្អូញត្អែរ កូនគេ ចៅគេបាត់បង់ ត្អូញត្អែរ បន្ទោសអ្នកណា? អាអ្នកដឹកនាំ អាអ្នកចាត់ចែង អាអ្នកឃោសនាអប់រំហ្នឹងណ៎ា អ៊ីចឹង។

[១៤:៤៤:៥៩]

អាអ្នកអប់រំហ្នឹងវាអត់ឃើញផ្លូវ។ ផ្លូវធ្វើឆ្ងាយ មនុស្សគិតហ្នឹងវាឆ្ងាយ មនុស្សធ្វើនេះវាជិត។ វាគិតថាយ៉ាងនេះយ៉ាងនោះ ទៅនោះទៅនេះ វាឆ្ងាយណាស់។ យើងដាំដំឡូង វាស្រួល មួយថ្ងៃពីរថ្ងៃ។ ប៉ុន្តែកម្លាំងវាអត់ជួបជុំគ្នា អត់ប្រមូលដែរ អ៊ីចឹង។ សតិអារម្មណ៍ក៏វាមិនមូលដែរ។ កម្លាំងចិត្តកម្លាំងកាយក៏វាមិនមូលដែរ អាហ្នឹងអាកាលហ្នឹង។ អ៊ូ ហត់ទាញ អប់រំទៅ អ៊ីចឹង។ អាហ្នឹងខ្ញុំគិតថា ម៉េចគាត់

ខ្លះបាត់កូនគាត់ ខ្លះបាត់ប្ដីគាត់ យើងថា  មកចូលមក ចេះចូលម៉េច វាធុំក្លិន ម៉េចវាចេះចូល? អាហ្នឹង កាលនុ៎ង កាលយើងតស៊ូហ្នឹង កាលយើងធ្វើហ្នឹងណ៎ា អ៊ីចឹង។ អត់ដឹងថាពីថ្នាក់លើក្បែរថ្នាក់ក្រោម ថ្នាក់ក្រោមអូសទៅនោះ។ បើអ៊ីចឹងវាមិនស្អុក! ហ្នឹងវាស្អុកហើយ អ៊ីចឹង។ អាហ្នឹង ម៉ែឪថា អ្ហែ! ធ្វើអីធ្វើ បដិវត្តន៍វាហិនហោចខ្ចោចផ្សា មនុស្សអស់ ក្រក៏ក្រទៀត អ៊ីចឹង។ ចុះម៉េចបើក្រ! កាលនុ៎ង យើងដូចជា ជ្រូកណ៎ា យើងដាក់ទ្រុង ធ្វើម៉េចវារកស៊ី។

[១៤:៤៧:១១]

កូនក៏អត់មាន ស៊ីវាមិនឆ្អែត ដូចយើងដែរ។ បើស៊ីមិនឆ្អែតហើយ វាខាំគ្នា វាស្រែកហើយ ហ៊ឺ!អា នោះអាក្រក់ម្ល៉េះ អ៊ីចឹង។ អាក្រក់នៅអាក្រក់ៗ មួយចប់តែម្ដង។ អាហ្នឹងហើយរឿងនេះវាៗពិបាកមែន ទែន។ មួយទៀត ដូចថា មកពីចម្ការទៅភូមិអ៊ីចឹង វាធូន់មក យើងស្ពាយមកពីចម្ការដល់ភូមិហើយ មានអី យូរទៅវាស្រេកទៅ អត់គ្រប់។ អាហ្នឹងរឿងនេះ។ ប៉ុន្តែខ្លះគ្នាហាត់គ្នាឡើយ ចង់ខឹងដែរ ខ្លះចងក ដែរ អ៊ីចឹង។ វាស្អុកស្មាញពេក។ អាហ្នឹងហើយអង្គការថ្នាក់លើ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក គណៈខេត្ត គេថា អ្ហែ! មូលដ្ឋានស្រួលណាស់ ដឹកនាំស្រួលណាស់ អត់អីទេ! ស្រួលម៉េច! យើងនៅដល់ ស្រុក ចុះក្រោមវាមិនស្រួលមិនម៉េច! ពេលកំពុងឡើង វាហាត់ចង់ងាប់ ភ្នំនោះ។ ដឹងដល់ ដឹងមិនដល់ យ៉ាងម៉េចវាមិនដល់! ធ្វើចុះធ្វើឡើង អានេះមិនកើត អានោះមិនកើតទេ! កម្មាភិបាលនេះ! ស្រុកនេះ! ខេត្តនេះ ឃុំនេះ អន់ម្ល៉េះ! កម្មាភិបាលអន់ ទុកក៏មិនកើតដែរ សម្រិតសម្រាំងកាប់ស៊ីចុះ កាប់ស៊ីទៅ។

[១៤:៤៩:៣៦]

រឿងនេះវាចង់ វាធាត់ អត់ធាត់ទេ! តំណាងសហគមន៍ វាមិនមែនវាយល់ថា អង្គការទេ ដូចរឿង ជំពាក់អង្ករ ជំពាក់លុយ យកដល់ខ្ញុំ គេចាប់ដោយខ្ញុំតែម្ដង អ៊ីចឹងតើ។ ខ្ញុំចង្អុលថា ឯណោះទៅសួរនោះ គេបញ្ជាទេ អ៊ីចឹងអាហ្នឹង។ កម្លាំងសហគមន៍វាបន្ទោស ឯណា កម្មាភិបាល គ្រប់គ្រងផ្ទៃក្នុងៗភូមិ ក្នុងឃុំ ក្នុងស្រុក ក្នុងក្រុមគេ អ៊ីចឹង។ អាហ្នឹងដែលថាងាយៗ ពេលដែលវាសន្តិសុខ យើងអត់ឃើញ ទេភូមិគេ មូលដ្ឋានគេ យើងអត់នៅជាក់ស្ដែងជិតស្និទ្ធទេ។ ដល់គ្រោះថ្នាក់ហើយ យើងនៅហើយ មូលហេតុមកពីអី? មកពីអង្គការ អ៊ីចឹងតើ។ គេបន្ទោសអ្នកណា? បន្ទោសយើង ដូចតែខ្ញុំ គេបន្ទោស ដែរ។ បន្ទោសខ្ញុំក៏មិនអន់ចិត្តដែរ ម៉េចអន់ចិត្ត! ខ្ញុំធ្វើមែន។ ធ្វើដោយសារ គេថាធ្វើបដិវត្តន៍ ៗ គេថា កសាងៗ អ៊ីចឹង។ កសាងគោលជំហរ អ្នកនយោបាយ សតិអារម្មណ៍។ អាហ្នឹងឲ្យវាជ្រះស្រឡះ វប្បធម៌ ផ្នែកនយោបាយស្អាតស្អំ។

[១៤:៥១:៣៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវបានហើយ រម៉ាម យុន។ ពេលវេលាសមល្មមនឹងសម្រាកហើយៗ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី ដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ ហើយខាងមន្ត្រីតុលាការសម្របសម្រួល ដើម្បីឲ្យរកកន្លែងសម្រាកសមរម្យសម្រាប់ដើម្បីរដ្ឋប្បវេណីរូបនេះផងក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ។ ហើយសូមឲ្យនាំគាត់មកកាន់កន្លែងសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណីនេះ ឲ្យបានមុនអង្គជំនុំជម្រះចូលមកកាន់អាសនៈ។

*(សវនាការសម្រាកពីម៉ោង ១៤:៥៣ នាទី ដល់ម៉ោង ១៥:១១ នាទី)*

[១៥:១១:១៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ អម្បាញ់មិញនេះ គឺអង្គជំនុំជម្រះបានស្ដាប់នូវសេចក្ដីអត្ថាធិប្បាយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី រម៉ាម យុន ដោយការតាំងសំណួររបស់ចៅក្រម ហ្សង់ម៉ាក។ តើលោកចៅក្រម ហ្សង់ម៉ាក មានសំណួរអ្វីសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះថែមទៀតទេ?

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំគ្មានសំណួរអ្វីដែលត្រូវសួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទៀតទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បើអស់លោក លោកស្រីចៅក្រមផ្សេងទៀត តើមានសំណួរអ្វីសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះទៀតទេ?

[១៥:១២:២៤]

បើមិនមានទេ គឺអង្គជំនុំជម្រះកំណត់ថាកិច្ចសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី រម៉ាម យុន ចប់ត្រឹមនេះ ហើយអង្គជំនុំជម្រះសូមអរគុណចំពោះលោក រម៉ាម យុន ដែលបានចំណាយពេល

វេលាដ៏មានតម្លៃ ហើយធ្វើដំណើរដ៏ផ្លូវវែងឆ្ងាយ ពីព្រំដែនម្ខាងមកដល់ទីក្រុងភ្នំពេញ ដើម្បីផ្តល់សក្ខីកម្ម។ អង្គជំនុំជម្រះអស់សំណួរត្រូវសួរដល់លោកទៀតហើយ។ ដូច្នេះ លោកអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏ទៅគោលដៅណាដែលលោកចង់ទៅបានហើយ។ ប៉ុន្តែដោយសារលោកនៅឆ្ងាយ ហើយមានការពាក់ព័ន្ធទៅនឹងភារកិច្ចរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញដែលត្រូវសម្របសម្រួលលោកក្នុងការវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកវិញ។ ដូច្នេះ លោកអាចនៅរង់ចាំដើម្បីឲ្យទុកលទ្ធភាពឲ្យខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញរៀបចំការវិលត្រឡប់របស់លោក។

[១៥:១៣:៣៨]

មន្ត្រីតុលាការនាំលោក រម៉ាម យុន ត្រឡប់ទៅកាន់កន្លែងវិញ ដើម្បីពាក់ព័ន្ធជាមួយនឹងខាងអង្គភាពដែលមានភារកិច្ចដើម្បីឲ្យទទួលយកលោកទៅរកកន្លែងសម្រាក និងហើយ ឲ្យអញ្ជើញលោក ក្លាន រ៉ិត ចូល មកកាន់បន្ទប់សវនាការ។

[១៥:១៤:៤៦]

ជាកិច្ចបន្តនេះ យើងអង្គជំនុំជម្រះកំណត់ក្នុងការស្តាប់នូវសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត គឺលោក ក្លាន រ៉ិត ដែលពីមុនគាត់បានធ្វើខ្លះហើយ ប៉ុន្តែដោយមានបញ្ហាសុខភាពមិនអាចដំណើរការបាន ដូច្នេះបានជាលើកសវនាការ។ ឥឡូវនេះមានវត្តមានរបស់លោក ក្លាន រ៉ិត ហើយអង្គជំនុំជម្រះសូមជម្រាបថា ខាងដើមបណ្តឹងរដ្ឋប្បវេណីបានសួររួចហើយ ចំណែកឯសហព្រះរាជអាជ្ញាបានសួរពាក់កណ្តាលហើយ នៅពាក់កណ្តាលទៀត អង្គជំនុំជម្រះនឹងផ្តល់ពេលវេលាសាមសិបនាទីក្នុងការសួរ ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ក្លាន រ៉ិត។

ទន្ទឹមនឹងហ្នឹងដែរ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា មេធាវីការពារក្តីទាំងបីក្រុម ដែលអង្គជំនុំជម្រះបានផ្តល់ជូននូវពេលវេលាតាមការស្នើសុំកន្លងមក ហើយមេធាវីចំនួនពីរក្រុមមិនបានប្រើប្រាស់នូវពេលវេលានៅក្នុងការសួរទេ។ មុននឹងចាប់ផ្តើមដំណើរការ ស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីក្លាន រ៉ិត អង្គជំនុំជម្រះបានសួរសាជាថ្មីម្តងទៀត ថាតើមេធាវីការពារក្តីមានជំហរយ៉ាងដូចម្តេចដែរ ក្នុងការសួរ តាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណី ក្លាន រ៉ិត? ហើយបើសិនជាត្រូវការសួរ ១ប៉ុន្មាន? ហើយបើថាមិនត្រូវការសួរទេ គឺសូមបង្ហាញជំហរច្បាស់លាស់ ដើម្បីអង្គជំនុំជម្រះរៀបចំកម្មវិធីក្នុងការដឹកនាំគ្រប់គ្រងសវនាការឲ្យមានប្រសិទ្ធភាព ដោយចាប់ផ្តើមពីមេធាវី នួន ជា មុន។ សូមអញ្ជើញ!

[១៥:១៦:៤០]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន វាអាស្រ័យទៅលើចម្លើយហ្នឹងដែលថា យើងនឹងត្រូវធ្វើដោយរបៀបណា ក៏ប៉ុន្តែជាទូទៅយើងខ្ញុំមិនមានសំណួរអីទេសម្រាប់យើងខ្ញុំ ដូចជាហេតុផល ដូចក្នុងរឿងដើមបណ្តឹងរដ្ឋប្បវេណីមុនដែរ។

**ប្រធានអង្គជំនុំ៖**

បាទ, សូមអញ្ជើញលោកស្រីចៅក្រម!

[១៥:១៧:០៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

គឺខ្ញុំ គឺមានការស្នើសុំឲ្យចែកពេលវេលាសម្រាប់មេធាវីការពារក្តីសួរសំណួរមកកាន់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ នៅពេលខាងមុខ ថ្ងៃខាងមុខ សូមបញ្ជាក់ឲ្យបានមុនផងថា តើបើប្រសិនណាជាលោកមិនត្រូវការសុំពេលវេលាដើម្បីសាកសួរសំណួរអ្វីទេ ដើម្បីងាយស្រួលឲ្យអង្គជំនុំជម្រះរៀបចំចាត់ចែងសវនាការ នឹងរៀបចំលៃលកពេលវេលាសម្រាប់ទៅក្រុមនីមួយៗ សូមអរគុណ។

[១៥:១៧:៤៥]

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមអញ្ជើញលោកមេធាវីការពារក្តី អៀង សារី បាទ!

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន ខ្ញុំបាទក៏យល់ស្របដែរនឹងការបែងចែកពេលវេលា ហើយខ្ញុំបាទដកបទពិសោធន៍កាលពីសវនាការលើកមុនតុលាការមិនអាចកំណត់ពេលវេលាបានទេ ដោយចាំផ្អែកលើកាលៈទេសៈ និងស្ថានការណ៍ដំណើរការទៅ។ ប៉ុន្តែបើសិនជាតុលាការតម្រូវឲ្យចែកពេលវេលាគួរតែចែកពីពេលវេលាហ្នឹងសម្រាប់ភាគីទាំងអស់ ហើយតាមតែការ តុលាការយល់ឃើញមិនអាចចែកតែមេធាវី ហើយដើមបណ្តឹងរដ្ឋប្បវេណី ឬព្រះរាជអាជ្ញាមិនចែក អាហ្នឹងក៏មិនសូវសមស្របដែរ។

សម្រាប់សាក្សី (សូមទោស) ដើមបណ្តឹងរដ្ឋប្បវេណី ក្លាន រ៉ិត ហើយក្រុមមេធាវីលោក អៀង សារី មានសំណួរប្រហែលជាមិនលើសសាមសិបនាទី ឬក៏តិចជាងហ្នឹងតាមខ្ញុំបាទព្យាយាមកាត់បន្ថយឲ្យខ្លី។ សូមអរគុណ។

[១៥:១៨:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

**លោក គង់ សំអុន៖**

សូមគោរពលោកប្រធាន! ទាក់ទងទៅនឹងសាក្សីលោក ក្លាន វ៉ិត នេះ ខាងយើងមិនទាន់អាចកំណត់ថា តើយើងត្រូវការពេលវេលាប៉ុន្មានទេ ដោយហេតុថាយើងមិនបានដឹងឲ្យច្បាស់ថា លោកនឹងនិយាយប៉ះពាល់អ្វីខ្លះដល់កូនក្តីរបស់ខ្ញុំបាទ។

ដូច្នេះ វាអាស្រ័យទៅលើសក្ខីកម្មដែលផ្តល់ដោយសាក្សីដើមបណ្តឹងរដ្ឋប្បវេណីនេះ។ ដូច្នេះបើសិនជាពេលវេលាយើងត្រូវការនោះ ប្រហែលជាមិនលើសពីសាមសិបនាទីទេ ហើយបើសិនជា មិនមានអ្វីពាក់ព័ន្ធនឹងអាចពុំមានសំណួរ។ បាទ, សូមអរគុណ។

[១៥:១៩:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ, អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅលោកតំណាងសហព្រះរាជអាជ្ញាដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

[១៥:២០:០៨]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ លោក ក្លាន វ៉ិត បាទយើងបានជួបគ្នារយៈពេលមួយខែមុននេះ ខ្ញុំចោទសំណួរទីមួយ សូមសង្ខេបដោយខ្លីទេ នូវអ្វីដែលលោកបាននិយាយពីកាលថ្ងៃមុននោះ។ បើសិនជាអ្វីដែលខ្ញុំលើកឡើងនេះ វាមិនត្រឹមត្រូវនោះ អ៊ីចឹងសូមលោកជួយកែសម្រួលផង។

លោកបានជម្រាបថា លោកត្រូវបានបង្ខំឲ្យចូលក្នុងចលនាបដិវត្តន៍នៅក្នុងទសវត្សរ៍ឆ្នាំ៦០ កាលនោះគេបានប្រាប់លោកថា បើសិនជាលោកមិនចូលក្នុងចលនានោះ លោកនឹងពុំមានសេរីភាពនោះទេ ឬក៏ថាលោកនឹងមិនអាចរស់រានមានជីវិតបានទេ ហើយលោកបានជម្រាបផងដែរថា លោកបានចូលរួមក្នុងចលនាដើម្បីរំដោះប្រទេសដែលស្ថិតក្រោមការគាបសង្កត់ ហើយនិងកេងប្រវ័ញ្ចដោយពួកសក្តិភូមិ។ លោកបានជម្រាបផងដែរ ដោយសារតែលោកជាមនុស្សពុំមានចំណេះ អ៊ីចឹងលោកនៅក្នុងជនជាតិភាគតិច អ៊ីចឹងខ្មែរក្រហមគេស្រួលបញ្ចុះបញ្ចូលលោក បំពាក់បំប៉នមនោគមន៍វិជ្ជា ហើយលោក

បានជម្រាបផងដែរថា លោកបានធ្វើការឲ្យបក្សចាប់ពីពេលដែលគេជ្រើសរើសលោកនៅទសវត្សរ៍ឆ្នាំ ៦០ រហូតដល់ថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ហើយនិងពេលក្រោយមកទៀតផងដែរ។

[១៥:២១:៥០]

អ៊ីចឹងលោកនៅតែរក្សាគោលជំហររឹងមាំនៅពេលដែលបក្ស ដែលសួរលោកថា លោកត្រូវតែគោរពវិធានសីលធម៌ គេតម្រូវឲ្យលោកថាលោកចេះនៅស្ងៀមស្ងាត់ ហើយគោរពវិន័យរបស់អង្គការ។ លោកបានជម្រាបផងដែរថា គេហាមមិនឲ្យលោកគោរពប្រតិបត្តិសាសនា ឬក៏ផ្ដល់ជាចង្ហាន់ទៅដល់អារក្សអ្នកតានោះ ហើយនៅទីបញ្ចប់ខ្ញុំចាំថា លោកបានជម្រាបថា មិនត្រូវក្បត់បក្សនោះទេ ហើយនិងមិនត្រូវចុះចូលសត្រូវនោះទេ ហើយនៅក្នុងឋានៈជាសត្រូវនោះ គឺថាមានពួកវៀតណាម ពួកលន់ នល់ ហើយនិងពួកសក្តិភូមិ។

**ស៖** អ៊ីចឹងសំណួរទីមួយរបស់ខ្ញុំ គឺដូចតទៅនេះ តើការងាររបស់លោកសម្រាប់បក្ស បដិវត្តន៍មុនឆ្នាំ១៩៧៥ នោះ គឺថាមុនពេលដែលវាយបែកភ្នំពេញ តើការងារនេះផ្ដល់សេរីភាពរបស់លោកលើសពីមុន ឬក៏ធ្វើឲ្យលក្ខខណ្ឌជីវភាពរបស់លោកប្រសើរជាងមុនដែរ ឬទេ?

[១៥:២៣:១៧]

**លោក ក្លាន វ៉ិត៖**

**ឆ៖** សូមឆ្លើយ ខ្ញុំសូមឆ្លើយក្នុងការតស៊ូដោយសារការជាក់ស្ដែង អ៊ំហៅខ្ញុំទៅប្រជុំនៅ ក-៥។ អ៊ំ អៀង សារី ខ្ញុំអត់បានទៅដោយសារ ខ្ញុំចុះដាំស្រូវស្រាល។ ខ្ញុំអត់ចង់ទៅ វាជួបខ្ញុំ វាដល់ថ្ងៃខែដាំស្រូវហើយ។ គាត់ចាត់ចែងកម្លាំងពីរនាក់ទៅកាក់យកខ្ញុំមានកាំភ្លើងបីដើម។ ឈ្មោះ អ៊ីន ទៅយកខ្ញុំម្នាក់ហ្នឹងស្គាល់ បញ្ញវន្តនៅមន្ទីរភូមិភាគរបស់គាត់នៅ ក-៥។ គាត់ថា បើឯងមិនទៅ ខ្ញុំក៏មិនទៅវិញដែរ បើឯងទៅថ្ងៃនេះ ខ្ញុំបានទៅថ្ងៃនេះ។ ខ្ញុំថាពីណាប្រាប់? អ៊ំ អៀង សារី ឲ្យទៅយកឯង បើឯងមិនទៅខ្ញុំអត់ទៅវិញទេ។ ឈ្មោះ អ៊ីនៗ ទៅហៅខ្ញុំនៅចម្ការ។ ប្រពន្ធខ្ញុំស្ពាយ កផា ហើយខ្ញុំយកឈើដាំស្រូវនោះ។ គិតទៅគិតមកបើមិនទៅខ្លាចគេ អង្គការគេអ្នកធំ។ អាអ្នកទៅយកខ្ញុំថា បើឯងមិនទៅខ្ញុំអត់បានទៅវិញទេ គេផ្ដាំថា ឯងទៅថ្ងៃណា ខ្ញុំត្រឡប់ថ្ងៃនោះ។ ខ្ញុំទៅសួរពុកខ្ញុំថា យ៉ាងម៉េចពុក គេហៅខ្ញុំទៅប្រជុំ។ ពីណាហៅ? អ៊ំ អៀង សារី ប្រជុំនៅក-៥។ គាត់ថា អូ៎! កូន គេដឹងហើយមនុស្សយើងរស់ដោយសារបាយ។ ពេលនេះខែនេះ ទៅហើយខែយើងដាំស្រូវ។ ដោយសារគេហៅចេះតែទៅកូន អាហ្នឹងខ្ញុំទៅ។ ទៅដល់ហ្នឹងកម្លាំងគាត់អប់រំគេ៩០នាក់ គេថាប្រជុំភូមិភាគ ទាំងអស់តាំង

ពីសៀមប៉ាង ស្ទឹងត្រែង ក្រចេះ លំផាត់ ស្ទឹងត្រែងគេហៅទាំងអស់។ កាលមុនគេហៅភូមិភាគ គេប្រជុំភូមិភាគអ៊ីចឹង។ ដល់អ៊ីចឹងខ្ញុំទៅដល់ហ្នឹង ខ្ញុំដាក់បាល់ឡូ ខ្ញុំឈរ អ៊ំ អៀង សារី ក្រឡេកមើលខ្ញុំ អ៊ូ! មិត្ត រ៉ិត មកហើយណ៎ា! បាទខ្ញុំមកហើយអ៊ំ។ ម៉េចឯងមកនេះធ្វើទេបដិវត្តន៍ ឬមិនធ្វើ? ខ្ញុំអត់ចេះឆ្លើយនៅស្មៀម ខ្ញុំថាអ៊ំធ្វើបដិវត្តន៍នៅកន្លែងណា ខ្ញុំទៅហ្នឹងបាន។ ម៉េចហៅឯង គេមកគ្រប់ហើយនេះ៩០នាក់នេះចាំឯងមួយថ្ងៃដូចជា៩០ថ្ងៃ ល្អដែរចិត្តឯង ឬក៏អាក្រក់? ខ្ញុំថាអត់ល្អទេ ខ្ញុំមកក្រោយគេដោយសារពុកខ្ញុំឈឺ។ ខ្ញុំចុះដាំស្រូវ ដល់អ៊ំហៅមកខ្ញុំចេះតែមក។

[១៥:២៦:២៤]

បើមិនធ្វើបដិវត្តន៍អត់បានរស់ទេមនុស្ស។ ឯងទៅនៅណា បើគេ ឯងខ្លាចអត់មានបាយហូប គេហូបបាយដែរ នឹកប្រពន្ធគេមានប្រពន្ធ នឹកម៉ែគេមានម៉ែដែរ។ បើថាខ្លាចងាប់គេចេះងាប់ដូចឯងដែរធ្វើយ៉ាងម៉េច។ ខ្ញុំអង្គុយៗ តាំងពីហ្នុងរហូតដល់សព្វថ្ងៃខ្ញុំគោរពខ្លាច ៗអង្គការ ក្រក៏ដោយ កម្សត់ក៏ដោយ ងាប់ក៏ដោយ ចេះតែគោរពអង្គការ គឺថាអង្គការ វាធំជាង ពីណាធំជាង។ បក្ស និងរដ្ឋ ហើយធំអាហ្នឹងសព្វថ្ងៃខ្ញុំខ្លាចដល់សព្វថ្ងៃ។ ខ្លាចដោយសារអ៊ំ អៀង សារី បង្ខំខ្ញុំធ្វើបដិវត្តន៍។ ដោយសារបង្ខំខ្ញុំអ្នកក្រខ្លាចអត់មានបាយ ដល់ហើយខ្ញុំចុះដាំស្រូវ គេហៅបើមិនទៅ ខ្ញុំទៅក្រោយគេអាហ្នឹងគាត់ខឹងគេ៩០នាក់គេទៅហើយ គេចាំខ្ញុំមួយថ្ងៃ។ អាហ្នឹងគាត់ឆ្លើយថា ម៉េចមិត្ត រ៉ិត ឯងមកក្រោយគេ គេ៩០នាក់ គេចាំមើលថ្ងៃដូច៩០ថ្ងៃ ល្អដែរចិត្តឯង? អ៊ីចឹងណា ហ្នឹងៗខ្ញុំថាគាត់បង្ខំខ្ញុំ អ៊ីចឹង អាហ្នឹងទីមួយ។

[១៥:២៧:៣៥]

ទីពីរទៀត ក្រោយពីហ្នឹង អាហ្នឹងកំពុងមិនទាន់ធ្វើសហករណ៍ ដល់គេចាត់តាំងខ្ញុំធ្វើអនុស្រុកហ្នឹងគឺឆ្នាំ៧៦។ ៧៦ហ្នឹង ចាត់តាំងគណៈស្រុក គេធ្វើសហករណ៍ៗ ប្រមូលទាំងដី ប្រមូលទាំងមនុស្សប្រមូលទាំងក្របី ប្រមូលទាំងគោ ប្រមូលទាំងឆ្នាំងបាយ ហូបបាយរួម។ ស្មុគស្មាញណាស់ ខ្ញុំអក្សរក៏អត់ចេះ ខ្មែរអត់ចេះ ម៉េចគេគេអនុម័តអ៊ីចេះ ធ្វើជុំ យ៉ាងម៉េចខ្ញុំថា ធ្វើយ៉ាងម៉េចបដិវត្តន៍នៅក្រ ធ្វើសហករណ៍នៅដៃនៅជើងកាប់ ធ្វើស្រែកាប់នឹងចប មិនទាន់មានម៉ាស៊ីន មិនទាន់រោងចក្រមិនទាន់មានអង្ករ ម៉េចធ្វើយ៉ាងនេះ។ ចងកខ្លួនឯង អាណិតកូន អាណិតប្រពន្ធ អាណិតម៉ែ អាណិតឪ ខំធ្វើអ៊ីចឹងហើយ ព្រមអ៊ីចឹងហើយ គេហៅទៅប្រជុំមកដឹកនាំប្រជារាស្ត្រធ្វើទំនប់ ជាក់ស្តែងធ្វើអី ធ្វើទំនប់ អូរភ្លល់សព្វថ្ងៃវាលទោងនេះ។ ទីពីរ ធ្វើទំនប់អូរកាតាំ។ ពេលធ្វើទំនប់អ្នកផ្ទាល់ដឹកនាំនោះ អ៊ំ រី, អ៊ំ វ៉ង់នេះទំពួននេះ អ៊ំ យ៉ា, អ៊ំ រី គាត់គណៈភូមិភាគ។ គាត់ទៅជួបជាមួយពួកខ្ញុំ ដឹកនាំអ្នកធ្វើទំនប់នោះ។

អូរភ្លល់មួយខ្សែ មួយកន្លែងអូរភ្លល់ វាលទោង មួយកន្លែងនៅវាលកាតាំ អូរកាតាំ វាលលេន ភូមិអ៊ីន សព្វថ្ងៃ។

**សៈ** លោក ក្លាន រ៉ិត ខ្ញុំសូមកាត់លោកបន្តិច។ ខ្ញុំសូមកាត់លោក ពីព្រោះថាយើងមានពេលខ្លី អ៊ីចឹងយើងសូមកម្រិតមកត្រឹមរយៈពេលមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ ខ្ញុំមានសំណួរមួយចំនួនដូចជា លោក តាំង ស៊ី (ប្រកបតាមសំឡេងដើម) ដែលលោកបានលើកឡើងឈ្មោះ តាំង ស៊ី នេះច្រើនណាស់ នៅក្នុងសវនាការពីមុននោះ។ លោកបាននិយាយថា គាត់ជាប្រធានស្រុក ហើយគាត់ជាគណៈភូមិភាគ ណ្ហសាន។ តើលោកអាចរៀបរាប់អំពីមុខងាររបស់លោក តាន់ ស៊ី (ប្រកបតាមសំឡេងដើម) នេះបាន ដែរឬទេ?

[១៥:៣០:១០]

**ឆៈ** បាទ។ អាហ្នឹងខ្ញុំនិយាយដូចការចលនាបដិវត្តប្រជាជាតិកាលពីខែមុន អ៊ំ អៀង សារី អ៊ំ វី គាត់ពីរនាក់ជាអ្នកដឹកនាំមុនដំបូង ធ្វើការមិនទាន់ធ្វើសហករណ៍ហ្នឹងបាទ។ រៀបរាប់ម៉េចហ្នឹង ឆ្នាំ៧៦ គាត់ចាត់តាំងខ្ញុំធ្វើជាអនុស្រុក រួចទៅធ្វើសហករណ៍។ អាហ្នឹងខ្ញុំបដិវត្ត។ ខ្ញុំអត់បដិវត្តទេអាហ្នឹង ខ្ញុំ និយាយអានេះមុនឲ្យហើយ មកកាលមុនហើយ ខ្ញុំបដិវត្តដោយសារ ក្នុងគេប្រមូលដីប្រមូលមនុស្ស ប្រមូលអីប្រមូលចង្ក្រានបាយអីហ្នឹង អាហ្នឹងខ្ញុំបដិវត្តទីពីរនេះអ៊ីចឹងបាទ។

**សៈ** សូមអរគុណ។ សំណួរខ្ញុំទាក់ទងទៅនឹងរយៈពេលមុនខែមេសា ឆ្នាំ១៩៧៥ លោកបាន លើកឡើងពីរបីដងថាលោក តាន់ ស៊ី ដែលមានរហស្សនាម ចាន់ ដេង ដែលថា ជាសមាជិកនៃក្រុមមួយ ដែលជំរុញឲ្យលោកចូលក្នុងចលនាបដិវត្តន៍ តើលោកអាចរំឭកអំពីមុខងាររបស់លោក តាន់ ស៊ី នេះបាន ដែរឬទេ?

**ឆៈ** បាន។ អ៊ំ ចង ស៊ី ហ្នឹង គាត់ហ្នឹងហើយចលនាឲ្យពួកខ្ញុំធ្វើបដិវត្តន៍មុនដំបូង។ កាលហ្នឹង គាត់ជនជាតិលាវ នៅភូមិកាឡាន់ នៅស្រុកវ៉ឺនសៃ គាត់ធ្វើអភិបាលស្រុក គាត់ចលនាពួកខ្ញុំ។ បន្តពីហ្នឹង ទៀត គឺគណៈភូមិភាគនោះ អ៊ំវី ជនជាតិខ្មែរទំពួន។ ពួកគាត់ហ្នឹងចលនាពួកខ្ញុំការតស៊ូតាំងពីបដិវត្ត ប្រជាជាតិ ដល់គេធ្វើសហករណ៍ហ្នឹងបាទ។

**សៈ** បាទ, សូមអរគុណ។ បើតាមលោកដឹងនោះ តើលោក តាន់ ស៊ី នេះជាមនុស្សសំខាន់នៅ ក្នុងបក្សដែរឬទេ?

[១៥:៣២:៣៣]

**ឆ៖** បាទ, សំខាន់ហើយគាត់ចលនាមុនពួកខ្ញុំនៅកំលោះ ដល់ខ្ញុំមានប្រពន្ធគាត់អូសទាញខ្ញុំធ្វើបដិវត្តជាជនជាតិលាវ។ ថង ស៊ី អាយុគាត់៥០ជាងហើយកាលនោះ។ ឥឡូវគាត់មិនដឹងស្លាប់នៅកន្លែងណា។

**ស៖** តើលោក តាន់ ស៊ី នេះបាននិយាយអំពីខ្មាំងដល់លោកទេ នៅពេលដែលគាត់ជ្រើសរើសយកលោកចូលទៅក្នុងបក្សនោះ? ហើយគាត់បាននិយាយអំពីអ្វីខ្លះទាក់ទងទៅនឹងខ្មាំងទាំងអស់នេះ?

**ឆ៖** សូមឆ្លើយ។ គាត់ចលនាធ្វើបដិវត្តន៍នោះ គាត់ថាអ៊ីចេះ ក្មួយបើយើងមិនធ្វើបដិវត្តន៍យើងនៅកន្លែងណា? យើងធ្វើបដិវត្តន៍ដោយសារ បើយើងមិនធ្វើបដិវត្តន៍អាចខ្មាំងវាជិះជាន់យើង។ ខ្ញុំថាអ្នកណាខ្មាំង? ខ្មាំងពួកអាកុម្ម៉ង់ដូ អាទាហានពួកអាលន់ នល់ ហ្នឹងហើយគឺថា ខ្មាំង។ បើយើងនៅល្ងង់ល្ងិតហ្នឹងអត់ចេះបដិវត្តហ្នឹង យើងអត់ឈ្នះគេទេ កើតជាខ្ញុំកញ្ជះគេ ដល់អស់ជីវិតថាអ៊ីចឹងណ៎ាមុនដំបូង។ អាហ្នឹងខ្ញុំក៏ចេះតែអត់ដឹងស្អីយ៉ាងម៉េច យ៉ាងម៉ាទេបដិវត្តចេះតែតាមគេ គេឲ្យទាក់ទងរត់សំបុត្រទាក់ទងឲ្យដាំបាយៗ ឲ្យធ្វើផ្ទះៗ ឲ្យធ្វើស្អីក៏ចេះតែទៅតាមគេតាមគាត់ទៅហើយ។ ដល់ចុងក្រោយគេចាត់តាំងអនុស្រុកដល់អ៊ំវី ឃើញមុខមាត់គាត់ហៅប្រជុំនៅបានលុង គាត់ហ្នឹងហើយគណៈភូមិភាគព្លសានអ៊ំ វី, អ៊ំ យ៉ា, តា ខាត់ បងប្អូនខ្មែរសុទ្ធ ហ្នឹងខ្ញុំបានឃើញបងប្អូនខ្មែរ ខ្ញុំបានចេះនិយាយតិចៗដល់សព្វថ្ងៃបាទ។ ថ្ងៃខែខ្ញុំភ្លេចហើយ ខ្ញុំអត់ចេះអក្សរ ខ្ញុំអត់សរសេរ ចំណាំតែឃើញមុខ ចំណាំតែគេផ្តែផ្តាំ ចំណាំតែគេបង្រៀនឲ្យអ៊ីចេះៗៗបាទ។

[១៥:៣៤:៥០]

**ស៖** បាទ, សូមអរគុណច្រើន ឥឡូវខ្ញុំសូមត្រឡប់មកនិយាយពីប្រធានបទមួយទៀត។ កាលពីលើកមុននោះលោកបានលើកឡើងថា លោកបានចូលរួមក្នុងកិច្ចប្រជុំចំនួនពីរជាមួយនឹងលោក អៀង សារី។ ហើយលោកបានលើកឡើងថា ក្នុងកិច្ចប្រជុំនោះបានប្រព្រឹត្តឡើងមុននៅថ្ងៃធ្វើរដ្ឋប្រហារឆ្នាំ៧០នោះ ហើយការប្រជុំនោះកើតមានឡើងនៅក្នុងព្រៃ។ ខ្ញុំចង់និយាយអំពីកិច្ចប្រជុំលើកទីពីរ ដែលលោកបានប្រជុំជាមួយលោក អៀង សារី។ តើលោកអាចជម្រាបប្រាប់យើងបានទេថា តើកិច្ចប្រជុំនោះកើតមានឡើងនៅកន្លែងណា ឲ្យច្បាស់លាស់តែម្តង?

**ឆ៖** បាទ, ខ្ញុំចម្លើយ។ ប្រជុំជាមួយគាត់មានពីរលើក ប្រជុំនៅព្រៃ។ កន្លែងខ្ញុំថានៅចម្ការបុស្សចាស់ នៅអូរដាំងមួយលើក។ លើកហ្នឹងគាត់សួរខ្ញុំធ្វើបដិវត្តន៍ ឬមិនធ្វើបដិវត្តន៍ៗ មួយលើក។ លើកទីពីរទៀត គឺប្រជុំនៅភូមិចាយ គេបើកវគ្គនៅភូមិចាយ មួយលើក។

[១៥:៣៦:០៥]

**ស៖** តើការប្រជុំទីពីរហ្នឹងរៀបចំដោយបក្សហ្នឹង គឺថាដើម្បីតែជាសមាជិកទេ ឬក៏ដើម្បីប្រជាជនក្នុងភូមិទាំងអស់តែម្តង?

**ឆ៖** បាទ, ខ្ញុំឆ្លើយ។ គេប្រជុំសមាជិកបក្សទាំងអស់ អ្នកគេហៅប្រធានឃុំ ប្រធានស្រុក អនុតំបន់ ហ្នឹងគេហៅគាត់ ហៅបើកវគ្គហ្នឹង។

**ស៖** សូមអរគុណ។ តើលោកអាចប្រាប់ថា តើការប្រជុំលើកទីពីរហ្នឹងកើតមានឡើងនៅពេលណា? តើមុនយូរមុនពេលដែលភ្នំពេញវាយបែកដោយពួកខ្មែរក្រហមនោះ ឬក៏នៅជិតពេលវាយបែកភ្នំពេញហើយ គឺថាមុនថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥នេះ?

**ឆ៖** ប្រជុំ បាទ មុននោះៗ មុនគេមិនទាន់រំដោះ។ តែខែថ្ងៃខ្ញុំអត់ចំណាំ មុនគេមិនទាន់រំដោះ។

[១៥:៣៧:៣១]

**ស៖** តើកាលនោះ លោកគឺជាប្រធានភូមិទេ ឬក៏លោកជាទាហានឃុំតាឡាវ កាលអង្កាល់នោះៗ?

**ឆ៖** បាទ,សូមឆ្លើយ ខ្ញុំគេចាត់តាំងមេឃុំហើយ។ ចាត់តាំងមេឃុំហើយ។

**ស៖** បើតាមខ្ញុំដឹង នៅចន្លោះឆ្នាំ១៩៧១-៧៥ ហ្នឹង គឺលោក អៀង សារី ភាគច្រើនគាត់នៅទីក្រុងប៉េកាំង។ តើលោកអាចបញ្ជាក់បានទេ ថាលោក អៀង សារី បានមកភាគឦសាននៅក្នុងរយៈពេលដែល រយៈពេលមុនពេលវាយបែកភ្នំពេញនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[១៥:៣៨:៣៨]

**លោក ម៉ៃខល កាណាវាស៖**

លោកប្រធានខ្ញុំសូមជំទាស់។ នេះគឺជាការសួរមួយមិនត្រឹមត្រូវ ក្រៅពីការសួរគាត់ថា នៅពេលណា គឺថាគាត់បានហាក់បីដូចជា បញ្ចុកចំណី ឬក៏មានន័យថា ឲ្យតម្រុយទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ជាជាងការដែលគាត់ផ្តល់សក្ខីកម្មដោយផ្ទាល់ខ្លួនទៅវិញ នេះគឺជាការតាំងសំណួរមួយដែលមិនត្រឹមត្រូវទេ។ ហើយដើមបណ្តឹងរដ្ឋប្បវេណី មុននេះគឺថា គឺគាត់មានការពិបាកក្នុងការចងចាំ ប៉ុន្តែមិនមានអ្នកណាប្រាប់គាត់។ ប៉ុន្តែចំពោះដើមបណ្តឹងរដ្ឋប្បវេណី បើគាត់មិនចងចាំ មូលហេតុអីបានជាហាក់

បីដូចជា រៀបរាប់រយៈពេលចន្លោះពី ៧១ ទៅ ៧៥ ដើម្បីឲ្យគាត់នឹកនូវការចងចាំឡើងវិញ។ ហាក់បីដូចជាគាត់ គឺថាជាអ្នកកំពុងតែបង្វឹកដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ សួរនាំមុខតំណាងដើមបណ្តឹងរដ្ឋប្ប--។ យ៉ាងហោចណាស់ក៏នាំមុខនោះដែរ។ អ៊ីចឹងសូមមេត្តាថា មិនត្រូវសួរសំណួរបែបនេះម្តងទៀតទេ។

សូមអរគុណលោកប្រធាន។

[១៥:៣៩:៤៩]

**ប្រធានអង្គជំនុំ៖**

មានអ្វីត្រូវតបនឹងការជំទាស់នេះទេ លោកសហព្រះរាជអាជ្ញាអន្តរជាតិ?

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈេ៖**

ខ្ញុំគ្រាន់តែចង់ឲ្យសាក្សីហ្នឹងបំភ្លឺរយៈពេល ហើយនិងមូលហេតុដែល អៀង សារី អាចទៅដល់ភាគពាយ័ព្យនោះ នៅក្នុងរយៈពេលនុ៎ង ក៏ប៉ុន្តែខ្ញុំអាចរៀបពាក្យពេចន៍សំណួរខ្ញុំក្រៅពីនេះក៏បានដែរ។

[១៥:៤០:៣៣]

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ កាលបើសួរឯណាឲ្យឈានទៅដល់ការធ្វើឲ្យភាគី និងសាធារណជនមើលឃើញថាជាសំណួរនាំមុខ។ ដូច្នេះសហព្រះរាជអាជ្ញារៀបចំនូវសំណួរ ចៀសវាងនូវសំណួរនាំមុខដែលអង្គជំនុំជម្រះបានរំឭក និងជម្រាបតាំងពីដំបូងនៃ មុននឹងចាប់ផ្តើមកិច្ចពិភាក្សា។ ទីពីរអង្គជំនុំជម្រះសូមរំឭកថាពេលវេលាគឺនៅសល់តិចតួចទេ សម្រាប់សហព្រះរាជអាជ្ញា ហើយសហព្រះរាជអាជ្ញាខាងជាតិទំនងជាមានសំណួរដែរ។ ដូច្នេះការសួរសូមប្រឹងប្រែងជ្រើសរើសនូវសំណួរណាដែលមានសក្តានុពលជាបឋម បន្ទាប់មកយ៉ាងហោចណាស់ក៏ជាលំដាប់បន្តបន្ទាប់ដែរ ចៀសវាងការចំណាយពេលវេលាសួរសំណួរណាដែលមិនសំខាន់ ស្រាប់តែទុកសំណួរសំខាន់រហូតដល់ពេលអង្គជំនុំជម្រះបញ្ចប់នូវការសួរដោយមូលហេតុអស់ពេលនោះ។

[១៥:៤១:៣៦]

**សួរដោយលោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈេ៖**

សូមអរគុណលោកប្រធាន។

**ស៖** ក្រៅពី អៀង សារី នោះគឺថា ពេលកិច្ចប្រជុំទីពីរនោះ ថាតើមានអ្នកដឹកនាំជាន់ខ្ពស់បានចូលរួមនៅក្នុងកិច្ចប្រជុំនោះដែរឬទេ?

**ឆ៖** ខ្ញុំសូមឆ្លើយអត់មាន មានតែពួកគាត់នោះហើយ។ អត់ពីណាទេ ក្រៅពីហ្នឹងអស់ឃើញ។

**ស៖** មានសំណួរទៀតទាក់ទងលោក អៀង សារី បន្ទាប់ពីកិច្ចប្រជុំលើកទីពីរនេះ រហូតដល់ឆ្នាំ ១៩៧៩ នេះ តើលោកបានជួបលោក អៀង សារី ដែរឬទេ? ហើយនៅក្នុងឱកាសណាដែរទៅ?

**ឆ៖** បាទ,ក្រោយគេរំដោះ អត់ឃើញហើយ មានតែពីរលើកហ្នឹងហើយ។ លើកប្រជុំនៅក-៥ នោះមួយលើក។ លើកប្រជុំនៅភូមិចាយ មួយលើក។ ពីរលើកហ្នឹងហើយ ឃើញគាត់។ ក្រៅពីនោះអត់ឃើញទេ។

[១៥:៤២:៥៤]

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាឯល៖**

សូមអរគុណ។ ខ្ញុំសូមឲ្យសហភាគារបស់ខ្ញុំចោទសំណួរក្នុងរយៈពេលដែលនៅសល់នេះបាទ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញាជាតិ!

**លោក ច័ន្ទ តារាស្មី៖**

តើខ្ញុំមានពេលប៉ុន្មាននាទីបាទ?

**ប្រធានអង្គជំនុំ៖**

ពេលនេះដល់ម៉ោងបួន។

[១៥:៤៣:២៤]

**លោក ច័ន្ទ តារាស្មី៖**

បាទ, សូមអរគុណលោកប្រធាន។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** ជម្រាបសួរលោក ក្លាន វ៉ុត ខ្ញុំឈ្មោះ ច័ន្ទ តារាស្មី សហព្រះរាជអាជ្ញារងជាតិនៅសាលាក្តីខ្មែរក្រហមនេះ។ សូមសួរសំណួរទៅលោកទាក់ទិននឹងលោក នួន ជា។ លោកធ្លាប់បាននិយាយថា កាលពីថ្ងៃទី០៦ ធ្នូ ហើយលោកក៏បាននិយាយនៅចំពោះមុខចៅក្រមស៊ើបសួរកន្លងមកថា លោកធ្លាប់បានចូលរួមវគ្គរៀនសូត្រចំនួនពីរដង ដែលវគ្គរៀនសូត្រនោះទាក់ទិនទៅនឹងការរៀនសូត្រនយោបាយ ដែលបានរៀបចំឡើងដោយលោក នួន ជា។ បានន័យថាក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ លោក

បានចូលរួមវគ្គរៀនសូត្រនោះ ដែលដឹកនាំដោយលោក នួន ជា។ ហើយកាលបរិច្ឆេទនេះ គឺថាបាន ប្រព្រឹត្តទៅនៅចន្លោះខែកក្កដា និងខែតុលា ឆ្នាំ១៩៧៥។ តើកាលបរិច្ឆេទនេះពិតប្រាកដមែនដែរឬទេ? សូមលោកឆ្លើយបាទ។

[១៥:៤៤:២៨]

**ឆ៖** បាទ ខ្ញុំឆ្លើយ។ ខ្ញុំនិយាយស្មោះត្រង់ ខ្ញុំឃើញអ៊ំ នួន ជា ពេលចុះប្រជុំនៅភ្នំពេញមានពីរលើក មានតែប៉ុណ្ណឹងទេ។ អត់ឃើញគាត់នៅព្រៃ ឃើញនៅប្រជុំនៅភ្នំពេញនោះ។ មនុស្សរាប់រយ រាប់-- ម្តងប្រាំរយ ម្តងប្រាំមួយរយកាលមុន។ អាហ្នឹងដែលឃើញគាត់។

**ស៖** តើការរៀបចំប្រជុំនោះនៅកន្លែងណាដែលលោក?

**ឆ៖** *(ឮមិនច្បាស់)*

**ប្រធានអង្គជំនុំ៖**

បើកក្បាលមេក្រូៗសិន។

**ស៖** តើការប្រជុំនេះរៀបចំនៅកន្លែងណាលោក?

**ឆ៖** ប្រជុំនៅភ្នំពេញ ប៉ុន្តែសាលាអត់ដឹងកន្លែងណាសាលាស្អីៗ សាលាកីឡាបូរី។ កាលមុនដំបូងធុំស្អុយ មុន ក្រោយគេវាយហ្នឹងធុំស្អុយ។ សាលាអត់ដឹងកន្លែងណាទេ អត់ចំណាំ។

**ស៖** តើការចូលរួមប្រជុំហ្នឹងមានកម្មាភិបាលចំនួនប៉ុន្មានរូបដែរ?

**ឆ៖** បាទ ពេញៗសាលា។ មិនដឹងប៉ុន្មាន យ៉ាងតិច៤០០- ៥០០ ទាំងអស់ ប្រទេសកម្ពុជាមុនក្រោយគេរំដោះ គេហៅប្រជុំ។

**ស៖** តើកម្មាភិបាលទាំងអស់នោះ អញ្ជើញមកពីខាងណា? តើមានមកពីថ្នាក់ឃុំ ថ្នាក់តំបន់ ឬក៏ថ្នាក់ណាផ្សេងទៀតដែរឬទេ នៅក្នុងពេលចូលរួមប្រជុំនោះ?

**ឆ៖** វាច្រើនមកពីប្រធានឃុំ ប្រធានស្រុក ប្រធានតំបន់ គ្រប់ក្រសួង។ គេប្រជុំក្រោយរំដោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ការពារ នួន ជា។

[១៥:៤៦:១៧]

**លោក ហ្សាស្តេ ប៉ោ៖**

ខ្ញុំសូមជំទាស់ទៅនឹងការសួរសំណួរមួយនេះ ដោយសារវាស្ថិតនៅក្រៅវិសាលភាពនៃអង្គហេតុ

របស់យើង ដូច្នេះហើយវាអត់មានពាក់ព័ន្ធទៅនឹងរយៈកាលដែលយើងត្រូវសួរនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ការជំទាស់គ្មានប្រសិទ្ធភាព ពីព្រោះការសួរសាក្សី ឬក៏ដើមបណ្តឹងរដ្ឋប្បវេណីដែលមកចំពោះមុខអង្គជំនុំជម្រះគឺសួរនៅក្នុងក្របខណ្ឌវិសាលភាពនៃសំណុំរឿង០០២/០១ បានសេចក្តីថា អង្គហេតុដែលអង្គជំនុំជម្រះសម្រេចយកមកធ្វើដំណាក់កាលដំបូងនេះ គឺភាគីអាចសួរបានទាំងអស់ ទាំងអង្គហេតុស្តីពីនៅវគ្គទីមួយអំពីប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា និងអង្គហេតុផ្សេងទៀត គ្រាន់តែឲ្យភាគីធ្វើយ៉ាងណាការសួរតាមលំដាប់លំដោយនៃអង្គហេតុ ដែលបានចង្អុលបង្ហាញនៅក្នុងកថាខណ្ឌនីមួយៗ តាមលំដាប់លេខរៀងពីលេខតូចទៅលេខធំប៉ុណ្ណោះ។

សូមបន្ត!

**លោក ច័ន្ទ តារាស្មី៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមអនុញ្ញាតបន្តសួរតទៀត។

**សួរដោយលោក ច័ន្ទ តារាស្មី៖**

**ស៖** លោក ក្លាន វ៉ិត ខ្ញុំសូមសួរបន្តទៀត។ តើលោកបានដឹងថា ការប្រជុំនោះដែលលោកបានចូលរួមដោយខ្ញុំបានសួរអម្បាញ់មិញនេះថា រៀបចំដោយលោក នួន ជា តើលោកដឹងថានរណាគេប្រាប់លោកថារៀបចំដោយលោក នួន ជា? នរណាគេថាការរៀបចំប្រជុំនេះគឺរៀបចំដោយលោក នួន ជា? ខ្ញុំចង់ដឹងថាតើលោកដឹងព័ត៌មាននេះដោយអ្នកណា? ពីណាអ្នកប្រាប់លោកនៅពេលនោះ?

[១៥:៤៧:៥៩]

**លោក ក្លាន វ៉ិត៖**

**ឆ៖** សូមឆ្លើយ ខ្ញុំអត់ដែលឃើញមុខមាត់ទេ ប៉ុន្តែគ្នាអ្នកសាលាប្រជុំនៅពេលគេចូលសាលាគេប្រកាសអ្នកនោះប្រធាន១នយោបាយ អានោះខាងសេដ្ឋកិច្ច អានោះខាងការពារសន្តិសុខ អាហ្នឹងគេចង្អុលមុខបាទ។ អ៊ំ នួន ជា ហ្នឹង ប្រធានគ្រូបើកវគ្គសាលានៅភ្នំពេញសាលានៅទូទាំងប្រទេសកម្ពុជា។ ហ្នឹងខ្ញុំបានស្គាល់ថា អ៊ំ នួន ជា អ៊ីចឹង។

**ស៖** អរគុណ ខ្ញុំសូមសួរទៀតថា តើលោកបានដឹងថាលោក នួន ជា មានឈ្មោះអីផ្សេងក្រៅពីឈ្មោះ នួន ជា ដែរឬទេ? ឈ្មោះក្នុងបដិវត្តន៍ ឈ្មោះដែលគាត់ប្រើប្រាស់នៅក្នុងបដិវត្តន៍នោះបាទ?

**ឆ៖** អត់ដឹងទេ។ ដឹងតែឈ្មោះជាមួយអ៊ំ នួន ជា។ មានតែអ៊ំ ពត មានតែអ៊ំ អៀង សារី ដែលអ៊ំ អៀង សារី ផង បង វ៉ាន់ ផង។ ឈ្មោះគាត់មានដែលខ្ញុំចំណាំ ឈ្មោះ នួន ជា ហ្នឹងហើយបាទ។

**ស៖** តើលោកបានជួបលោក នួន ជា ដែរឬទេនៅមុនឆ្នាំ១៩៧៥ នៅមុនខែកក្កដា ឆ្នាំ១៩៧៥ ឬអាចនិយាយម្យ៉ាងទៀតថា នៅចន្លោះឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ តើលោកបានជួបលោក នួន ជា ដែរឬទេ? បើជួបនៅកន្លែងណា? ដោយមូលហេតុអី?

**ឆ៖** ខ្ញុំឃើញតែពីរដង អង្កាល់គាត់ហៅបើកវគ្គនៅភ្នំពេញហ្នឹងហើយឃើញ អង្កាល់ខ្ញុំនៅព្រៃ នៅភ្នំ អត់ឃើញទេ។ ឃើញតែពីរដង។ ចប់។

[១៥:៤៩:២៨]

**ស៖** តើលោកបានដឹងអំពីលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានកំណត់អំពីតួនាទីភារកិច្ចរបស់កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា កំណត់នៅមុនឆ្នាំ១៩៧៥ មុនខែមេសា ឆ្នាំ១៩៧៥ តើលោកបានដឹងអំពីការកំណត់អំពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬក៏តួនាទី ភារកិច្ចរបស់កម្មាភិបាល ដែលត្រូវធ្វើអីខ្លះ មិនត្រូវធ្វើអីខ្លះដែរឬទេនៅពេលនោះ?

**ឆ៖** ខ្ញុំបាទ ខ្ញុំអត់យល់ទេ គឺថាបក្សកុម្មុយនីស្តស្អី? គេផ្សព្វផ្សាយគេថា មនុស្សយើងពិចារណាធ្វើកម្មាភិបាល ទាល់តែមានរៀនឱ្យលក្ខន្តិកៈ។ លក្ខន្តិកៈយ៉ាងម៉េច? ខ្ញុំថា លក្ខន្តិកៈកាចក់នេះអត់ចេះទេលក្ខន្តិកៈ។ គេថា លក្ខន្តិកៈអ៊ីចេះ ទីមួយតស៊ូដាច់ខាត បើខ្មាំងចាប់មិនប្រាប់អ្នកនោះអ្នកនេះទេគ្នាយើង។ ស្លាប់ម្នាក់ឯង រស់ម្នាក់ឯង បើស្លាប់បម្រើបក្ស បម្រើប្រជាជន បើរស់បម្រើបក្សបម្រើប្រជាជន។ ទីមួយ កុំឱ្យបើខ្មាំងចាប់កាប់សម្លាប់កុំឱ្យប្រាប់បងប្អូនគ្នាយើង។ ទីពីរ មិនលាក់លួចរបស់គេ, ទីបី មិនដណ្ដើមសិទ្ធិអំណាចធ្វើបដិវត្តន៍។ អាហ្នឹងគេថាលក្ខន្តិកៈ ទីបីកូនគេល្អ ប្រពន្ធគេល្អកុំស្រឡាញ់របស់គេប្រពន្ធគេ អាហ្នឹងគឺថាលក្ខន្តិកៈរបស់បក្សកុម្មុយនីស្ត។ ខ្ញុំស្ដាប់គេប្រាប់អ៊ីចឹង--

**ស៖** លោក ក្លាន រ៉ិត ខ្ញុំចង់សួរលោកថា តើលោក នួន ជា ពេលនុ៎ងគឺមានឋានៈត្រឹមណាដែរ? មុខនាទីគាត់ ឋានៈគាត់ត្រឹមណាដែរនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំអត់ដឹងថ្នាក់ទេ លោក១ខ្ញុំឃើញតែគេថា គេហៅមករៀនភ្នំពេញគេថាគណៈមជ្ឈិមគណៈភូមិភាគ វាអស់អ៊ំពត អ៊ំ អៀង សារី អ៊ំ ខៀវ សំផន គ្រាន់តែប៉ុណ្ណឹងទេ ឮគេនិយាយភាគច្រើន។ ខ្ញុំអត់ដឹងទេ។ ឮគេនិយាយប្រាប់ខ្ញុំ សាកចង្អុលមុខអានេះ អ៊ំ នួន ជា អានេះអ៊ំ អៀង សារី អានេះអ៊ំ ខៀវ សំផន អ្នកធំជាងគេប្រធានណា អ៊ំ ប៉ុល ពត។ ខ្ញុំស្ដាប់តែប៉ុណ្ណឹងទេ។

**ស៖** លោក ក្លាន រ៉ិត ថាតើការមករៀនបណ្តុះបណ្តាលនៅទីក្រុងភ្នំពេញហ្នឹង គេរៀនក្នុងគោលបំណងអ្វី? គេអញ្ជើញលោកមករៀនក្នុងគោលបំណងអ្វី?

**ឆ៖** គេបង្រៀនឲ្យយល់ប្រទេសជាតិឯករាជ្យហើយ ត្រូវតែយើងម្ចាស់ការ បើយើងមិនម្ចាស់ការគ្រប់គ្រងរៀងៗខេត្ត រៀងៗស្រុកហ្នឹងអាចខ្មាំងវាក្តាប់ទៀត វាកើតទៀតអ៊ីចឹង។ គេអប់រំមកថាយើងថែរក្សា មាតុភូមិខ្លួនឯង ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់តំបន់ ថ្នាក់ភូមិភាគ ថ្នាក់មជ្ឈិម យើងប្រទេសជាតិឯករាជ្យ ហើយ។

**ស៖** លោកបាននិយាយថា លោកធ្លាប់ចូលរួមការរៀនសូត្រនៅវគ្គទីពីរ នៅបុរីកីឡានៅទីក្រុងភ្នំពេញជាមួយនឹងលោក នួន ជា។ តើលោកអាចពន្យល់បានទេថា មានមេដឹកនាំណាខ្លះដែលបានចូលរួមរៀនសូត្រនៅក្នុងវគ្គនោះនាពេលនោះបាទ?

**ឆ៖** ខ្ញុំអត់ដឹងទេ ខ្ញុំគ្រាន់តែដើរមុខគាត់ប្រធានសាលាមានតែប៉ុណ្ណឹង។

**ស៖** នៅពេលដែលលោកចូលរួមរៀនវគ្គនយោបាយ ឬក៏វគ្គបណ្តុះបណ្តាលជាមួយលោក នួន ជា នៅពេលនោះ តើលោក នួន ជា បាននិយាយអ្វីខ្លះ នៅក្នុងពេលនោះ?

[១៥:៥២:៥៨]

**ឆ៖** គេនិយាយបើកឯកសារហ្នឹងហើយ ឯកសារថា យើងកសាងមាតុភូមិ ការពារប្រទេសជាតិយើង យើងបានឯករាជ្យហើយ មានតែប៉ុណ្ណឹងទេគេឃោសនា ប៉ុន្តែខ្ញុំនិយាយខ្មែរមិនទាន់ចេះខ្មែរផង និយាយលាវ មិនទាន់ចេះ ចេះតែស្តាប់មកអង្គុយ ដល់ឥឡូវបានចេះនិយាយខ្មែរបន្តិចបន្តួច។ មិនដឹងគេថាយ៉ាងម៉េច បើមិនទៅមិនមក ខ្លាចគេហៅមកអ៊ីចឹង។ ប៉ុន្តែការយល់មិនទាន់យល់ទេ មកដោយសារខ្លាច ធ្វើដោយសារខ្លាចដល់សព្វថ្ងៃ។

**ស៖** ការរៀនសូត្រហ្នឹងមានរយៈពេលប៉ុន្មានដែរ លោក ក្លាន រ៉ិត?

**ឆ៖** មួយលើកៗបានបីថ្ងៃ ភាគច្រើន បីថ្ងៃ បួនថ្ងៃ។ លើកទីមួយ បីថ្ងៃ លើកទីពីរទៀត បួនថ្ងៃ មានតែប៉ុណ្ណឹងទេ មនុស្សវាច្រើនអត់យូរទេ។

**ស៖** ការរៀនសូត្រវគ្គទីពីរនោះ តើមានកម្មាភិបាលចូលរួមមានអ្នកណាខ្លះលោកមានចាំទេ?

**ឆ៖** មានបងប្អូនខ្មែរគាត់គ្រប់ខេត្ត គាត់ថានេះបងប្រធានខេត្តនេះ ខេត្តនោះៗ។

**ស៖** នៅក្នុងពេលដែលលោក នួន ជា បាននិយាយនៅក្នុងពេលប្រជុំវគ្គរៀនសូត្រនោះ តើលោក នួន ជា បាននិយាយអំពីប្រវត្តិរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ឬទេនៅពេលនោះបាទ?

**ឆ៖** ប៉ុន្តែគេមានប្រវត្តិដែរ ប៉ុន្តែខ្ញុំអត់យល់គេថាបក្ស មិនដឹងយ៉ាងម៉េចបក្ស? មិនដឹងយ៉ាងម៉េចកុម្មុយនីស្ត? ឮដែរ យ៉ាងម៉េចគេថាបក្ស? យ៉ាងម៉េចគេថាកុម្មុយនីស្ត អត់យល់។ ខ្ញុំសួរគេភាគច្រើន បងប្អូន គេថា អ៊ីចេះៗ។ ខ្ញុំអត់ហ៊ានទេសួរគាត់ ខ្ញុំសួរអ្នកក្រៅនៅពេលសម្រាកចេញពីសាលានោះ អាហ្នឹងបានខ្ញុំបានដឹង។

**ស៖** នៅក្នុងអង្គប្រជុំនោះ តើលោក នួន ជា បាននិយាយអំពីវិន័យរបស់បក្សដែរឬទេ ដល់សមាជិកអង្គប្រជុំនោះបាទ?

[១៥:៥៤:៤៥]

**ឆ៖** មាននិយាយដែរ ប៉ុន្តែខ្ញុំអត់ដឹងថា របៀបរបបនិយាយអ៊ីចេះៗ ប៉ុន្តែគេលើកមានឮគាត់លើកមានឯកសារ។ ឯកសារមានច្រើន (ឮមិនច្បាស់) ដល់ចុងបំផុតមានឆ្លងជីវទស្សន៍ ចុងបំផុត មួយថ្ងៃឆ្លងជីវទស្សន៍។ ឆ្លងជីវទស្សន៍អ្នកធ្វើកម្មាភិបាល អ្នកធ្វើកម្មាភិបាល ឧទាហរណ៍ មួយខេត្តគេយកម្នាក់ៗ ឆ្លងជីវទស្សន៍ ដើម្បីកសាងឲ្យមានជំហរដឹកនាំប្រទេសជាតិមាតុភូមិខ្លួនឯង។ ប៉ុណ្ណឹង ខ្ញុំនៅចំណាំតែប៉ុណ្ណឹង។

**ស៖** នៅក្នុងវគ្គរៀនសូត្រនោះ តើលោកបានឮគេនិយាយអំពីពាក្យសហករណ៍ ពាក្យថាតំបន់ ពាក្យថាប្រជាជនថ្មី ឬ/និងពាក្យថា សត្រូវ ខ្មាំងសត្រូវ តើលោកមានបានឮពាក្យទាំងអស់ហ្នឹងដែរឬទេបាទ?

**ឆ៖** អាហ្នឹង ខ្ញុំនិយាយឲ្យស្មោះត្រង់អត់មានឮទេអ៊ីចឹង។ ខ្ញុំអត់ឮ រឿងប្រវត្តិបក្សនោះទេ អត់ឮ។ ថាអ្នកនោះ អ្នកថ្មី អ្នកក្រអ៊ីចេះអ៊ីចុះ អត់ឮ។

[១៥:៥៦:០១]

**ស៖** លោក ក្លាន រ៉ិត នៅក្រោយពេលដែលវគ្គរៀនសូត្របានចប់លើកទីពីរ ជាមួយនឹងលោក នួន ជា តើមានការបែងចែកកាំភ្លើងដល់កងឈ្លប ឬក៏ដល់សន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? ហើយបើមានការបែងចែកវិញ បើសិនជាមាន តើហេតុអ្វីបានជាមានការបែងចែកអាវុធឲ្យទៅខាងទាំងអស់នោះបាទ?

**ឆ៖** ក្រោយគេរំដោះ គេចាត់តាំងឈ្លបគ្រប់ភូមិ។ មួយឃុំនុ៎ង ២០នាក់ មួយឃុំ២០នាក់។ ហេតុអី គេថាការពារតាមឃុំ តាមស្រុកតាមខេត្ត ខ្លាចខ្មាំងវាបង្កើតសង្គ្រាមទៀត ដើម្បីការពារ។ ប៉ុន្តែជាក់ស្តែងមានបង្កប់មែន កាំភ្លើងនៅឃុំ២០ដើម។ ជាក់ស្តែងនៅស្រុក២១ ពីដើម។

**ស៖** លោកប្រធាន ដោយសារតែអត់មានពេល ខ្ញុំសូមអនុញ្ញាតសួរសំណួរបន្តិចទាក់ទងនឹងលោក ខៀវ សំផន បាទ។ លោក ក្ហាន រិត ខ្ញុំសូមសួរលោកទាក់ទងនឹងលោក ខៀវ សំផន។ តើលោកបានជួបជាមួយលោក ខៀវ សំផន ដែរឬទេ មុនពេលដែលទីក្រុងភ្នំពេញត្រូវបានរំដោះដោយខ្មែរក្រហម បើសិនជាបានជួប តើលោកជួបនៅកន្លែងណា? ហើយជួបនៅពេលណា?

[១៥:៥៧:២២]

**ឆ៖** សូមឆ្លើយ ខ្ញុំនិយាយស្មោះត្រង់ អត់ឃើញទេអ៊ំ។ អត់ឃើញ អត់ដែលឃើញ។ មួយដងខ្ញុំអត់ដែលឃើញជួបអ៊ំ អ៊ំ ខៀវ សំផន។ ខ្ញុំអត់ដឹងឈ្មោះ អត់ដឹងមុខមាត់សោះ។ ខ្ញុំអត់ដឹង អត់ឃើញ អត់ដែលឃើញ។ ឮគេថា លោក ខៀវ សំផនៗ អ្នកការពារប្រទេស មានតែឮប៉ុណ្ណឹងទេ ឮតាមគេនិយាយទូទៅ។ អត់ឃើញ អត់បានជួបទេ។

**ស៖** តើលោកស្គាល់-- លោកបានដឹងឮពាក្យគេថា ក៥ ទេបាទ។ តើ ក៥ មានន័យដូចម្ដេច? ហើយតើលោកបានដឹងថាមានការប្រជុំនៅក្នុងព្រៃ នៅក្នុងពេលនោះ តើលោកបានដឹងរឿងហ្នឹងដែរឬទេបាទ?

**ឆ៖** ដឹងឮ កាលហ្នឹងមានមែន ប្រជុំព្រៃ។ ប្រជុំនៅព្រៃហ្នឹង កាលហ្នឹង យើង មិនទាន់រំដោះ ប្រជុំនៅព្រៃ ឮគេហៅឈ្មោះ គណៈភូមិភាគហ្នឹង ទាំងអស់ហ្នឹង ប៉ុល ពត, អ៊ំ អៀង សារី, នួន ជា, ខៀវ សំផន ថា ខៀវ សំផន ហ្នឹង អ្នកការពារប្រទេស។ ខ្ញុំឮថាគេថាប៉ុណ្ណឹង។

[១៥:៥៨:២៥]

**ស៖** តើលោកបានដឹងថា លោក ខៀវ សំផន មានឈ្មោះផ្សេងដែលប្រើប្រាស់នៅក្នុងចលនាបដិវត្តហ្នឹងដែរឬទេ ក្រៅឈ្មោះ ខៀវ សំផន តើគាត់មានឈ្មោះអ្វីផ្សេងក្រៅពីហ្នឹងដែរឬទេបាទ?

**ឆ៖** អត់ដឹងទេ អត់ឮទេ អត់ដឹងទេ។ ដឹងមានភារកិច្ចស្អី ខ្ញុំអត់ដឹងទេ។

**ស៖** តើលោកបានដឹងថា លោក ខៀវ សំផន ហ្នឹង មានមុខតំណែងតួនាទីថ្នាក់កម្រិតណាដែរនៅក្នុងបក្សកុម្មុយនីស្តកម្ពុជានាពេលនោះ បាទ?

**ឆ៖** អត់ដឹងឮទេលោក អត់ដឹងទេ។ និយាយស្មោះត្រង់។

**ស៖** តើលោកបានជួបលោក ខៀវ សំផន នៅក្រោយខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ? ប្រសិនបើបានជួបៗ តើជួបនៅកន្លែងណា? ហើយជួបនៅពេលណា?

**ឆ៖** អ៊ំ ខៀវ សំផន អត់ដែលជួបសោះ និយាយស្មោះត្រង់។

**ស៖** តើលោកបានដឹងមុខតំណែងរបស់លោក ខៀវ សំផន ក្រោយខែមេសា ឆ្នាំ១៩៧៥ ដែរឬទេ?

**ឆ៖** អត់ដឹងទេ។ អត់ដឹងសោះ ស្អីក៏អត់ដឹងសោះ។ អត់ដែលឃើញមុខមាត់ អត់ដែលឮ អត់ជួបប្រជុំជាមួយគាត់ទេ។

**ស៖** លោក ក្លាន រិត ទាក់ទងនឹងវិទ្យុដែលបានផ្សាយ។ ខ្ញុំសូមឲ្យលោកបំភ្លឺជូនអង្គសវនាការនៅពេលនេះ ឲ្យបានជ្រាបថា តើនៅភូមិភាគព្លិសាននៅចន្លោះរយៈពេលនៃការធ្វើរដ្ឋប្រហារនៃរបបលន់ នល់ ហើយនិងជ័យជម្នះខែមេសា ឆ្នាំ១៩៧៥។ តើលោកបានឮវិទ្យុ-- តើបានដឹងឮថាមានវិទ្យុផ្សព្វផ្សាយបញ្ហាដែរឬទេ នៅក្នុងតំបន់ភូមិភាគព្លិសាននាពេលនោះបាទ?

[១៥:៥៩:៥៦]

**ឆ៖** ដឹងឮដែរ ប៉ុន្តែដឹងឮ ខ្ញុំនិយាយខ្មែរ វាអត់ចេះស្តាប់ខ្មែរ គេផ្សាយរឿងឯករាជ្យអីចេះៗឮដែរ គេថាយើងជ័យជម្នះហើយ។ ប៉ុន្តែក្នុងខ្លឹមសារហ្នឹង ខ្ញុំអត់ចេះនិយាយខ្មែរ។ ខ្ញុំចេះតែនិយាយលាវ។

**លោក ច័ន្ទ តារាស្នើ៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតសួរសំណួរចុងក្រោយទាក់ទងទៅនឹងបញ្ហាជម្លៀសប្រជាជនពីទីក្រុងភ្នំពេញបាទ។

**សួរដោយលោក ច័ន្ទ តារាស្នើ៖**

**ស៖** ជាសំណួរចុងក្រោយរបស់ខ្ញុំ លោក ក្លាន រិត តាមការយល់ដឹងរបស់លោក តើលោកមានដែលឮគេនិយាយអំពីពាក្យថា "ប្រជាជនថ្មី" អំពីការជម្លៀសប្រជាជនចេញពីទីក្រុង ទៅតំបន់ភូមិភាគព្លិសាន ទៅតំបន់ផ្សេងៗនៅក្នុងប្រទេស ឬទៅតាមភូមិឃុំផ្សេងៗនៅក្នុងប្រទេសកម្ពុជាដែរឬទេ?

**លោក ក្លាន រិត៖**

**ឆ៖** បាទ អាហ្នឹងខ្ញុំឃើញនឹងភ្នែក។ បងប្អូនមកពីក្រោមហ្នឹងគឺ ពេលគេធ្វើសហករណ៍ហ្នឹងគេបញ្ចូលទៅក្នុងភូមិនេះ ក្នុងឃុំនេះ ក្នុងស្រុកនេះនៅជាប់៨០០នាក់ បងប្អូនខ្មែរមកពីក្រោមនោះនៅផ្លូវលេខ១៩ មានតែបងប្អូនខ្មែរ ដែលគេមកនៅចូលនៅនោះ។ នោះនៅភូមិស្រែគរនោះក៏មានដែរច្រើនបងប្អូនខ្មែរមកពីក្រោម អាហ្នឹងខ្ញុំឮ។ ឮផងឃើញជាក់ស្តែងគេធ្វើស្រែសហករណ៍ គេកូសដីស្រែឃើញ

ជាក់ស្តែងលោកអត់ប្រកែកទេ។

**ស៖** តើលោកដឹងថា ប្រហែលជាប៉ុន្មានថ្ងៃ រយៈពេលប៉ុន្មានថ្ងៃក្រោយពីមានការដួលរលំរបបទីក្រុងភ្នំពេញ កាលសម័យនោះ ហើយមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅពេលនោះ តើប្រហែលជាប៉ុន្មានថ្ងៃក្រោយពីការដួលរលំនៃទីក្រុងភ្នំពេញនោះបាទ?

[១៦:០១:២៦]

**ឆ៖** អាហ្នឹងលោកប្រធានខ្ញុំអត់ចំណាំទេជាមួយគេ ប៉ុន្តែខ្ញុំប្រជាជនកាលនៅព្រៃភ្នំអត់ទាក់ទងខ្ញុំជួបអង្គការពេលហៅប្រជុំ ឃើញគេបើកាលអ៊ីចឹងខ្ញុំអត់ឃើញជាក់ស្តែងកំណត់ថ្ងៃណាៗប៉ុន្មានថ្ងៃប៉ុន្មានពេលអត់ដឹងទេលោកប្រធាន។ ខ្ញុំសូមប៉ុណ្ណឹង។

**ស៖** លោកមានបានដឹងឮគេនិយាយទេ មានដឹងឮបក្សកុម្មុយនីស្តកម្ពុជានិយាយ ឬកម្មាភិបាលណានិយាយ ឬថ្នាក់ដឹកនាំបក្សកុម្មុយនីស្តណានិយាយថា ហេតុអ្វីបានជាមានការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញកាលសម័យនោះ? តើលោកមានបានដឹងឮទេរឿងហ្នឹងបាទ?

**ឆ៖** បាទ, អត់ដឹងឮទេ។ ឃើញតែគេជម្លៀសប្រជាជន។ កាលពួកខ្ញុំនៅ គេចាប់ខ្ញុំយកនៅភ្នំពេញនោះ ឃើញគេដឹកមកខេត្តព្រៃវែង ពីខេត្តតាកែវ ដឹកមកខាងនេះដាក់នៅឯរថក្រោះនៅរាល់ថ្ងៃនេះ។ អាហ្នឹងឃើញជាក់ស្តែងមែន។ ខ្ញុំថា ម៉េចដឹកបងប្អូនមកពីនោះ? គេថាពួកវានៅផ្ទាល់ជាមួយស្រុកយួន ដឹងគេដឹកមកនេះខ្លាចពួកគេរត់ទៅ។ ឮគេថាអ៊ីចឹង ឮពួកកងពលនៅភ្នំពេញហ្នឹងហើយគេពួកគេគ្រប់គ្រងពួកខ្ញុំៗ។ ខ្ញុំសូមអស់។

[១៦:០២:៤០]

**ស៖** ខ្ញុំសូមសួរពីរសំណួរតូចចុងក្រោយបាទ។ លោកមានបានដឹងទេថាតើមានឮគេនិយាយ ឬក៏លោកបានឮថាអង្គការបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយលោកមានបានដឹងថាបានឃើញទេថា ការរស់នៅរបស់ប្រជាជនថ្មី ដែលជម្លៀសចេញពីទីក្រុងទៅនៅតាមតំបន់ភូមិភាគផ្សេងៗនៅក្នុងប្រទេសកម្ពុជាហ្នឹងជួបទិដ្ឋភាពងាយស្រួល ឬលំបាកយ៉ាងណាខ្លះដែរឬទេបាទកាលហ្នឹង?

**ឆ៖** ឃើញការលំបាកហើយ។ ខ្ញុំថា បើខ្ញុំអត់ប៉ិនមាត់ប៉ិនក គ្រាន់តែខ្ញុំសួរប៉ុណ្ណឹង ខ្ញុំខ្លាចខ្លាចអង្គការចូលការងារគេ។ ដឹងថាលំបាកមែនហើយ។ ឧទាហរណ៍ ដូចពួកខ្ញុំខាងលើនេះ ភូមិនេះទៅរស់នៅភូមិនោះ ទៅរត់នៅព្រៃនៅអីខ្លាចយួនវ៉ៃអាហ្នឹងឃើញជាក់ស្តែង គឺថាដឹកខ្លាចយួនវ៉ៃ ពួកខេត្ត

ព្រៃវែង ខេត្តស្វាយរៀង ខ្ញុំឮគេប្រាប់អ៊ីចឹង។

[១៦:០៣:៣៨]

**ស៖** បាទសំណួរចុងក្រោយ តើប្រជាជនថ្មី ដែលរស់នៅតំបន់ដែលលោកបានឃើញផ្ទាល់ភ្នែក លោកបានដឹងថា នរណាគេជាអ្នកបញ្ជាគ្រប់គ្រងតាមដានឃ្លាំមើល ដាក់បទបញ្ជាផ្សេងៗទៅលើប្រជាជនថ្មីនៅតំបន់នោះ? តើអ្នកណាគេជាអ្នកដាក់បញ្ជាហ្នឹង? អ្នកណាអនុវត្តតាមបញ្ជាហ្នឹងបាទ? សូមអរគុណ។

**ឆ៖** អ៊ំៗហ្នឹងហើយមានពីណាធំជាងនោះទៀត។ មានពួកអ៊ំ ពក អ៊ំ អៀង សារី អ៊ំ-- មានគេធ្វើធំៗគណៈភូមិភាគហ្នឹងហើយ។ ក្រៅពីហ្នឹងពីណាប៉ាន ក្រៅពីពួកគាត់នោះពីណាប៉ានទៀត។

**លោក ច័ន្ទ តារាស្មី៖**

ខ្ញុំអរគុណលោក ក្លាន រ៉ិត ដែលបានបកស្រាយសំណួររបស់ខ្ញុំយ៉ាងក្បោះក្បាយ ហើយខ្ញុំសូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំសួរសំណួរចប់ចុងចប់ដើមសូមអរគុណ។ សូមអរគុណ។

[១៦:០៤:២៧]

**ប្រធានអង្គជំនុំ៖**

អរគុណសហព្រះរាជអាជ្ញា។ អរគុណលោក ក្លាន រ៉ិត។

ឥឡូវនេះដោយសារពេលវេលាសមល្មមនឹងឈប់សម្រាកហើយ នៅសម្រាប់សវនាការនៅរសៀលនេះ។

[១៦:០៤:៣៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៥:៣០]

**ប្រធានអង្គជំនុំ៖**

បាទ, មុននឹងបញ្ចប់ដោយសារដដែល រឿងដដែល វាកើតឡើងបីដងហើយ នៅក្នុងការសួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សាជាថ្មីទៀត ដោយសារអម្បាញ់មិញនេះ មានមេធាវីដូចជាមេធាវី ខៀវ សំផន ប្រកាន់ជំហរមួយថា រង់ចាំស្តាប់នូវការសួរដេញដោលពីភាគីសហព្រះរាជអាជ្ញា ដើម្បីខ្លួនមានសំណួរ ឬក៏គ្មានសំណួរ។ ឥឡូវនេះបានស្តាប់ចប់ហើយផ្នែកខាងភាគីចោទប្រកាន់។

ដូច្នេះអង្គជំនុំជម្រះដើម្បីច្បាស់លាស់លើ ក្នុងការរៀបចំផែនការសកម្មភាពក្នុងការគ្រប់គ្រង

ដឹកនាំសវនាការ នៅថ្ងៃស្អែក និងថ្ងៃបន្តបន្ទាប់ទៀត។ សំណួរសួរថា តើក្រុមមេធាវីរបស់លោកមានសំណួរដែរទេ? មេធាវី ខៀវ សំផន?

[១៦:០៦:៣៧]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ដោយសារក្រុមរបស់យើងខ្ញុំនៅក្រោយគេ។ ដូច្នេះ វានៅតែជាបញ្ហាចោទដដែល ពីព្រោះថា មិនដឹងថាខាងមុខនឹងឆ្លើះ ឬលើកយកបញ្ហាអ្វីខ្លះដើម្បីតាំងសំណួរដល់ដើមបណ្ដឹងរដ្ឋប្បវេណី។ បាទ, សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវីការពារក្ដី អៀង សារី តើប្រកាន់ជំហរយ៉ាងម៉េចទៅ? ឥឡូវនេះដល់ពេលភាគីខាងដើមចោទ ខាងចោទប្រកាន់ចោទសួរអស់ហើយ។ តើនៅតែប្រកាន់ថាមានសំណួរត្រូវសួរដល់ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ឬក៏មិនមានទេ? ពីព្រោះឃើញចុងក្រោយនេះ មេធាវីបានស្នើសុំនូវពេលវេលាសមស្របរួចហើយ ស្រាប់តែចុងក្រោយបានប្ដូរនូវជំហរមិនតាំងសំណួរវិញ។ ដូច្នេះ ដើម្បីរៀបចំនូវកិច្ចដំណើរការដេញដោលសវនាការនេះឲ្យបានល្អប្រសើរ និងប្រើពេលវេលាឲ្យមានប្រសិទ្ធភាព សូមបង្ហាញជំហរជាថ្មីម្ដងទៀត។

[១៦:០៧:៤០]

**លោក អាង ឧត្ដម៖**

សូមគោរពលោកប្រធាន។ ខ្ញុំបាទ សូមបញ្ជាក់ច្បាស់ថា ក្រុមមេធាវីលោក អៀង សារី មិនដូរជំហរទេ។ ក្រុមយើងខ្ញុំនឹងសួរសំណួរ លោកសាក្សីរូបនេះនៅថ្ងៃស្អែកដដែលក្នុងរយៈពេលប្រមាណ៣០នាទី។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក សុន អរុណ!

**លោក សុន អរុណ៖**

សូមគោរពលោកប្រធាន ខ្ញុំជាមេធាវីរបស់ នួន ជា នឹងមានសំណួរទៅលោក ក្លាន រ៉ុត នៅពេលស្អែក។

**ប្រធានអង្គជំនុំ៖**

អំមិញមេធាវីអន្តរជាតិថាមិនសួរទេ។ ពីព្រោះប្រកាន់ជំហរដូចពីព្រឹកមិញ ចំពោះ រម៉ាម យុន អ៊ីចឹងហើយយើងមិនសួរអម្បាញ់មិញនេះ។ ហើយការដែលមិនសួរ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យធ្វើដូចព្រឹកមិញទេ បើមិនសួរគឺចប់ ពីព្រោះអង្គជំនុំជម្រះផ្តល់វេទិកាឲ្យសួរ មិនផ្តល់វេទិកាឲ្យជំទាស់ឡើយ។

[១៦:០៨:៥៦]

ឥឡូវនេះលោកប្រកាន់ជំហរក្នុងការសួរ តើត្រូវចំណាយពេលវេលាប៉ុន្មានទៅ?

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមបញ្ជាក់ជំហររបស់ខ្ញុំឡើងវិញ--

**ប្រធានអង្គជំនុំ៖**

អំមិញយើងបានអនុញ្ញាតឲ្យលោក សុន អរុណ មិនមែនលោកមេធាវីអន្តរជាតិការពារ នួន ជា ទេ។ លោក សុន អរុណ អ្នកនិយាយ។ លោក សុន អរុណ មិនទាន់បានឆ្លើយនឹងសំណួររបស់អង្គជនុំជម្រះទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានសាជាថ្មី។ ខ្ញុំមានប្រហែលជា២០នាទី សម្រាប់ពេលស្អែក។

សូមអរគុណ!

[១៦:០៩:៤៥]

**ប្រធានអង្គជំនុំ៖**

អរគុណនូវការបង្ហាញនូវជំហរជាក់លាក់ ដើម្បីអង្គជំនុំជម្រះក្នុងការរៀបចំកាលវេលាសម្រាប់ផែនការសកម្មភាពនៃកិច្ចពិភាក្សាដេញដោលសម្រាប់ថ្ងៃស្អែក។ ហើយវាក៏ជាបទពិសោធន៍សម្រាប់ទៅថ្ងៃមុខដែរ នៅក្នុងកិច្ចដំណើរការនេះ។

លោក ក្លាន វ៉ុត អង្គជំនុំជម្រះអរគុណលោកដែលបានមកផ្តល់សក្ខីកម្ម តាមការកោះហៅ។ ក៏ប៉ុន្តែដោយសារកិច្ចដំណើរការដេញដោលចំពោះលោកសម្រាប់រសៀលនេះ គឺបានត្រឹមតែភាគីខាងសហព្រះរាជអាជ្ញាប៉ុណ្ណោះ។ ដូច្នេះ នៅខាងភាគីមេធាវីការពារក្តីបីក្រុម ដែលលោកបានស្តាប់ហើយម្នាក់ៗ គឺមួយក្រុមអាចចំណាយពេលវេលាសួរពីរ ២០ ទៅ ៣០នាទី។

ដោយតាមផែនការ គឺអង្គជំនុំជម្រះ នៅថ្ងៃស្អែកព្រឹកឡើងត្រូវសួរដេញដោលទៅលើជនជាប់ចោទ នួន ជា។ ដូច្នេះ ចំពោះរូបលោក អង្គជំនុំជម្រះកំណត់កាលបរិច្ឆេទសម្រាប់ការសួរដេញដោលបន្តនៅថ្ងៃស្អែកវេលារសៀល ចាប់ពីម៉ោងមួយនិងសាមសិបនាទី។ ហេតុដូច្នេះ សូមលោកអញ្ជើញមកកាន់សាលសវនាការឲ្យបានតាមការកាលកំណត់នេះ។ ហើយសូមឲ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញសម្របសម្រួលកន្លែងស្នាក់នៅ ហើយនិងរៀបចំដំណើរឲ្យគាត់ ដើម្បីឲ្យគាត់បានមកដល់កន្លែងសាលសវនាការនេះឲ្យបានមុនម៉ោងមួយ និងសាមសិបរសៀលថ្ងៃស្អែក។

[១៦:១១:៤៥]

ពេលវេលាសវនាការដេញដោលសម្រាប់ថ្ងៃនេះ សមល្មមដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃត្រឹមនេះ។ សវនាការនឹងលើកទៅបន្តធ្វើនៅព្រឹកនៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹក។

អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទាំងបីរូបត្រលប់ទៅកាន់មន្ទីរឃុំឃាំងវិញ ហើយនិងឲ្យនាំខ្លួនគាត់ទាំងបីរូបមកកាន់សាលសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។

សូមអញ្ជើញសម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១៣ នាទី)*